OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Apr-2015, 15:05
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៧០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែនៃ
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

កញ្ញា រ៉ូប៊ីន្នី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ួច អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ថាន់ ធីម (2-TCCP-288) | ខ្មែរ |
| លោក ពេជ្រ ជឹម ហៅ តាជឹម (2-TCW-809) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ថាន់ ឌីម** (2-TCCP-288)

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ....................................ទំព័រ ៤
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី ....................................ទំព័រ ៨
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................ទំព័រ ៣៦
សួរដោយលោក គង់ សំអុន ផ្តើមពី ....................................ទំព័រ ៤៥
សួរដោយលោក អាកទូរ វែកគែន ផ្តើមពី ....................................ទំព័រ ៤៨

**ការសួរសំណួរទៅសាក្សី៖ ពេជ្រ ជីម ហៅ តាជីម** (2-TCW-809)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................ទំព័រ ៥៣
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................................ទំព័រ ៥៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលភស្តុតាងក្នុងសំណុំរឿង០០២/០២។ សវនាការនៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ថាន់ ធីម។ ដូចដែលអង្គជំនុំជម្រះបានជម្រាបជូនដំណឹងដល់ភាគីកាលពីថ្ងៃសុក្រ ទី០៣ មេសា ២០១៥ និងបញ្ជាក់បន្ថែមតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងនៅពេលក្រោយមក។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺលោក ថាន់ ធីម។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះផងដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-809។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅព្រឹកនេះ មុនពេលមកផ្តល់សក្ខីកម្ម។ លោកមានមេធាវីប្រឹក្សា គឺលោកមេធាវី មឿន សុវណ្ណ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ៊ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាពខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬក៏ដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាព ជនជាប់ចោទ នួន ជា នៅ អ.វ.ត.ក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មានអាការៈឈឺចង្កេះ ពេលអង្គុយយូរនិងវិលមុខ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញលោក ថាន់ ធីម ចូលកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះ

មុខអង្គជំនុំជម្រះ។

*(ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីប្រឹក្សាចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:១៩]

**ប្រធានអង្គជំនុំ៖**

សួស្ដីលោក ថាន់ ធីម! ថ្ងៃនេះអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោក ពាក់ព័ន្ធជាមួយនឹងអង្គហេតុដូចអង្គជំនុំជម្រះបានជម្រាបជូនលោករួចហើយកាលពីអំឡុងនៃដំណើរការសវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលបានធ្វើកាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥។ ហើយដោយសារចម្លើយរបស់លោកមានការពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុជាច្រើនដូច្នេះភាគីបានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោកលើអង្គហេតុក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយថ្ងៃនេះអង្គជំនុំជម្រះកំណត់ធ្វើសវនាការស្ដាប់សក្ខីកម្មរបស់លោកលើអង្គហេតុ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគីនិងសាធារណជនជ្រាបថាដោយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ថាន់ ធីម ត្រូវបានអង្គជំនុំជម្រះសួរបញ្ជាក់ពីអត្តសញ្ញាណរបស់គាត់កាលពីសវនាការព្រឹកថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ រួចហើយ ហើយសវនាការនេះ អង្គជំនុំជម្រះមិនចាំបាច់សួរបញ្ជាក់អំពីអត្តសញ្ញាណ ថាន់ ធីម ម្ដងទៀតឡើយ។

ហើយលោក ថាន់ ធីម នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ គឺពេលវេលាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថាសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញា មានពេលវេលាកន្លះថ្ងៃក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់ ខ្ញុំមានសំណួរតិចតួចទេលោកដើម

បណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** កាលពីលើកមុនលោកនិយាយថា លោកនៅជំរំជនភៀសខ្លួននៅភ្នំពេញនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ ដំបូងលោកត្រូវបានបញ្ជូនទៅស្រុកគិរីវង់ បន្ទាប់មកនៅឆ្នាំ១៩៧៧ ខ្ញុំសូមដកស្រង់ -- ខ្ញុំសូមដកស្រង់ប្រតិចារឹកនៅម៉ោង ១០:៤៣:២២ វិនាទី៖ នៅឆ្នាំ១៩៧៧ គេជម្លៀសលោកទៅភូមិត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ សំណួរទី១របស់ខ្ញុំលោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំចង់ដឹងថាតើនៅលោកត្រូវបានគេជម្លៀសពីស្រុកគិរីវង់ទៅភូមិត្រពាំងធំខាងជើង ស្រុកត្រាំកក់ នៅឆ្នាំ១៩៧៧ នេះដោយរបៀបណា? ហើយនិងក្នុងលក្ខខណ្ឌបែបណាខ្លះ?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ គេជម្លៀសខ្ញុំពីស្រុកគិរីវង់មក១នៅភូមិត្រពាំងត្រាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវដែរ។ គឺគេដឹកដោយរថយន្ត បាទ ដឹកឡាន។

**ស៖** តើលោកធ្វើដំណើរទៅតែម្នាក់ឯង ឬក៏មានសមាជិកគ្រួសាររបស់លោកទៅជាមួយដែរ? ហើយនៅក្នុងឡានដែលទៅហ្នឹងមានអ្នកណាផ្សេងទៀតទេ?

**ឆ៖** បាទ ក្នុងឡានដែលគេដឹកពួកខ្ញុំមកហ្នឹង គឺមានបងស្រីខ្ញុំ ម្ដាយខ្ញុំ និងគ្រួសាររបស់ខ្ញុំទាំងអស់គ្នា។

[០៩:១១:១៥]

**ស៖** នៅសម័យនោះតើលោកមានកូនទេ? ហើយបើសិន បើមានតើកូនហ្នឹងធ្វើដំណើរទៅជាមួយលោកទេ?

**ឆ៖** បាទ ក្នុងសម័យហ្នឹងខ្ញុំមានកូនស្រីពីរនាក់ ហើយកូនហ្នឹងបានធ្វើដំណើរជាមួយគ្នាដែរបាទ។

**ស៖** សូមអរគុណ។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថា នៅពេលដែលលោកទៅដល់គោលដៅចុងក្រោយនៅស្រុកត្រាំកក់ហ្នឹង តើមានរឿងអ្វីកើតឡើងចំពោះលោកដែរ?

**ឆ៖** បាទ ពេលទៅដល់ស្រុកត្រាំកក់ហ្នឹង គឺទៅដល់ភ្លាមហ្នឹង គឺស្លាប់ក្មួយហ្នឹងអស់ម្នាក់ទៀត ព្រោះកូនបងស្រីខ្ញុំហ្នឹង ព្រោះជិះឡានហ្នឹងវាចង្អៀតពេក អ៊ីចឹងទៅវាក៏បានស្លាប់នៅពេលទៅដល់ហ្នឹងទៅបាទ។ ហើយចំពោះខ្លួនខ្ញុំ១ហ្នឹងគេឲ្យនៅតាមកងរទេះអ៊ីចឹងទៅ ហើយខាងគ្រួសារហ្នឹងគេក៏នៅ

តាមកងនារីអ៊ីចឹងទៅ គេដកស្ទួងអ៊ីចឹងទៅ។ ហើយខ្ញុំហ្នឹងមកខាងកងដឹកជញ្ជូនបាទ។ ហើយមាន មួយថ្ងៃ ហ្នឹងខ្ញុំក៏បានទៅដឹកឈើនៅភ្នំបុស្សតាផង់ហ្នឹង ឈើហូបហ្នឹង ជាមួយនឹងកងរទេះទៅកាលនោះ មានប្រហែលជា៥០រទេះ បាទដឹកឈើហ្នឹង។ ហើយដល់ពេលត្រឡប់មកវិញប្រហែលជាម៉ោងប្រាំពីរ យប់ ប្រាំបីយប់ហើយ ដឹកមកពីឈើបុស្សតាផង់វិញហ្នឹង។ ហើយដល់រួចទៅគេ ខ្ញុំក៏ដាក់ឈើហ៊ុបពី រទេះចេញហើយក៏បររទេះហ្នឹងមកកន្លែងកង។ មកកន្លែងកងអ៊ីចឹងទៅ ដល់រួចទៅខ្ញុំយកចំបើងយកអី ដាក់ឲ្យគោស៊ីអ៊ីចឹងហើយ ឡើងទៅសម្រាន្ត បាទដល់ឡើងទៅសម្រាន្តអ៊ីចឹងហើយ មិនទាន់ទម្លាប់ខ្នង ហ្នឹងដល់រនាបផង ប្រធានកងរទេះហ្នឹងឈ្មោះ តាប៊ុន ហ្នឹងគាត់ហៅខ្ញុំ ថាឲ្យជូនគាត់ទៅប្រជុំ។ ហើយ ខ្ញុំក៏នឹកឃើញថា ស្លាប់ហើយពេលនេះ។ គេហៅយប់ទៀត អត់មានថាហៅពេលថ្ងៃផង គេហៅថា យប់។ ហើយខ្ញុំនឹកខ្ញុំចិត្តខ្ញុំថា ពួកមូលដ្ឋាន គេមិនដែលហៅអ្នក១៧ហ្នឹងទៅ ឲ្យជូនគេទៅប្រជុំទេ គ្រាន់ តែប្រជុំ គេសុទ្ធតែមានការលាក់ការណ៍ គេមិនឲ្យយើងដឹងទៀតផង។ ហើយខ្ញុំដឹងខ្លួនខ្ញុំថា ខ្ញុំពេលហ្នឹង ស្លាប់ហើយ អត់រស់ទេ។ ហើយដល់អ៊ីចឹងទៅ គេហៅខ្ញុំឲ្យជូនគេទៅប្រជុំ។ ហើយគាត់នាំមុខ ខ្ញុំអ៊ីចឹងទៅ ហើយខ្ញុំដើរពីក្រោយគាត់ ឲ្យដើរតាមក្រោយគាត់។ ដល់ដើរតាមក្រោយគាត់អ៊ីចឹងទៅ គាត់ មានឯណា គាត់ដល់រួចទៅ អាមុខកន្លែងឈ្លបហ្នឹង វាមានគេដាំឪឡឹក។ ឪឡឹកហ្នឹងផ្លែ អ៊ូ!មាំណាស់។ អ៊ីចឹងទៅ គេថា “អើមក! បងធីម ចូលរកសុំឪឡឹកទុំឈ្លបមួយហូបសិន”។ ដល់អ៊ីចឹងទៅ ខ្ញុំក៏ចូលទៅៗ គ្នាគេប្រហែលជាបួនប្រាំនាក់ ពួកកងឈ្លបហ្នឹងចេញមកចាប់ចងបីចំណងស្លាបសេកទៅក្រោយ បាទ។ គ្រាន់តែចងជាប់ តាប៊ុន ហ្នឹងវេះមកបាត់មក ហើយពួកកងឈ្លបហ្នឹងគេរុញខ្ញុំចូលទៅក្នុងបន្ទប់គេហ្នឹង ទៅ គេវៃដួលត្រឡប់ត្រឡិនអ៊ីចឹងទៅ។ គេវៃសួរចម្លើយ។ នៅតែវៃមួយ វៃអ៊ីចឹងទៅ ខ្ញុំថាខ្ញុំអត់មាន ធ្វើអីទេ។ ខ្ញុំនៅភ្នំពេញហ្នឹង ខ្ញុំមិនមែនធ្វើទាហានធ្វើអីនឹងគេ មានបណ្ដាស័ក្តិអីទេ ខ្ញុំកម្មករ ខ្ញុំរកបាន ព្រឹកខ្វះល្ងាច។ ខ្ញុំកម្មកររកស៊ីលក់ខសបន្តិចបន្តួច ចិញ្ចឹមប្រពន្ធកូន ចិញ្ចឹមប្រពន្ធហ្នឹង។ គ្មានទេ បានព្រឹក ខ្វះល្ងាច បានល្ងាចខ្វះព្រឹក កាប់ខសលក់។ អ៊ីចឹងទៅ គេក៏នៅតែមិនជឿដែរ គេនៅតែវៃ មួយហាត់ អ៊ីចឹងទៅ មួយចូលវៃទៀត។

[០៩:១៧:៤៤]

ដល់វៃទៅ គេថា “អ្អែង ប្រាប់អញឲ្យត្រង់ អ្អែងធ្វើទាហាននៅភ្នំពេញ ពាក់ស័ក្តិ២មែនមិនមែន? បើឆ្លើយត្រង់ គេលែងឥឡូវហ្នឹង។ មិនបាច់លាក់ទេ កូនអ្អែងប្រាប់គេច្បាស់ហើយៗ”។ ចុះកូនខ្ញុំវានៅកង វានៅក្មេងប្រហែលអាយុ៦-៧ឆ្នាំហ្នឹង វានៅកងកុមារហ្នឹង។ ហើយខ្ញុំក៏មិនដឹងថា កូនហ្នឹងវាឆ្លើយហ្នឹង

គេគំរាមយ៉ាងណាៗឲ្យវាឆ្លើយនុ៎ង ក៏ខ្ញុំមិនដឹងដែរ ប៉ុន្តែវាៗ -- គេប្រាប់ខ្ញុំអ៊ីចឹង។ គេថា “កូនអ្នែងឆ្លើយប្រាប់គេអស់ហើយ អ្នែងនៅភ្នំពេញហ្នឹងពាក់ស័ក្តិ២ ធ្វើទាហាន”។ ខ្ញុំថា “អត់ទេលោកអើយ ខ្ញុំអត់មានធ្វើទាហានធ្វើអីនឹងគេទេ។ ខ្ញុំរកស៊ីលក់ខស លក់អីបន្តិចបន្តួច បានគ្រាន់ចិញ្ចឹមប្រពន្ធ ចិញ្ចឹមកូនហ្នឹងបាទ”។

**ស៖** សូមអរគុណលោក។ លោកបានឆ្លើយថាល្អបបាននិយាយថាកូនរបស់លោកជាអ្នកនិយាយប្រាប់ថា លោកជាទាហាន លន់ នល់។ អ៊ីចឹង ក្រោយពីរបប លន់ នល់ តើលោកមានបាននិយាយជាមួយកូនអំពីរឿងរ៉ាវហ្នឹងទេ? ហើយប្រសិនបើបាននិយាយហ្នឹង តើកូនលោកហ្នឹងបាននិយាយអ្វីខ្លះប្រាប់លោក?

**ឆ៖** ក្រោយពីរបប លន់ នល់ ឯណាទៀត បើវា -- ព្រោះបែក លន់ នល់ ហើយៗ បានចូលប៉ុល ពត បាទ។ ខ្ញុំមិនដឹងក្រោយរបប លន់ នល់ ម៉េចទៀត។

[០៩:១៩:៤៦]

**ស៖** នៅពេលដែលលោកជួបកូនលោកវិញនោះ ពីព្រោះលោកថាកូនរបស់លោកហ្នឹងនៅរស់កូនស្រីទាំងពីរហ្នឹង។ អ៊ីចឹង នៅពេលដែលលោកជួបកូនរបស់លោកវិញហ្នឹង គឺក្រោយឆ្នាំ៧៩នោះលោកធ្លាប់មានបាននិយាយជាមួយកូនស្រីទាំងពីរហ្នឹង អំពីរឿងរ៉ាវហ្នឹងទេ? ហើយពួកគាត់ទាំងពីរហ្នឹងមានបានប្រាប់លោកថា គេទាំងពីរហ្នឹងបានផ្ដល់ឈ្មោះលោកហ្នឹងទៅឲ្យល្អបទេ?

**ឆ៖** បាទ កូនខ្ញុំហ្នឹងវាបានផ្ដល់ថា ខ្ញុំអ្នកប្រើឲ្យវាលួចកាច់អំពៅ បេះឪឡឹក បេះត្រសក់គេស៊ីអ៊ីចឹងទៅ ហើយវាឆ្លើយ គេគំរាមវាថាឲ្យឆ្លើយថា “ឪអ្នែងនៅភ្នំពេញហ្នឹងធ្វើទាហាន ពាក់ស័ក្តិ២អ៊ីចឹងទៅ បានគេឲ្យរួចខ្លួន”។ ហើយខ្ញុំនឹកថា អើ! ហេតុតែគ្នាក្មេង គេឲ្យឆ្លើយថាម៉េច ចេះតែឆ្លើយតាមគេឮថាបានរួចខ្លួន។ គេគំរាម គេវៃវាទៀត គេធ្វើទារុណកម្មវាទៀត។

**ស៖** សូមអរគុណ។ លោកឆ្លើយថាកូនរបស់លោកនៅកងកុមារ។ តើលោកអាចពន្យល់បានទេចាប់ពីពេលណា ដែលគេបំបែកចេញពីកូនៗ? ហើយតើលោកអាចមានលទ្ធភាពទៅសួរសុខទុក្ខកូនទេ? អ៊ីចឹង មុនពេលដែលគេចាប់ខ្លួនលោកនោះ តើការទំនាក់ទំនងគ្នារវាងកូនលោកនិងលោកនោះយ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំមិនដែលទំនាក់ទំនងអីជាមួយកូនហ្នឹងទេ មិនដែលនឹងបានជួបគ្នាផង។ អ៊ីចឹង ពេលដែលគេឲ្យកំណត់ឲ្យយើងជួបគ្នា ក្នុងរយៈពេលដែលថា ១០ – ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០អ៊ីចឹង គឺ១០ថ្ងៃ

ជួបគ្នាម្តងៗហ្នឹង គេមិនដែលឲ្យយើងសម្រាកមួយថ្ងៃហ្នឹងទេ គឺគេឲ្យយើងជួបកូនហ្នឹង -- ជួបប្រពន្ធហ្នឹងតែពេលយប់ទេបាទ ទៅជួបពេលយប់។ ហើយអាកូនហ្នឹងវាមិនដែល -- ខ្ញុំមិនដែលនឹងបានជួបវាផង វាទៅ តែទៅវា ជួនណា វានៅផ្ទះទៅ ជួនណា វាដើរលេង វាដើរ វាពួននៅតែព្រៃអ៊ីចឹងទៅ បាទ។ ជួនណា វាដេកលក់អ៊ីចឹងទៅ។ ហើយខ្ញុំទៅកងៗ អំ! ទៅបាន គេបើកឲ្យទៅជួបប្រពន្ធ ជួបកូនម្តងៗហ្នឹង គឺខ្ញុំរកមើលវាដែរ រកមើលមិនឃើញ។ វានៅដើរលួច បេះបោចឪឡឹក អំពៅអី ត្រសក់អីហ្នឹងគេហូប បានវាមានរឿង បាទ។

[០៩:២២:៥៨]

**ស៖** គេមានបានពន្យល់ប្រាប់លោកទេ ថាហេតុអីបានជាគេបំបែកលោកពីគ្រួសារ? គេមិនឲ្យលោករស់នៅជាមួយនឹងកូន ហើយជាមួយនឹងប្រពន្ធលោកនោះ?

**ឆ៖** បាទ មិនមែនតែខ្ញុំមួយគ្រួសារទេ។ វាជាទូទៅហើយកាលសម័យនោះបាទ។ គឺគេមិនដែលឲ្យយើងនៅរួមរស់ នៅជាមួយប្រពន្ធកូន ជួបជុំគ្នាព្រឹកល្ងាចទេ។ គឺកូននៅកងកុមារអ៊ីចឹងទៅ ហើយម្តាយនៅកងនារីអ៊ីចឹងទៅ ហើយខ្ញុំជាបុរសហ្នឹងក៏នៅតាមកងអ៊ីចឹងដែរ។ នៅតាមកង ដូចថាគេឲ្យធ្វើអីធ្វើហ្នឹង ឲ្យភ្ជួរស្រែ ភ្ជួរស្រែ ឬក៏នៅតាមកងដឹកជញ្ជូនអ៊ីចឹង គេត្រូវការដឹកអី គេឲ្យយើងទៅដឹកហ្នឹងបាទ។

**ស៖** អម្បាញ់មិញនេះលោកឆ្លើយថាលោកបានទៅសួរសុខទុក្ខកូននៅពេលយប់។ តើលោកអាចប្រាប់បានទេ ថាហេតុអីបានជាលោកអាចទៅជួបកូន ទាល់តែពេលយប់អ៊ីចឹង?

**ឆ៖** បាទ អាហ្នឹងដូចថាយើងនៅតាមកងរៀងៗខ្លួនអ៊ីចឹង ដូចថាអង្គការគេហ្នឹងកំណត់ថាឲ្យទៅជួបជុំប្រពន្ធកូនហ្នឹង ក្នុង១០ថ្ងៃម្តង។ ប៉ុន្តែទៅហ្នឹង ទៅបានតែពេលយប់ ថ្ងៃគេឲ្យយើងធ្វើការដដែលគេប្រើយើងធ្វើការ។ ឲ្យទៅជួបពេលយប់។ ហើយទៅពេលយប់ហ្នឹង ជួនណាជួបវាទៅ មិនសូវនឹងដែលបានជួបផង ព្រោះថាវាក្មេងវានៅកងកុមារហ្នឹង វាហូបមិនឆ្អែត អ៊ីចឹងទៅ ដល់រួចទៅវាចេះតែដើរលួចបេះបោចដំណាំដំណោចអីគេ សហករណ៍គេអ៊ីចឹង។

[០៩:២៥:២០]

**ស៖** ដោយសារតែពេលខ្លី អ៊ីចឹងជាសំណួរចុងក្រោយ។ ចុះសមាជិកគ្រួសារផ្សេងទៀតរបស់លោកនោះ លោកនិយាយអំពីជោគវាសនារបស់ប្រពន្ធនិងកូនរបស់លោកទាំងពីរ។ ចុះចំណែកអ្នកផ្សេងទៀតនៅក្នុងគ្រួសាររបស់លោកនោះ តើមានរឿងអ្វីកើតឡើងដែរ ចំពោះពួកគាត់នៅពេលដែល

លោកទៅដល់ត្រាំកក់នោះ?

**ឆ៖** បាទ អារឿងក្នុងសង្គមគ្រួសារខ្ញុំហ្នឹង វាមានបងស្រីម្នាក់គាត់មានកូនមួយៗ។ កូនប្រុសទៀតឈ្មោះ -- អឺដល់រួចទៅវា គេដឹកជញ្ជូនមកដល់ត្រាំកក់ហ្នឹងវាស្លាប់ទៅ រួចជិះឡាន វាចង្អៀតពេក គេញាត់ ហើយជិះមកយប់ទៀត។ បាទ មានតែប៉ុណ្ណឹង។

[០៩:២៦:២៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា។ តំណាងសហព្រះរាជអាជ្ញា សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីដែលមានវត្តមាននៅទីនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកបានឆ្លើយរួចមកហើយកាលពីថ្ងៃទី០២ ខែមេសាកន្លងទៅ ក៏ប៉ុន្តែខ្ញុំមានសំណួរផ្សេងទៀត។ ដោយសារតែយើងមានពេលវេលាច្រើន អ៊ីចឹងខ្ញុំនឹងបង្ហាញឯកសារមួយចំនួនទៅកាន់លោក ដើម្បីសួរលោក។ ជាដំបូង ខ្ញុំចង់ដឹង លោកនៅជំរំជនភៀសខ្លួននៅពេលជម្លៀសចេញពីភ្នំពេញ។ ខ្ញុំចង់ដឹងថាហេតុអ្វីបានជាពេលនុ៎ង លោករត់ទៅនៅជំរំជនភៀសខ្លួនហ្នឹង លោករត់គេចពីអ្វីដែរ?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ពេលនុ៎ង ពួក -- ខ្លាចវៀតណាមៗ ពួកគេហៅ "អាដង់ជិន"ៗហ្នឹង។ អាពួកសញ្ញាក្បាលខ្មោចហ្នឹង។ គេថា ថ្ងៃស្អែកស្លាប់ហ្នឹង ខ្ញុំខ្លាចវាមាំណាស់ យួនហ្នឹងវាឡើងមកលុកលុយនៅតាមព្រំដែនហ្នឹង ហើយខ្ញុំខ្លាច ខ្ញុំចេះតែរត់មកៗ មកនៅដល់ជំរំជនភៀសខ្លួនអូរបែកក្អមហ្នឹង។

**ស៖** មុននឹងរត់ទៅជំរុំជនភៀសខ្លួនហ្នឹង តើលោករស់នៅឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ

មែនទេ? ហើយនៅកន្លែងហ្នឹងគឺនៅតាមបណ្ដោយព្រំដែនវៀតណាម មែនទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ នៅតាមបណ្ដោយព្រំដែនវៀតណាម។ ខ្ញុំរស់នៅទុំងរហូត។

[០៩:២៨:៤៤]

**ស៖** លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយនៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់លោក លោកឆ្លើយថាលោកជាខ្មែរកម្ពុជាក្រោម ប្រពន្ធលោកក៏ខ្មែរកម្ពុជាក្រោមដែរ។ តើលោកអាចរៀបរាប់បានទេថាតើនៅពេលណាដែលគ្រួសាររបស់លោកទៅតាំងទីលំនៅនៅកម្ពុជាក្រោម?

**ឆ៖** ព្រោះអ៊ីចេះ ខ្ញុំឆ្លើយហ្នឹង ខ្ញុំថា ខ្ញុំកើតនៅភូមិទួលពង្រ ឃុំសោមហ្នឹងទេ តែប្រពន្ធរបស់ខ្ញុំហ្នឹង វានៅកម្ពុជាក្រោម តែវាមកឡើងមកនៅកម្ពុជាលើ បានជួបគ្នាហ្នឹងបាទ។

**ស៖** ខ្ញុំនឹងដកស្រង់ឃ្លាមួយនៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនៅចំពោះមុខសហចៅ-ក្រមស៊ើបអង្កេត។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ដើម្បីជួយសម្រួលដល់ការងារនេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារ E319/12.3.8 ជូនទៅលោក ហើយចម្លើយដែលពាក់ព័ន្ធនោះគឺចម្លើយលេខ២០ និងចម្លើយ៥៥។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតប្រគល់កំណត់ហេតុនេះជូនដើមបណ្ដឹងរដ្ឋប្បវេណីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[០៩:៣០:៣១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជាដំបូង គឺនៅសំណួរចម្លើយទី២០ ចំពោះអ្នកបកប្រែ គឺខ្ញុំនឹងដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថាឯកសារនេះមិនមានបកប្រែជាបារាំងទេ។ ដូច្នេះ ខ្ញុំសូមដកស្រង់អ្នកដែលមានស្បែកស ហើយនិយាយខ្មែរមិនច្បាស់ដូចជាពួកខ្មែរក្រោម គឺពួកគេចាត់ទុកថា ជាយួនទាំងអស់ ហើយចុងក្រោយត្រូវគេយកទៅសម្លាប់។ សំណួរ២១៖ តើលោកសំដៅ “គេ” ហ្នឹងទៅលើអ្នកណា? ឆ្លើយ៖ “គេ” សំដៅទៅលើពួកឈ្លប មេភូមិ និងមេសហករណ៍”។ សូមបញ្ចប់ការដកស្រង់។

ខ្ញុំសូមបន្តគឺសំណួរចម្លើយទី៥៥ ខ្ញុំដកស្រង់ជាភាសាអង់គ្លេសដដែល។ ខ្ញុំសូមដកស្រង់ “ពួកគេកំណត់ដោយការប្រើប្រាស់ភាសា។ គឺគេសម្គាល់តាមសំនៀងភាសាខ្មែរ ឧទាហរណ៍ដូចជាស្ត្រីស្លៀក

ខោនិងពាក់អាវដូចស្ត្រីវៀតណាម។ ខ្ញុំក៏ដឹងថាពួកខ្មែរក្រហមយកជនជាតិយួនទៅប្តូរយកខ្មែរក្រោមដែរ”។ សូមបញ្ចប់ការដកស្រង់។

បាទ ខ្ញុំសង្ខេបចម្លើយរបស់លោកទៅ គឺថាលោកបានលើកឡើងនូវមធ្យោបាយបីដែលខ្មែរក្រហមកំណត់អត្តសញ្ញាណខ្មែរក្រោម។ ទី១ គឺនិយាយខ្មែរមិនសូវច្បាស់ ឬនិយាយទៅមានរដឺន។ ទី២ គឺសម្បុរស។ ទី៣ គឺពាក់ខោអាវដូចជនជាតិវៀតណាម។ ខ្ញុំចង់សួរលោកថា តើកម្មាភិបាលខ្មែរក្រហមស្រុកគីរីវង់ ឬកម្មាភិបាលខ្មែរក្រហមស្រុកត្រាំកក់នោះ មានស្វែងរកខ្មែរក្រោមនៅក្នុងចំណោមអ្នក១៧មេសា ដែលនៅកន្លែងនោះទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៣២:៤៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកលោកស្រីចៅក្រម។ ខ្ញុំជំទាស់ទៅលើសំណួរនេះ ព្រោះសំណួរនោះទាក់ទងទៅនឹងប្រធានបទដែលស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ គឺទាក់ទងទៅនឹងប្រព្រឹត្តចំពោះខ្មែរក្រោមដែលមិនមែនជាផ្នែកនៃសវនាការនេះ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅលើការសួរសំណួរបែបនេះ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ការជំទាស់នេះ ត្រូវបានលើកឡើងជាច្រើនដងរួចមកហើយ ហើយយើងឃើញថា ដីកាដំណោះស្រាយពាក់ព័ន្ធនឹងចំណុចនេះ គឺមាននិយាយ -- មានបង្ហាញអំពីការធ្វើបាបខ្មែរក្រោម។ ដូច្នេះខ្ញុំគិតថា គួរតែអាចអនុញ្ញាតឲ្យសួរសំណួរបែបនេះបាននៅពេលនេះលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៦:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចឆ្លើយតប

ទៅនឹងសេចក្ដីជំទាស់របស់មេធាវីការពារក្ដីចំពោះសំណួរចុងក្រោយរបស់សហព្រះរាជអាជ្ញា។

សូមអញ្ជើញ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះបានកត់សម្គាល់ថា សំណើដែលបានស្នើសុំឲ្យមានការបញ្ជាក់បំភ្លឺទៅលើដីកាចោទប្រកាន់បញ្ជូនឲ្យស៊ើបសួរទាក់ទងទៅនឹងខ្មែរក្រោមនេះ គឺថាយើងនឹងចេញសេចក្ដីសម្រេចនៅក្នុងពេលឆាប់ៗខាងមុខនេះ។ ដូច្នេះ រហូតដល់ពេលមានសេចក្ដីសម្រេចនោះ គឺយើងអនុញ្ញាតឲ្យមានការសួរសំណួរនៅពេលនេះគឺទាក់ទងទៅនឹងប្រជាជន១៧មេសា។ ដូច្នេះ អាចសាកសួរបាន។

[០៩:៣៦:៥៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឥឡូវនេះ ខ្ញុំសួរសំណួរឡើងវិញ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើកម្មាភិបាលខ្មែរក្រហមស្រុកគិរីវង់ ឬកម្មាភិបាល ខ្មែរក្រហមស្រុកត្រាំកក់ មានស្វែងរកខ្មែរក្រោមក្នុងចំណោមអ្នក ១៧ មេសា ដែលនៅកន្លែងនោះទេ?

**លោក ផាន់ ធីម៖**

**ឆ៖** បាទ ទាំងមេដឹកនាំនៅខាងស្រុកគិរីវង់ ទាំងមេដឹកនាំនៅខាងស្រុកត្រាំកក់ គឺមិនមានការស្វែងរកខ្មែរក្រោមអីទេ បាទ ពីព្រោះថា វាទាល់តែវាមាន គឺថាមានគេរាយការណ៍ថាអ៊ីចេះ ថាអ៊ីចុះអីអាហ្នឹងបានគេស្វែងរក។ ប៉ុនថាអានេះដូចអត់មានទេបាទ អត់មានស្វែងរកទេ។

**ស៖** នៅចម្លើយទី៥៤ នៃកំណត់ហេតុដែលនេះ លោកនិយាយថាគេមានការពិបាកនឹងកំណត់ថាអ្នកណាជាខ្មែរក្រោមនៅក្នុងចំណោមអ្នក១៧មេសា។ លោកក៏បានឆ្លើយនៅក្នុងចម្លើយទី៥៥ ដែលលោកឆ្លើយថាមានការយកខ្មែរ -- ខ្មែរក្រហមយកយួន ជនជាតិយួន ទៅដូរយកខ្មែរក្រោម។ តើគេមានចុះកិច្ចព្រមព្រៀងអ្វីខ្លះដែររវាងការដោះដូរជនជាតិវៀតណាមជាមួយនឹងខ្មែរក្រោមនេះ?

**ឆ៖** គេ -- អាហ្នឹងខ្ញុំក៏មិនបានដឹងច្បាស់ដែរ ប៉ុន្តែថាអារឿងគេដោះដូរហ្នឹងមានមែន បាទ។ ដូរយក វៀតណាមយកទៅដូរហ្នឹង។

[០៩:៣៩:២៥]

**ស៖** តើលោកមានបានឃើញជាច្រើនដងទេ ថាជនជាតិវៀតណាមត្រូវបានបញ្ជូនទៅដល់ព្រំដែន ឬក៏ឃើញខ្មែរក្រោមហ្នឹងមកដល់កន្លែងដែលលោករស់នៅ ឬក៏លោកគ្រាន់តែធ្លាប់ឮទេ ប៉ុន្តែលោកមិនបានឃើញផ្ទាល់ភ្នែកអំពីការដោះដូរហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់តែឮទេ អត់បានឃើញផ្ទាល់ទេបាទ អត់បានឃើញផ្ទាល់ទេ។

**ស៖** តើលោកមានឮថាការដោះដូរហ្នឹងមានបាន ត្រូវបានបញ្ចប់នៅពេលណាមួយជាក់លាក់ទេនៅក្នុងរបបនោះ?

**ឆ៖** ទេអារឿងបញ្ចប់នៅពេលណានោះ ខ្ញុំអត់បានឮបានដឹងទេបាទ អត់បានដឹងទេ។

**ស៖** តើលោកធ្លាប់ដឹងទេថាជនជាតិវៀតណាម ឬខ្មែរក្រោមដែលគេចាត់ទុកថាជាវៀតណាមនោះ ត្រូវបានសម្លាប់ចោលនៅស្រុកត្រាំកក់ ឬក៏កន្លែងណាផ្សេងទៀតនៅក្នុងភូមិភាគនិរតី?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប សូមអញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយហេតុថាតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯងផ្ទាល់ មិនមែនជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេទាក់ទងទៅនឹងការសន្និដ្ឋានថា "ខ្មែរក្រោមជាជនជាតិវៀតណាមនោះ" បាទ។ ហើយមែនទែនទៅវាផ្ទុយទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទៀត ដោយលោកបានបញ្ជាក់អម្បាញ់មិញនេះថា មិនមានការស្វែងរកកម្ពុជាក្រោមជាលក្ខណៈទូទៅនោះទេបាទ លុះណាតែមានបញ្ហាអីផ្សេងៗទាក់ទងទៅនឹងបុគ្គលណាមួយទើបមានការស្វែងរក។ បាទសូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណ។ ខ្ញុំដឹងហើយថាដើមបណ្តឹងរដ្ឋប្បវេណីគាត់មិនបាននិយាយទេ ក៏ប៉ុន្តែខ្ញុំដកស្រង់ពីចម្លើយទី២០ នៃឯកសារ E319/12.3.8 គាត់និយាយថា "អ្នកដែលមានសំបុរស ហើយនិយាយខ្មែរមិនសូវច្បាស់នោះ ត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាម"។ អ៊ីចឹងលោកប្រធាន តើលោកប្រធានអនុញ្ញាតឱ្យខ្ញុំសួរសំណួរហ្នឹងទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី ហើយអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលសួរដោយសហព្រះរាជអាជ្ញារងអន្តរជាតិ។ បើមិនចាំទេ សហព្រះរាជអាជ្ញារងអន្តរជាតិអាចរំឭកបញ្ជាក់សំណួរចុងក្រោយរបស់លោកចំពោះដើមបណ្តឹងរដ្ឋប្បវេណីសាជាថ្មី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមអរគុណលោកប្រធាន ខ្ញុំសូមសួរឡើងវិញ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅស្រុកគិរីវង់ ឬនៅស្រុកត្រាំកក់ លោកធ្លាប់ដឹងទេថា ជនជាតិវៀតណាម ឬខ្មែរក្រោមដែលគេចាត់ទុកថាជាវៀតណាមនោះ ត្រូវបានសម្លាប់ចោលនៅក្នុងភូមិភាគនោះដោយពួកខ្មែរក្រហម?

[០៩:៤៤:០៥]

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ពួកខ្មែរក្រហមហ្នឹង អង្គាល់ដែលខ្ញុំបាទរស់នៅស្រុកគិរីវង់ អ៊ីចឹងវាមានមែន ដូចថាវា -- ខ្មែរក្រោមហ្នឹងអាខ្លះនិយាយរដីនៗអត់ច្បាស់ទេ ហើយវៀតណាមក៏វាៗនិយាយខ្មែរវាអត់ច្បាស់ដែរ អ៊ីចឹងគេក៏ថាជា -- គេចាត់ទុកថាពួកហ្នឹងសុទ្ធតែជាពួកខ្មែរក្រោមទាំងអស់ហើយ ឬមួយក៏វៀតណាម អ៊ីចឹងទៅ គេថាសម្បុរសៗ ហើយនិយាយខ្មែរមិនច្បាស់ទៀត អាហ្នឹងគេថាៗយួនហើយ ហើយគេយកទៅបាត់ទៅ មិនដឹងគេយកទៅណាបាទ គេយក -- មិនដឹងគេយកទៅសម្លាប់ ឬមួយក៏គេយកទៅបាត់រហូតអ៊ីចឹងទៅ វាអត់ឃើញនៅកន្លែងហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំនិយាយអំពីអ្នកដែលកាន់តួនាទីនៅក្នុងទាហាន លន់ នល់ ឬមន្ត្រីរដ្ឋការ ឬក៏មន្ត្រីរដ្ឋការជាន់ខ្ពស់នៃរបបលន់ នល់។ ខ្ញុំសូមអាននូវចម្លើយរបស់លោក ដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយនិងសំណួរបន្ថែមទៅកាន់លោក។ ទាក់ទងនឹងឯកសារដែលខ្ញុំបានប្រគល់ជូនលោក គឺចាប់ពីចម្លើយទី៤៤ទៅ ខ្ញុំនឹងដកស្រង់ជាភាសាអង់គ្លេស នៅសំណួរចម្លើយមួយចំនួន។ សំណួរ៤៤ សូមដកស្រង់៖ “ពេលដែលលោកនៅភូមិស្វាយរល្លិ តើលោកមានដឹងថាគេមានសម្លាប់មនុស្សច្រើនទេ?” ចម្លើយ៤៤៖ បាទគេមាន -- ខ្មែរក្រោមសុទ្ធតែធ្វើទាហាន

ហើយមានបុណ្យស័ក្តិ ស្វាយរល្ហិ ខ្មែរក្រហមបានឃោសនាថា អ្នកមានបណ្តាស័ក្តិអ្វី កាលនៅរបបលន់ នល់ គេនឹងឲ្យទៅកាន់តំណែងក្នុងកងទ័ពវិញ។ ហើយបន្ទាប់មកត្រូវទៅវាយជាមួយយួន។ តែការពិតពួកគេយកទៅសម្លាប់ចោលទាំងអស់"។ ចម្លើយលេខ៤៥៖ "ខ្ញុំចាំពីប្រជាជនខ្មែរក្រោមបានប្រាប់ពួកគេថា គាត់គឺជាស័ក្តិ៥ -- ស័ក្តិបួនកន្លះ នេះជាល្បិចកលរបស់ខ្មែរក្រហមដើម្បីចង់ឲ្យដឹងថាយើងធ្លាប់ធ្វើអ្វីនៅសម័យលន់ នល់។ តាមការពិតអ្នកទាំងនោះ គឺគេយកទៅសម្លាប់ទាំងអស់"។ ចម្លើយ៤៦៖ "ពួកគេគ្រាន់តែចង់បញ្ឆោតអ្នកដែលធ្លាប់ធ្វើការក្នុងរបបលន់ នល់ ឲ្យបង្ហាញខ្លួន ដើម្បីយកទៅសម្លាប់ចោល ឧទាហរណ៍ដូចជា ទាហាន និងគ្រូបង្រៀនជាដើម"។ ចម្លើយលេខ៤៨ របស់លោកថា៖ "អ្នកប្រកាសឃោសនាគឺមេភូមិ"។ ហើយចុងក្រោយគឺចម្លើយលេខ៥៣៖ "ក្រោយពីការឃោសនា គេ ខ្មែរក្រហមធ្លាប់ធ្វើក្នុងរបបលន់ នល់ ក៏យកទៅសម្លាប់"។ បញ្ចប់ការដកស្រង់។

សំណួរទី១ តើនៅក្នុងភូមិស្វាយរល្ហិ អតីតយោធា ឬមន្ត្រីរដ្ឋការលន់នល់ច្រើនទេ បានជឿថាខ្មែរក្រហម -- បានជឿខ្មែរក្រហម ហើយបានប្រាប់អំពីមុខងារ -- មុខរបរពីមុនរបស់ខ្លួននោះ?

[០៩:៤៨:១៧]

**ឆ៖** បាទពេលដែលគេជម្លៀសយើងចេញទៅដល់ -- ពីភ្នំពេញទៅដល់ភូមិស្វាយរល្ហិហ្នឹង គឺថាបានបួនប្រាំថ្ងៃ គេក៏ប្រកាសប្រាប់ប្រជាជន១៧ហ្នឹងទាំងអស់ថា អ្នកណាមានបណ្តាស័ក្តិអ្វី គឺគេឲ្យធ្វើការងារហ្នឹងវិញ ឬក៏ជាគ្រូបង្រៀន គេឲ្យទៅបង្រៀនវិញ។ ហើយអ៊ីចឹង អ្នកខ្លះអត់មានបណ្តាស័ក្តិអីផង ដល់រួចទៅឮគេថា "អ្នកណាដែលបានពាក់ស័ក្តិប៉ុន្មាន គេឲ្យពាក់ស័ក្តិហ្នឹងវិញ" ឮថាគេឲ្យអ៊ីចឹងអាខ្លះគ្មានពាក់ស័ក្តិផងបានឆ្លើយប្រាប់គេថាមាន ពាក់អាក់សូដង់ ឬអាក់សូដង់សែហ្វអ៊ីចឹងទៅ ឬក៏ស័ក្តិ១ ស័ក្តិ២អ៊ីចឹងទៅ ហើយសុទ្ធតែពួកខ្មែរក្រោមបាទ ទាហាន ធ្វើទាហានពួកខ្មែរក្រោមហ្នឹង។ ហើយគេក៏យកទៅបាត់ទៅ មិនដឹងយកទៅឯណា បើយកដល់ប្រកាសហើយ ដល់រួចទៅបាត់ខ្លួនអស់រលីង។ ខ្ញុំក៏មិនបាន -- អ្នកណាឲ្យយើងដឹងបាទ។

[០៩:៤៩:៤១]

**ស៖** ចុះបន្ទាប់មកទៀត តើលោកធ្លាប់ឮក្រោយរបបខ្មែរក្រហមទេថា អ្នកទាំងអស់ហ្នឹងមាននៅរស់ទេ? ខ្ញុំសំដៅលើ ឧទាហរណ៍ដូចជា ពឹង ដែលលោកបានរៀបរាប់នេះ?

**ឆ៖** បាទ មានដូចថា -- កាលនុំងវាអ៊ីចេះ កាលដែលគេប្រកាសប្រាប់ថាអ្នកណាមានបណ្តាស័ក្តិអ្វី ឬក៏មានមុខងារជាអ្វី គ្រូបង្រៀនអីហ្នឹង មានលោក ពឹង ហ្នឹងគាត់ចេញមុខមុនគេ។ គាត់ថាគាត់

ពាក់ស័ក្តិបួនកន្លះ ហើយឥឡូវសុំអង្គការយកតែត្រឹមស័ក្តិ៤ទេ ព្រោះគាត់ចង់ទៅវាយយួនអ៊ីចឹងណ៎ា។ វាអ៊ីចឹងទេ លោក ពីង ហ្នឹង។ ហើយដល់រួចទៅ ស្រាប់តែបាត់គាត់រហូតអ៊ីចឹងទៅ។

**សៈ** នៅក្នុងរបបខ្មែរក្រហមលោកធ្លាប់ឮទេថា មានការប្រកាសបែបហ្នឹងដូចគ្នាដែរនៅក្នុងភូមិផ្សេងៗទៀត នៅស្រុកគិរីវង់ ឬស្រុកត្រាំកក់ ដើម្បីអាចស្វែង -- កំណត់អត្តសញ្ញាណមន្ត្រីរដ្ឋការ ឬទាហានលន់នល់?

**ឆៈ** បើតាមខ្ញុំដឹង គឺនៅស្រុកគិរីវង់ប្រកាសអ៊ីចឹងមែន។ ពេលដែលខ្ញុំចុះទៅដល់ភ្លាមៗហ្នឹង បួនប្រាំថ្ងៃអី ១០ថ្ងៃអ៊ីចឹង គេប្រកាសមែន តែបើចំពោះនៅតាមត្រាំកក់ ដូចថាខ្ញុំវាយួស(?) បានប៉ុន្មានឆ្នាំហើយ បានគេជម្លៀសខ្ញុំចេញពីនុ៎ងមកទៀត បាទខ្ញុំម៉េចនឹងដឹងនៅត្រាំកក់ អត់មាន។ ប៉ុនបើនៅខាងគិរីវង់ មាន បាទ មានប្រកាសអ៊ីចឹងមែន។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលនិយាយអំពីការជម្លៀសលោកពីស្រុកគិរីវង់ ទៅស្រុកត្រាំកក់។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកដកស្រង់នូវចម្លើយរបស់លោកកាលពីថ្ងៃទី០២ មេសា ដែលគាត់និយាយថា គឺនៅឆ្នាំ៧៧ ដែលគេជម្លៀសលោកទៅភូមិត្រពាំងធំខាងជើង ស្រុកត្រាំកក់។ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេថានៅភូមិជីម្រាក់ អ្នកណាជាអ្នកប្រកាសថា លោកត្រូវតែចាកចេញពីស្រុកគិរីវង់ ទៅស្រុកត្រាំកក់នោះ?

[០៩:៥២:៥៥]

**ឆៈ** នៅចុងឆ្នាំ១៩៧៧ហ្នឹង គឺខ្ញុំនៅធ្វើស្រែនៅឯទួលពោន នៅឯភូមិស្វាយវល្លិនោះ។ ហើយដល់រួចទៅ ស្រាប់តែមេកង មេក្រុមអីហ្នឹង គេប្រាប់ថាឲ្យឈប់ការងារហ្នឹង មកឡើងមកមូលគ្នានៅវត្តកំពែងទាំងអស់បាទ។ ហើយអ្នកដែលប្រកាសនុ៎ង ខ្ញុំថាអត់មានអ្នកណាទេ គឺមេឃុំហ្នួង ឈ្មោះគាត់តាប៉ស់ ។ ហើយ តាប៉ស់ ហ្នឹងគាត់ទៅពីត្រាំកក់ហ្នឹងទៅដែរណ៎ា តាប៉ស់ នុ៎ង។ កាលនុ៎ង គេប្រើតែពាក្យអង្គការទេ អង្គការគេៗ ប៉ុន្តែមេឃុំហ្នឹងអ្នកនេះ – គណៈឃុំហ្នឹង។

**សៈ** នៅវត្តកំពែងនៅពេលដែលគេប្រកាសថា ត្រូវតែចាកចេញពីស្រុកគិរីវង់នោះ តើមានមនុស្សច្រើនទេ? លោកអាចគិតមើលទៅ ថាៗប្រហែលជាមានប៉ុន្មាននាក់ដែរ ដែលនៅជួបជុំនៅក្នុងវត្តនោះ?

**ឆៈ** ជួបជុំនៅក្នុងវត្តហ្នឹង គិតទៅគ្នាច្រើនណាស់ អ្នក១៧មេសាហ្នឹងទាំងអស់ដែលរស់នៅក្នុងភូមិស្វាយវល្លិ នៅភូមិជីម្រាក់ គឺត្រូវតែមូលមកនៅក្នុងវត្តកំពែងហ្នឹងទាំងអស់បាទ។ មនុស្សច្រើន

ណាស់ ខ្ញុំមិនដឹងជាប៉ុន្មានទេ ស្មាន មិនអាចស្មានដឹងបាន ប្រហែលៗជារាប់រយគ្រួសារឯណោះ។

[០៩:៥៥:០០]

**ស៖** សូមអរគុណ។ តើ តាប៉ស់ ដែលជាអ្នកប្រកាសនោះ មានសួរយោបល់លោក ឬក៏សួរយោបល់អ្នក១៧មេសា ដែលជួបជុំគ្នានៅទីនោះទេ មុននឹងបញ្ជូនលោកទៅនោះ? ឬមួយកថា តើលោកមានជម្រើសទេ ថាទៅ ឬមិនទៅស្រេចចិត្ត?

**ឆ៖** បាទ តាប៉ស់ ហ្នឹង គាត់គ្រាន់តែថា អ៊ីចេះថា "ឥឡូវ អង្គការលើហ្នឹងត្រូវជម្លៀសបងប្អូនចេញពីកន្លែងនេះទៀតហើយ ព្រោះឆ្នាំហ្នឹង ពួកវៀតណាមហ្នឹងវាបុកឡើងមក ឮសូរផ្ទុះអាវុធក្នុងខ្លាំងអ៊ីចឹងទៅ ហើយដល់រួចទៅ គេថា ខ្លាចពួកហ្នឹង ទៅចូលជាមួយយួនហ្នឹង បានគេជម្លៀសចេញពីហ្នឹងមកនៅត្រាំកក់ឲ្យឆ្ងាយបន្តិច បាទ។ តាប៉ស់ គាត់ប្រើតែពាក្យ "អង្គការ"ទេ។ ថាអង្គការលើអ៊ីចឹង "ត្រូវជម្លៀសបងប្អូនទៅនៅត្រាំកក់ម្តង"។

[០៩:៥៦:៤៩]

**ស៖** លោកបាននិយាយថា ការប្រជុំហ្នឹង មានតែអ្នក១៧មេសាទេ។ អ៊ីចឹង តើអ្នកមូលដ្ឋាននៅភូមិនោះ ឬក៏ភូមិក្បែរៗហ្នឹងនោះ គេមានបញ្ជូនទៅស្រុកត្រាំកក់ដែរទេ?

**ឆ៖** បាទ ពួកអ្នកមូលដ្ឋាន គេអត់ទៅណាទេ អត់មានទៅណាទេ បញ្ជូនតែយើងពួកថ្មី ពួក១៧ហ្នឹង គេឲ្យមកត្រាំកក់ទាំងអស់។ សម័យនោះពួកមូលដ្ឋានហ្នឹង គេអត់ទៅណាទេ។

**ស៖** តើលោកធ្លាប់ តាប៉ស់ ឬខ្មែរក្រហមផ្សេងទៀតនិយាយថា គេថាខ្លាចលោករត់ទៅវៀតណាមទេ?

**ឆ៖** បាទ អាហ្នឹង វាខ្មែរក្រហមពួកគេអ្នកធ្វើការហ្នឹង គេចេះតែខ្លាចហើយ។ គេខ្លាចដូចថា ទី១ យើងនៅនោះ វាជិតទៅវៀតណាម ហើយបានគេចេះតែខ្លាចហ្នឹង គេជម្លៀសយើងឡើងមកនៅឲ្យឆ្ងាយបន្តិច បាទ។

**ស៖** ក្រៅពីភូមិរបស់លោកដែលស្ថិតនៅក្នុងឃុំកំពែង តើមានអ្នក១៧មេសាផ្សេងទៀតនៅស្រុកគិរីវង់ហ្នឹងបានធ្វើដំណើរទៅស្រុកត្រាំកក់ទេ?

**ឆ៖** បាទឲ្យតែអ្នក១៧មេសាហ្នឹង គេដឹកឡើងមកទាំងអស់ បាទ។ មិនថាអ្នកណារស់នៅទឹកដីឃុំកំពែងហ្នឹងហើយ មិនជម្លៀសចេញមកនៅនេះទេ គឺឲ្យតែៗតែអ្នក១៧មេសា គេជម្លៀសមកទាំងអស់។

[០៩:៥៩:៣១]

**ស៖** នៅក្នុងចម្លើយទី៦៤នៃកំណត់ហេតុរបស់លោក គឺE319/12.3.8 លោកបាននិយាយអំពីឡានប្រាំដែលដឹកលោក ពួកលោក។ អ៊ីចឹង តើលោកអាចជម្រាបបានទេ នៅក្នុងឡាននីមួយៗហ្នឹងមានមនុស្សប្រហែលប៉ុន្មាននាក់ដែរ ដែលដឹកពួកលោកមកស្រុកត្រាំកក់ហ្នឹង?

**ឆ៖** បាទ មួយឡានៗហ្នឹង មនុស្សប្រហែលជា តិចណាស់ក៏៣០ ទៅ៤០នាក់ដែរ មួយឡានៗហ្នឹង ឡានគេធំដែរ។

**ស៖** តើមានទាហានខ្មែរក្រហមមកតាមលោក ឬក៏ឃាមពួកលោកទេនៅពេលដែលគេបញ្ជូនមកហ្នឹង?

**ឆ៖** បាទមិនមានទេ អត់មានតាម មកតែតែកុងឡានហ្នឹង ពួកខ្មែរក្រហមហ្នឹងគេអត់មានមកទេ។

**ស៖** អ៊ីចឹងមានអ្នកដែលព្យាយាមលោតពីលើឡានរត់គេចទេ?

**ឆ៖** បាទអត់មានទេ អត់មាននរណាមួយប៉ានរត់គេចទៅឯណាទេ ព្រោះថាវាមិនប៉ានអ៊ីចឹង។

**ស៖** លោកនិយាយអំពីថាមានគ្នា៧៧នេះ -- លោកនិយាយអំពីឆ្នាំ៧៧។ តើលោកមាននៅចាំទេថា ពេលនុ៎ងជារដូវណាដែរ ជារដូវប្រាំង ឬក៏ជារដូវវស្សា?

**ឆ៖** ពេលនុ៎ងជារដូវប្រាំង។

**ស៖** បើតាមលោកដឹងការជម្លៀសអ្នកនៅគិរីវង់មកត្រាំកក់ហ្នឹង គឺថាធ្វើឡើងតែមួយពេលទេ ឬក៏ច្រើនពេល?

**ឆ៖** បាទ ធ្វើឡើងតែមួយពេលហ្នឹងៗ។

**ស៖** ពាក់ព័ន្ធនឹងឆ្នាំ១៩៧៧ដដែលនេះ ដើម្បីព្យាយាមឲ្យដឹងថាតើនៅពេលណាឲ្យពិតប្រាកដនោះ គឺខ្ញុំចង់សួរថា តើនៅពាក់កណ្ដាលដំបូង មានន័យថាពីខែ១ ដល់ខែ៦ ពាក់កណ្ដាលដំបូង ឬក៏ពីខែ៦ ដល់ខែ១២ តើវានៅចន្លោះខែណាដែរ?

[១០:០៣:០៥]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សំណួរនេះមិនគួរសួរដដែលទៀតទេ ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយរួចហើយថា ចុងខែ (សូមទោស) ចុងឆ្នាំ១៩៧៧។ ដូច្នេះបើអាចសួរ អាចបញ្ជាក់ថាចុងឆ្នាំក្នុងខែណាឲ្យច្បាស់ អាហ្នឹងគួរសួរបញ្ជាក់ចំណុចនេះវិញបាទ។ សូមអគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

គាត់ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់និយាយថារដូវប្រាំង។ អ៊ីចឹងរដូវប្រាំងវាវែងណាស់ តាំងពីខែ៥ដល់ខែ១១ឯណោះ។ អ៊ីចឹងបានខ្ញុំសួរឲ្យច្បាស់។ អ៊ីចឹងខ្ញុំសួរឡើងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** តើលោកចាំថានៅខែណាឲ្យពិតប្រាកដ ឬក៏រដូវណាពិតប្រាកដនៅឆ្នាំ៧៧ហ្នឹងទេ ដែលគេបញ្ជូនលោកពីគិរីវង់ មកត្រាំកក់នោះ ឬក៏លោកមិនចាំទេ?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ប្រហែលជានៅក្នុងខែ៩ ខែ១០ហ្នឹង ឆ្នាំ៧៧ហ្នឹង។

[១០:០៤:៣៥]

**ស៖** ឥឡូវនេះខ្ញុំនឹងអានសម្រង់មួយចេញពីសៀវភៅរបស់ ប៉ែន យៀវនិន គឺឯកសារE3/1593។ សៀវភៅនេះមានចំណងជើងថា "អំពើប្រល័យពូជសាសន៍នៅកម្ពុជា"។ ទំព័រដែលខ្ញុំចាប់អារម្មណ៍នោះគឺភាសាអង់គ្លេស 00678580, ជាភាសាបារាំង 00638944, ជាភាសាខ្មែរ 00637647 រហូតទៅដល់48។ ខ្ញុំសូមដកស្រង់៖ "ក្នុងអំឡុងពេលនោះអ្នកភ្នំពេញដែលត្រូវជម្លៀសទៅគិរីវង់ត្រូវបានជម្លៀសត្រឡប់មកវិញ។ នៅដើមឆ្នាំ១៩៧៧ សារុន នឹកឃើញថាប្រជាជនថ្មីនៅស្រុកគិរីវង់ ត្រូវបានបញ្ជូនមកកសាងខ្លួនរាប់ពាន់នាក់នៅស្រុកត្រាំកក់។ ខ្មែរក្រហមសង្ស័យថាពួកយើងអាចរត់គេចទៅវៀតណាម។ នៅពេលដែលសារុន និងប្រជាជនថ្មីមកពីគិរីវង់ គេបង្កើតថ្នាក់មួយទៀត គឺថ្នាក់ក្រោមប្រជាជនថ្មីទៅទៀត។ អ្នកមកដល់ថ្មីនៅត្រាំកក់ ក្លាយទៅជាចោរព្រៃ។ ប្រហែលជាគេចោទពួកហ្នឹងថា មានចេតនាចង់រត់គេចទៅវៀតណាម"។ សារុន នឹកឃើញថា សូមដកស្រង់៖ "យើងរស់នៅក្នុងភូមិហ្នឹង គឺថាអ្នកប្រជាជនថ្មី អ្នករស់នៅកន្លែងនុំងគឺថាគាត់ហូបចុកហ្នឹងគឺគ្រាន់បើជាងយើង"។ សម្រង់ដកចេញពីសៀវភៅនេះ និយាយអំពីប្រជាជនថ្មីរាប់ពាន់នាក់នៅស្រុកគិរីវង់ ដែលត្រូវបានគេជម្លៀសមកស្រុកត្រាំកក់នៅឆ្នាំ១៩៧៧។ អ៊ីចឹងតើលោកឯកភាពជាមួយនឹងការប៉ាន់ប្រមាណហ្នឹងទេ ថាមានប្រជាជន

ថ្មីរាប់ពាន់នាក់ដែលត្រូវជម្លៀសមក?

[១០:០៧:០៥]

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ប្រហែលជាច្រើនដែរ។ ខ្ញុំមិនដឹងថាប៉ុន្មានពាន់ ឬក៏ប៉ុន្មានរយអ៊ីចឹងណា វាច្រើន ហើយខ្ញុំ ដឹងតែថាខ្ញុំឡើងឡានមកមុនគេអ៊ីចឹងមក ហើយគេចេះតែដឹកបន្តបន្ទាប់ បញ្ជូនទាល់តែអស់ មកនៅត្រាំកក់ហ្នឹង។

**ស៖** នៅក្នុងសម្រង់ចេញពីសៀវភៅនេះ គេនិយាយថា អ្នក១៧មេសា ដែលមកពីគិរីវង់ ត្រូវបានគេប្រព្រឹត្តមិនសូវល្អទេ គឺអាក្រក់ជាងអ្នក១៧មេសា ដែលនៅស្រុកត្រាំកក់ហ្នឹងស្រាប់តែម្តង។ តើលោកមានកត់សម្គាល់ឃើញបែបហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំវាកត់សម្គាល់ឃើញដូចតែគ្នាដែរ ព្រោះអង្កាល់សម័យនោះគេបែងចែកវាវណ្ណៈហ្នឹងវាបីឯណោះ។ វាមានត្រៀម អ៎ា! វាមានផ្ញើ វាមានត្រៀម វាមានពេញសិទ្ធិ។ អ៊ីចឹងពួកខ្ញុំហ្នឹងជាបញ្ញើ បាទ គេផ្ញើ។

**ស៖** ក្នុងចំណោមអ្នកដែលផ្ញើហ្នឹង តើលោកមានសង្កេតឃើញទេថា មានការប្រព្រឹត្តខុសគ្នាចំពោះអ្នកដែលនៅត្រាំកក់ស្រុកហ្នឹង ដូចជារបបអាហារ ការរស់នៅ ហើយនិងការធ្វើការនោះ?

**ឆ៖** បាទ រឿងការងារនោះវាមិនខុសប្លែកគ្នាទេ។ វាធ្វើការងារដូចតែគ្នាហ្នឹង ខ្ញុំថាវាមិនខុសប្លែកទេ រឿងការងារ ហើយនិងរឿងឲ្យហូប របបហូបហ្នឹង ហូបតែបបរ បីកំប៉ុងអីគ្នាប្អូនដប់នាក់។ ហូបដូចតែគ្នាហ្នឹង ហូបបបរ។

[១០:០៩:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មរួមទាំងបុគ្គលិកនៃអង្គការ ធី.ភី.អូ ផងដែរ ដែលអង្គុយអមគាត់ហ្នឹង មកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ នៅវេលាម៉ោងដប់និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជ-អាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ មុនពេលសម្រាកលោកនិយាយថាលោកបានទទួលបបររាវដើម្បីបរិភោគ នៅពេលដែលលោកទៅដល់ភូមិត្រពាំងត្រាវនៅក្នុងស្រុកត្រាំកក់។ តើលោកមានអាហារបរិភោគគ្រប់គ្រាន់ដែរឬទេ?

**លោក ថាន់ ធីម៖**

**ឆ៖** ទេអារឿងអាហារហ្នឹងមិនដែលបានគ្រប់គ្រាន់ទេ គឺហូបតែបបររាវហ្នឹង បបររាវហូតអត់ដែលបានហូបគ្រប់គ្រាន់ទេ។

**ស៖** តើដោយសារខ្វះអាហារហ្នឹង គឺអ្នកដែលនៅក្នុង -- ប្រជាជន១៧មេសាទាំងប៉ុន្មានហ្នឹង ធ្លាក់ខ្លួនឈឺដែរឬទេ?

**ឆ៖** បាទ គឺអាខ្លះក៏ធ្លាក់ឈឺអីចឹងទៅ អាក្បាលជង្គង់ត្រមែងត្រមោង ក្បាលជង្គង់ធំជាងភ្លៅទៀត ដើរយោងតែអាត្មាមិនចង់រួចផងបាទ ហើយអាខ្លះក៏ឈឺទៅ គេថាឈឺសតិអារម្មណ៍ ឈឺសតិអារម្មណ៍អី ដល់រួចទៅធ្លាក់ឈឺពិតប្រាកដ ដល់រួចទៅ គេថា "យី!ទុកវាក៏មិនចំណេញ ដកចេញក៏មិន

ខាត" យកទៅបាត់អស់ទៅ បាទគេទុកអត់ចំណោញ គេទុកធ្វើអ្វី គេទុកឲ្យអាណាចំណោញ។

**សៈ** នៅពេលដែលមនុស្សឈឺហ្នឹង តើពួកគេទាំងអស់ហ្នឹងបានទទួលរបបអាហារធម្មតាដែរ ឬទេនៅពេលដែលពួកគាត់មិនធ្វើការបាននោះ?

[១០:៣៤:០៦]

**ឆៈ** ពួកគេដែលមិនធ្វើការមិនបានហ្នឹង គឺអាហារបើតាមដែលខ្ញុំដឹងគឺគេបន្ថយទៀត គេថាឈឺ ហើយត្រូវបន្ថយទៀត ឲ្យគ្នាហូបបបររាវហើយហ្នឹងណ៎ា។ ហើយបើតាមពិតទៅគេថាយើងអត់មាន ពលកម្មអី មិនចេញធ្វើការងារអី "មិនបាច់ហូបច្រើនទេ ហូបបន្តិចៗបានហើយ" អ៊ីចឹងបាទ។

**សៈ** តើអ្នកជំងឺហ្នឹងមានទទួលការព្យាបាលសមរម្យដែរឬទេ?

**ឆៈ** បាទ អារឿងការព្យាបាលហ្នឹង ខ្ញុំក៏មិនបានទៅឃើញដែរ ប៉ុន្តែថាអ្នកដែលឃើញគេចូល ទៅហ្នឹង ឃើញអាថ្នាំលញ់ៗដូចអាចម៍ទន្សាយអ៊ីចឹង គេឲ្យលេបអ៊ីចឹងទៅ ហើយអាហ្នឹងមានគេ ព្យាបាលមានថ្នាំពេទ្យអីមិនដឹង ខ្ញុំអត់ដឹង អារឿងការព្យាបាល អត់។

**សៈ** តើឈ្លបភូមិត្រពាំងត្រាវនោះ នៅក្នុងឃុំត្រពាំងធំខាងជើង ហើយនិងកម្មាភិបាលខ្មែរក្រហម ដែលនៅធ្វើការនៅមូលដ្ឋានទុំង ពួកគេទាំងអស់គ្នាហ្នឹងទុកចិត្តរបស់ប្រជាជនថ្មីដែលនៅ ដែលគេបញ្ជូន មកពីគិរីវង់ដែរទេ ឬក៏ពួកគេទាំងអស់ហ្នឹងឃ្លាំមើលប្រជាជនដែលថ្មី មកទាំងប៉ុន្មានហ្នឹងទាំងអស់គ្នា?

**ឆៈ** បាទ ពួកគេមិនហ្នឹងដែលទុកចិត្តយើងប្រជាជនថ្មីហ្នឹងទេ មិនដែលទេ អត់ទុកចិត្តសោះ ពួកគេតាមដាន តាមសាកសួរយើងអ៊ីចឹង តាមគេថា "ស្លទឹកត្រជាក់"ហ្នឹង។ អាហ្នឹងគេៗនិយាយតាម ដានយើងតែរហូតហ្នឹង អត់ដែលទុកចិត្តយើងទេ បាទ។

**សៈ** តើនៅក្នុងភូមិហ្នឹងមានកម្មាភិបាលខ្មែរក្រហមដែលជាប្រជាជន១៧ មេសា ឬប្រជាជនថ្មី ដែរឬទេ?

**ឆៈ** អត់មានទេបាទ គឺមានតែគេមូលដ្ឋានទេ។

[១០:៣៦:៥៣]

**សៈ** អម្បាញ់មិញនេះលោកនិយាយថា ការជម្លៀសរបស់លោកត្រាំកក់ហ្នឹង ដែលជម្លៀសមក ពីស្រុកគិរីវង់នោះ ក្នុងខែកញ្ញា សីហា ឆ្នាំមួយពាន់ប្រាំបួនរយ -- ខែតុលា ឆ្នាំ១៩៧៧ ខ្ញុំសូមបង្ហាញ ឯកសារពីរជូនលោក ឯកសារទាំងពីរនេះទាក់ទងនឹងការជម្លៀសប្រជាជនពីស្រុក១០៩ មកដល់ស្រុក ១០៥ ដែលនៅក្នុងខែកញ្ញា តុលា ឆ្នាំ១៩៧៧ គឺឯកសារ E3/2448 ហើយនិងឯកសារ E3/4088

លោកប្រធាន -- 87 (សុំទោស)។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេះ**

លោកប្រធានខ្ញុំសូមបង្ហាញបញ្ចាំងឯកសារនេះនៅលើអេក្រង់ ជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី លោកប្រធាន។ សូមការអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាងលេះ**

**ស៖** បាទ ឯកសារទី១ នោះគឺឯកសារ E3/2448 ទំព័រពាក់ព័ន្ធជាភាសាខ្មែរគឺ 00079102។ ហើយខ្ញុំសូមបញ្ចាំងឯកសារហ្នឹងឥឡូវហ្នឹង បាទឥឡូវបញ្ចាំងហើយ។ ជាភាសាអង់គ្លេសគឺ 00322157 ជាភាសាបារាំង គឺ 00588784។ បាទ ដើម្បីសង្ខេបឯកសារនេះ គឺជារបាយការណ៍ដែលធ្វើនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៧ ដោយឈ្មោះ ម៉ុន ពីគណៈកម្មាការសហករណ៍ត្រពាំងធំខាងជើង ទៅកាន់អង្គការស្រុកទាក់ទងទៅនឹងស្ថានភាពខ្មាំង។ របាយការណ៍និយាយពីការចាប់ខ្លួនមនុស្សនៅក្នុងសហករណ៍ គឺចាប់ខ្លួនសិស្សម្នាក់ឈ្មោះ កែវ រៃ ដែលគាត់និយាយថាគាត់ហ្នឹងត្រូវបានបញ្ជូនដោយអង្គការពីស្រុក ១០៩។ គាត់ក៏បញ្ជាក់ផងដែរថា ពួកគាត់ត្រូវបានកម្ទេចដោយអង្គការហើយថា កែវ រៃហ្នឹងបាននិយាយផងដែរ ខ្ញុំសូមដកស្រង់៖ “ថាបើសិនជាខ្មែរបានឈ្នះសង្គ្រាមនោះពីព្រោះថា តាមអាមេរិកាំងបានឈប់ធ្វើការទម្លាក់គ្រាប់បែក” សូមបញ្ចប់ការដកស្រង់។ តើលោកស្គាល់មនុស្សម្នាក់ហ្នឹងដែលឈ្មោះ ម៉ុន ដែលតំណាងឲ្យគណៈកម្មការសហករណ៍ត្រពាំងធំខាងជើងដែរឬទេ?

[១០:៣៩:៥១]

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ឈ្មោះ ម៉ុន ហ្នឹង ខ្ញុំអត់ស្គាល់ទេបាទ។

**ស៖** ថាតើលោកស្គាល់ក្មេងម្នាក់ -- យុវជនម្នាក់ដែលឈ្មោះ កែវ រៃ ហ្នឹងដែលត្រូវបានបញ្ជូនពីស្រុកគិរីវង់ មកស្រុកត្រាំកក់ គឺក្រោយថ្ងៃទី៩ កញ្ញា ឆ្នាំ១៩៧៧ បន្តិច។ តើលោកធ្លាប់បានឮឈ្មោះ យុវជន កែវ រៃ នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលឮទេ សូម្បីតែថាអាកងយុវចាស់ហ្នឹងវានៅផ្សេង។ កងកុមារ កងយុវជន កងនារីហ្នឹង វានៅផ្សើងៗគ្នា។ ខ្ញុំអត់ដែលស្គាល់ផងបាទ។

**ស៖** បាទ អំមិញ ខ្ញុំនិយាយអំពីយុវជននេះ មិនមែននិយាយជាមនុស្សចាស់ទេ។ ឥឡូវ ខ្ញុំសូមចូលមកនិយាយអំពីឯកសារទី២ គឺឯកសារ E3/4082 ទំព័រ ERN ជាភាសាខ្មែរដែលត្រូវបញ្ជាំងហ្នឹង គឺលេខ 00079106, ជាភាសាបារាំងគឺ 00712134, ជាភាសាអង់គ្លេសគឺ 00276574។ បាទ នេះគឺជាឯកសារមួយទៀតដែលចេញពីសហករណ៍ឃុំត្រពាំងធំខាងជើងដដែល ចុះថ្ងៃទី៩ តុលា ឆ្នាំ១៩៧៧ ហើយឯកសារនេះត្រូវបានផ្ញើទៅអង្គការស្រុកត្រាំកក់។ របាយការណ៍នេះនិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "នៅក្នុងអង្គភាពយុវជនឃុំត្រពាំងធំខាងជើង មានយុវជនថ្មីដែលអង្គការឲ្យមកពី១០៩ មានឈ្មោះ ជឹប ឆន ជាកូនសិស្ស -- ម៉ម សឿន (សូមទោស) លាង លាត់, កែប សំ ពួកគេនេះបានលាក់ខ្លួនវេលាយប់ម៉ោង១២ នៅយប់នៅឆ្នាំ១៩៧៨។ ហើយឈ្លបនោះបានយកពួកគេទៅសួរចម្លើយ ពួកគេមិនព្រមឆ្លើយនៅស្ងៀមទាំងអស់គ្នា"។ សូមបញ្ចប់ការដកស្រង់។

តើនៅក្នុងចំណោមមនុស្សដែលត្រូវបានជម្លៀសពីស្រុក១០៩ មកស្រុកត្រាំកក់ ឬក៏គេហៅស្រុកគិរីវង់ មកស្រុកត្រាំកក់នេះ ដែលគេជម្លៀសមកជាមួយលោកហ្នឹង។ តើលោកមានធ្លាប់ស្គាល់យុវជនទាំងអស់ហ្នឹង ដែលមានឈ្មោះដូចខាងលើនេះ ជឹប ឆន, ម៉ម សឿន, លាង លាត់,កែប សំ ហ្នឹងដែរឬទេ? ធ្លាប់ឮឈ្មោះពួកគាត់ទាំងអស់គ្នា ឬក៏ស្គាល់ពួកគាត់ទាំងអស់គ្នាហ្នឹងដែរឬទេ?

[១០:៤៣:១៣]

**ឆ៖** ខ្ញុំអត់ស្គាល់ទេ។ បាទ អត់ដែរ មិនធ្លាប់ស្គាល់។

**ស៖** តើមុនពេលដែលគេចាប់ខ្លួនលោកៗធ្លាប់បានឮថា មានអ្នកផ្សេងទៀតត្រូវបានចាប់ខ្លួន គឺថាអ្នកប្រជាជន១៧មេសា ទាំងប៉ុន្មានដែលត្រូវគេបានជម្លៀសពីគិរីវង់ហ្នឹងមកដែរឬទេ?

**ឆ៖** បាទ ខ្ញុំមានម្នាក់ជម្លៀសមកពីគិរីវង់ដូចគ្នា ឈ្មោះវា អៀម សុខា។ អៀម សុខា ហ្នឹងវា -- គេចូលទៅមន្ទីរសន្តិសុខហ្នឹងមុនខ្ញុំទៀត។ បាទ ស្គាល់ឈ្មោះ អៀម សុខា ម្នាក់ទេ ក្រៅពីនុ៎ង -- ដូចថាយើងអត់មានស្គាល់អីចឹងទៅ អត់ៗមានស្គាល់នរណា។

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមផ្លាស់មកនិយាយអំពីការឃុំឃាំងខ្លួនលោកនៅអង្គរកា ដែលលោក

បាននិយាយអង្កាល់ពីថ្ងៃទី០២ មេសា កន្លងមកនេះ។ ឥឡូវនេះ ខ្ញុំសូមសួរបំភ្លឺ រយៈពេលជាក់លាក់ ឬក៏ខែជាក់លាក់ដែលលោកត្រូវបានគេចាប់ខ្លួន។ លោកបានឆ្លើយទៅចៅក្រមស៊ើបអង្កេត គឺឯកសារ E319/12.3.8 នៅចម្លើយ៦៥ លោកបានឆ្លើយថា លោកបានធ្វើការនៅទីនោះរយៈប្រហែលជា១ខែ នៅក្នុងក្រុមរទេះ មុន -- ក្រុមរទេះគោ មុនពេលដែលគេចាប់ខ្លួនលោកនោះ។ នៅក្នុង

ទម្រង់បែបបទចម្លើយបន្ថែមរបស់លោក គឺឯកសារ E3/5035 លោកបាននិយាយថា លោកត្រូវបានគេចាប់ខ្លួនរយៈពេលប្រាំខែ ក្រោយពេលដែលលោកមកដល់ត្រពាំងធំខាងជើងហើយ។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើប្រើរយៈពេលប្រហែលជាប៉ុន្មាន ក្រោយពេលដែលលោកមកដល់នៅភូមិត្រពាំងត្រាវ នៅក្នុងឃុំត្រពាំងធំខាងជើងនោះ ដែលលោកត្រូវបានគេចាប់ខ្លួន? មកដល់ប៉ុន្មានរយៈពេលប៉ុន្មានហើយបានគេចាប់ខ្លួនលោក? លោកនិយាយ -- ហើយក្រោយមកនុ៎ង គេបញ្ជូនលោកទៅអង្គរកានុ៎ង។ អ៊ីចឹងសួរថា រយៈពេលប៉ុន្មានក្រោយមក?

**ឆ៖** បាទ គេចាប់ខ្លួនខ្ញុំនុ៎ងវា ខ្ញុំមិនចាំថាខែប៉ុន្មានៗអ៊ីចឹងទេ ប៉ុន្តែថាក្នុងឆ្នាំ៧៨ បាទ ក្នុងឆ្នាំ៧៨ហ្នឹង គឺគេចាប់ខ្ញុំ។

[១០:៤៦:៣៣]

**សៈ** អ៊ីចឹង លោកមិនមាន -- មិនចាំច្បាស់ថារយៈពេលប្រហែលប៉ុន្មានខែ ក្រោយពេលដែលលោកចូលមកដល់ឃុំហ្នឹង ហើយក្រោយមកលោកចូលធ្វើការនៅក្នុងកងរទេះហើយហ្នឹង មិនដឹងថារយៈពេលប៉ុន្មានខែច្បាស់លាស់ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតមែនហើយ។

**សៈ** នៅក្នុងពាក្យបណ្តឹងសុំជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកនោះ គឺឯកសារ E3/5034 លោកថាលោកបានមកដល់អង្គរកា លោកនិយាយថា៖ “នៅពេលដែលដល់ផ្សារអង្គរកាហើយហ្នឹង អ្នកបើករទេះហ្នឹង បាននាំខ្ញុំទៅជួបប្រធានកងឈ្មោះ រស់”។ នៅសវនាការថ្ងៃទី០២ មេសា ប្រហែលជាម៉ោងដប់ បាទគឺឯកសារ E1/287.1 លោកបាននិយាយដូចតទៅនេះ “ខ្ញុំគិតថាផ្សារនោះ ប្រហែលគេយកមកប្រើធ្វើជាមន្ទីរនៅសម័យនោះ” ខ្ញុំសូមបញ្ចប់ការដកស្រង់។ បាទ កាលនោះ គឺនៅម៉ោងដប់សែសិបប្រាំពីរនាទី លោកនិយាយថា លោកធ្វើការនៅអង្គរកានោះ ក្នុងឋានៈជាទោស ហើយគេឱ្យលោកធ្វើការនៅពេលថ្ងៃ។ ហើយនៅក្នុងពេលធ្វើការនោះ តើលោកមានបានដឹងថា មន្ទីរដែលនៅផ្សារអង្គរកានោះ ដែល រស់ ធ្វើការនៅក្នុងមន្ទីរហ្នឹង។ អ៊ីចឹងខ្ញុំសួរថាតើមន្ទីរហ្នឹងជាមន្ទីរស្រុក ឬក៏មន្ទីរពាណិជ្ជកម្ម ឬមន្ទីរសន្តិសុខ ឬក៏ជាមន្ទីរអីផ្សេងទៀត?

[១០:៤៨:៤៧]

**ឆ៖** ខ្ញុំមិនច្បាស់ដែរ ព្រោះរឿងមន្ទីរហ្នឹង គេយកផ្សារអង្គរកាហ្នឹងធ្វើជាមន្ទីរស្រុកក៏មិនដឹងក៏ខ្ញុំមិនដឹង ប៉ុនថាខ្ញុំគេចាប់មកនោះ ចាប់មកពីឃុំ មកពីភូមិ ហើយអ៊ីចឹងមកដល់ហ្នឹង ខ្ញុំសន្និដ្ឋានខ្លួនឯង

ថាប្រហែលជាស្រុកហើយ ព្រោះឈ្លបស្រុកហ្នឹងឈ្មោះ តារស់ ហ្នឹងពិតមែន គេៗអ្នកជូនខ្ញុំទៅដាក់មន្ទីរសន្តិសុខហ្នឹង។

**ស៖** បាទ សូមអរគុណ។ បាទ នៅពេលដែលលោកទៅដល់មន្ទីរឃុំឃាំង គឺថាគុកអង្គរកាហ្នឹង លោកនិយាយថាមន្ទីរហ្នឹង គុកហ្នឹង នៅប្រហែលជាបីបួនរយម៉ែត្រពីផ្សារហ្នឹង នៅខាងលិចផ្សារ។ តើនៅពេលដែលលោកទៅដល់បន្ទប់ដែលគេនឹងឃុំខ្លួនលោកនោះៗ លោកមានអារម្មណ៍យ៉ាងម៉េចដែរ? តើក្លិនដែលសាយភាយចេញពីបន្ទប់ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** បាទ អារឿងទៅដល់កន្លែងហ្នឹង មុនដំបូង ចុះគេបញ្ជូនយើងទៅយប់ ខ្ញុំទៅឃើញភ្លើងហ្នឹងស្មានតែកន្លែងគេជីករណ្ដៅអីចឹងទៅ ដល់រួចទៅបានខ្ញុំឃើញរោងមួយដែលសងផ្ទាល់ដី គេដាក់រនាបក្ដារ ជញ្ជាំងក្ដារ ដំបូលប្រក់ស័ង្កសី ប្រហែលជាទទឹង៥ម៉ែត្រ បណ្ដោយ១០ម៉ែត្រជាងអីៗហ្នឹង។ ហើយដល់រួចទៅ ឈ្មោះ ម៉េង ហ្នឹង គេក៏យកអាសោទ្វារគុកហ្នឹងយកមកចាក់ ចាក់ហើយគេបើកទ្វារហ្នឹងទៅ គេរុញខ្ញុំបញ្ចូលទៅហ្នឹងទៅ ថាចូលទៅហ្នឹង ចង់ប្រកាច់ ចុះវាឆ្អេះអាទឹកនោមផង ស្អុយលាមកយើងហ្នឹងផង។ ដល់ហើយ ចូលទៅដល់ក្នុងហ្នឹងចង់ងាប់ម្ដងទៀតហើយ ក្លិនស្អុយអសោច។

[១០:៥១:៣៨]

**ស៖** តើអាការៈក្រៅរបស់អ្នកទោសដែលលោកឃើញនៅទីនោះយ៉ាងម៉េចដែរ? គាត់មើលទៅទំនងថាពួកគាត់ហ្នឹងមានសុខភាពល្អ ឬក៏យ៉ាងណា?

**ឆ៖** បាទ ពួកគាត់ទាំងអស់គ្នាហ្នឹង ដូចអត់មានសុខភាពល្អទេ បាទ។ ខ្ញុំមើលទៅ នៅតែស្បែកដណ្ដប់ឆ្អឹងដូចតែគ្នាទេ។ ខ្ញុំចូលទៅមុនដំបូង ខ្ញុំថែមទាំងអាណិតម្នាក់ឈ្មោះ អៀម សុខា ហ្នឹងទៀត។ ដូចថា គ្នាស្គមនៅតែស្បែកដណ្ដប់ឆ្អឹងហ្នឹង ហើយរបបរបស់ខ្ញុំហ្នឹង គេឲ្យ ដួសមកឲ្យខ្ញុំមួយវែកក្រឡុមមួយវែកដួសសម្លរហ្នឹង ដួសមកឲ្យខ្ញុំ ខ្ញុំក៏អត់ហូបទេ។ ខ្ញុំថា ឃើញគ្នាវាស្គមស្គាំងពេក មានតែស្បែកដណ្ដប់ឆ្អឹង។ ខ្ញុំថា ហ៎! ហូបទៅ។ គ្នាមិនហូបទេវ៊ី ឃើញឯង ដូចជាស្គមណាស់។ ប៉ុន្តែអារឿងសុខភាពខ្ញុំថាអត់មានណាមួយ អ្នកណាមួយសុខភាពល្អទេ អត់មានទេ។ អ្នកទោសទាំងអស់ហ្នឹង គ្មានតែសោះ។

[១០:៥៣:០៣]

**ស៖** នៅសវនាការថ្ងៃទី០២ មេសា ម៉ោង១១:០២នាទី លោកបាននិយាយថា អ្នកដែលមានមនុស្សស្លាប់នៅក្នុងមន្ទីរឃុំឃាំងឈ្មោះ ផាត់។ បើតាមស្លាប់ដោយអត់ឃ្លានអាហារនោះ។ អីចឹងបើតាមលោកដឹងនោះ តើមានអ្នកទោសណាស្លាប់ដោយអត់ឃ្លាន ដោយជំងឺ ឬក៏ដោយការធ្វើបាបនៅ

អង្គរកាហ្នឹងដែរឬទេ នៅពេលដែលលោកជាប់ឃុំឃាំងដែរហ្នឹង?

**ឆៈ** បាទ នៅពេលដែលខ្ញុំជាប់ឃុំឃាំងហ្នឹង ព្រោះថាក្នុងរយៈពេលខ្ញុំនៅក្នុងគុក គឺមានអាម្នាក់ហ្នឹង មិនមែនឈ្មោះ ផាត់ ទេ គឺវាឈ្មោះ ប៉ាត់ – បាទ ឈ្មោះ ប៉ាត់។ ហើយអ្នកផ្សេងទៀតហ្នឹងមានម្នាក់អាមួយនោះ គ្នាពិការៗ ហើយដល់រួចទៅវាធ្វើការអីមិនបានពេញលេញដូចគេ គ្នាពិការហ្នឹង។ អាទុកក៏មិនចំណេញ ដកចេញក៏មិនខាត។ គេយកដាក់ជីដូងជីអី ខ្ញុំអត់ដឹង គេយកទៅបាត់ទៅ មិនដឹងយកទៅណា។

[១០:៥៤:២៧]

**សៈ** លោកបាននិយាយអំពីទំហំបន្ទប់ឃុំឃាំង តើលោកអាចបញ្ជាក់ដែរឬទេថាមានបន្ទប់តែមួយទេ ដែលគេឃុំមនុស្សនោះ? ឬក៏មានបន្ទប់ផ្សេងទៀតដែរ ដែលគេឃុំមនុស្ស?

**ឆៈ** ក្នុងរោងវែងមួយដែលគេសង់ទទឹង៥ម៉ែត្រ បណ្ដោយប្រហែល១០ម៉ែត្រជាងហ្នឹង គឺអត់មានបន្ទប់ច្រើនទេ គឺមួយរោងហ្នឹង ប៉ុន្តែគេរៀបពីរល្វែង យើងដេកទល់ជើងគ្នាអ៊ីចឹង ហើយអាប្រឡោះកណ្ដាលហ្នឹងគេដាក់ខាប់ ដាក់ពាងអីសម្រាប់យើងបត់ដៃ បត់ជើងអីហ្នឹង។ បាទ ប្រឡោះកណ្ដាលអ៊ីចឹង។ ហើយស្រីៗដេកក្បាលទៅនោះទៅ ហើយខ្ញុំប្រុសៗដេកក្បាលមកនេះមក ហើយជើងជាប់ខ្នោះដូចតែគ្នាហ្នឹង ប៉ុន្តែថាអាមួយជាប់ជើងទាំងសងខាង មួយជាប់ជើងម្ខាង។ តែមួយបន្ទប់ទេ -- តែមួយរោងហ្នឹង អត់មានច្រើនបន្ទប់ទេ។

**សៈ** តើលោកអាចប៉ាន់ប្រមាណចំនួនជាអតិបរិមារបស់អ្នកទោសដែលត្រូវបានជាប់ឃុំឃាំងក្នុងពេលជាមួយលោកដែរឬទេ ជាប់ឃុំពេលយប់នៅអង្គរកាហ្នឹង? តើមានពេលណាមួយនោះ មានមនុស្សអ្នកជាប់ចោទឃុំឃាំងច្រើនជាងគេបំផុតដែរឬទេនៅក្នុងកន្លែងដែលគេ -- រោងដែលគេឃុំខ្លួនលោកនោះ?

**ឆៈ** បាទ វាមានដោយថ្ងៃអ៊ីចឹងដែរ។ ថ្ងៃណានេះ គេបញ្ជូនទៅណែនទាំងអស់។ ដល់រក ដល់ពេលយប់អ៊ីចឹង គេបញ្ចូលយកទៅដាក់នៅហ្នឹង នៅជាប់គុកនៅហ្នឹង។ ហើយដល់ពេលថ្ងៃ ដូចថាវាណែនពេកអ៊ីចឹង គេបញ្ជូនចេញវិញ មិនដឹងទៅឯណាទេ។

[១០:៥៦:៥៥]

**សៈ** តើលោកអាចធ្វើការប៉ាន់ប្រមាណបានដែរឬទេ នៅពេលដែលរោងហ្នឹងមានមនុស្សច្រើនអ្នកឃុំខ្លួនច្រើនមែនទែននោះ តើនៅពេលយប់នោះមានអ្នកទោសប៉ុន្មាននាក់ដែលគេដាក់ខ្នោះ?

**ឆ៖** បាទ ប៉ាន់ប្រមាណហ្នឹង ខ្ញុំថាវាពី៧០នាក់ យ៉ាងហោចណាស់ក៏មាន៧០នាក់ដែរ ហើយតែនៅក្នុងហ្នឹងហើយ គឺជាប់ខ្នោះទាំងអស់។ អត់មានទេ លើកលែងតែកុមារតូចៗ ដូចថាកូនខ្ចីអីហ្នឹង អាហ្នឹងនៅបៅដោះហ្នឹង អាហ្នឹងអត់មានដោះខ្នោះទេ ដាក់ខ្នោះតែម៉ែវា។

**សៈ** បាទ ទាក់ទងទៅនឹងអ្នកថ្មីដែលមកដល់ អ្នកទោសថ្មី មកដល់អង្គរកានោះ កាលពីថ្ងៃទី០២ មេសា កន្លងមកនេះ លោកបាននិយាយថា "មកម្តងម្ភាលទេ"។ តើលោកអាចបញ្ជាក់ជូនតុលាការបានដែរឬទេអំពីអ្វីដែលលោកចង់និយាយនៅពេលនោះ តើអ្នកទោសថ្មីនោះមករាល់សប្តាហ៍ ច្រើនដងក្នុងមួយខែ ឬក៏លោកប៉ាន់ប្រមាណខុសពីនេះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១០:៥៨:៣១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

ទោះបីថាសំណួរវាគួរឲ្យចាប់អារម្មណ៍ ហើយចម្លើយក៏ប្រហែលជាគួរឲ្យចាប់អារម្មណ៍ដែរ ក៏ប៉ុន្តែខ្ញុំយល់ថា ក្នុងស្ថានភាពនេះនិយាយអំពីអង្គរកា គឺវាមិនមែនជាផ្នែកនៃការជំនុំជម្រះមួយនេះទេ។ ដូច្នេះ ខ្ញុំគិតថាប្រហែលជាខ្ញុំអាចធ្វើជាសំណើឲ្យមានការណែនាំទាក់ទងទៅនឹងមន្ទីរឃុំឃាំងអង្គរកា។ ដូច្នេះ ប្រសិនបើអង្គជំនុំជម្រះយល់ថា វាពាក់ព័ន្ធទៅនឹងការដំណើរការរបស់ក្រាំងតាចាន់ ខ្ញុំយល់ថាវាជារឿងសមស្របមួយដែរ។ ប៉ុន្តែខ្ញុំចង់ ខ្ញុំលើកការជំទាស់ខ្ញុំឡើង ដើម្បីចង់ឲ្យមានការណែនាំពីអង្គជំនុំជម្រះទៅវិញទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ ខ្ញុំសូមឆ្លើយតប។ បាទ គឺថាមានទំនាក់ទំនងជាមួយក្រាំងតាចាន់ ដែលត្រូវបានបង្ហាញរួចហើយតាមរយៈឯកសារដែលបង្ហាញជូនតុលាការកន្លង។ ហើយចំណុចមួយទៀត គឺថាមានទំនាក់ទំនងច្បាស់លាស់ណាស់ជាមួយនឹងសហករណ៍នៅក្នុងស្រុកត្រាំកក់ ពីព្រោះថាអ្នកដែលនៅក្នុងសហករណ៍នោះត្រូវបានចាប់ខ្លួន ជូនបញ្ជូនទៅអង្គរកា ជូនបញ្ជូនទៅក្រាំងតាចាន់។ អ៊ីចឹងខ្ញុំគិតថាទំនាក់ទំនងនេះច្បាស់លាស់ហើយ ហើយខ្ញុំសូមអនុញ្ញាតសួរបន្ត សំណួរបន្តទៀតលោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០១:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចថាអនុញ្ញាតឲ្យភាគីអាចសួរពាក់ព័ន្ធជាមួយនឹងអង្គហេតុនៃមន្ទីរសន្តិសុខអង្គរកា ប៉ុន្តែសូមភាគីជ្រាបថា មិនគប្បីសួរឲ្យបានលម្អិតពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខអង្គរកានោះទេ។ ប៉ុន្តែអង្គរកាហ្នឹង គឺជាផ្នែកមួយដែលពាក់ព័ន្ធទាំងជាមួយនឹងសហករណ៍ត្រាំកក់ ហើយក៏ពាក់ព័ន្ធផងដែរ ជាមួយនឹងមន្ទីរសន្តិសុខក្រាំងតាចាន់។

ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយសហព្រះរាជអាជ្ញារងអន្តរជាតិ ប្រសិនបើនៅចាំ ហើយបើសិនមិនចាំទេ សហព្រះរាជអាជ្ញារងអន្តរជាតិអាចរំឭកឡើងវិញនូវសំណួរដែលលោកបានសួរទៅដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ថាន់ ធីម៖**

**ឆ៖** សុំសំណួរម្តងទៀតបាទ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសួរឡើងវិញ។ លោកដើមបណ្តឹងរដ្ឋប្បវេណីតើអ្នកទោសថ្មីមកមន្ទីរអង្គរកានុំងមកមួយសប្តាហ៍ម្តង ឬក៏មួយខែហ្នឹងច្រើនដង ឬក៏មកញឹកញាប់ខុសពីហ្នឹង?

**ឆ៖** បាទ វាអត់ទៀង ជួនណានេះមួយអាទិត្យមកម្តងអ៊ីចឹងទៅ បួនដប់នាក់អ៊ីចឹងទៅ។ ជួនណានេះ កន្លះខែអី វាអត់ទៀងបាទ។

**ស៖** តើអ្នកទោសនោះ មកចំនួនច្រើន ឬក៏មិនទៀងទាត់ទេ ឬក៏មានក្រុមអ្នកទោសនុំងមកម្តងព្រមៗគ្នាតែម្តង?

**ឆ៖** ជួនណាក៏មកជាក្រុមអ៊ីចឹងមក។ បើខាងនារីមកប្រហែលជាប្រាំមួយ ប្រាំពីរនាក់អីអ៊ីចឹងមក ហើយបើខាងបុរសហ្នឹង មកម្តងបួនប្រាំនាក់អីអ៊ីចឹងមក។ ប៉ុន្តែចូលទៅខាងនុំងតែពេលយប់ទេ ដាក់ខ្មោះមួយយប់ហ្នឹង ដឹងថាបញ្ចេញទៅទៀតហើយ មិនដឹងទៅឯណាបាទ។

[១១:០៤:៤៣]

**ស៖** បាទ ទាក់ទងទៅនឹងអ្នកទោសចេញ លោកបាននិយាយនៅក្នុងចម្លើយរបស់លោក គឺឯកសារ E3/50 -- បាទ គឺឯកសារ E319/12.3.8 លោកឆ្លើយថានៅអង្គរកានោះ រាល់ថ្ងៃគេយកអ្នក

ទោសប្អូនទៅប្រាំនាក់ទៅសម្លាប់រៀងរាល់ថ្ងៃ។ ឯកសារមួយទៀត គឺឯកសារ E3/5035 គឺថាលោកនិយាយថា "រៀងរាល់បីបួនថ្ងៃម្ដង ពីរបីថ្ងៃម្ដង" គឺជាចម្លើយបន្ថែមរបស់លោក។ តើការដែលយកមនុស្សចេញនេះពីអង្គរកាប្រែប្រួលទៅតាមពេលវេលា ឬក៏យ៉ាងណាយកមនុស្សចេញទៅក្រៅនោះ សួរថាប្រែប្រួលតាមវេលា ឬក៏មិនមានការប្រែប្រួលអីទេ?

**ឆ៖** បាទ អារឿងវាប្រែប្រួលតាមពេលតាមវេលាអ៊ីចឹង វាមិនមែនដូចថាជាប់លាប់ទេ។

**ស៖** អ៊ីចឹងលោកបាននិយាយថាអ្នកដែលគេយកចេញទៅហ្នឹង គឺត្រូវគេយកចេញទៅសម្លាប់នៅជើងភ្នំដំរីរមៀល។ តើបើតាមលោកដឹងនោះ នៅពេលដែលលោកធ្វើការនៅក្រោមមន្ទីរ ឬក៏មន្ទីរឃុំឃាំងនៅអង្គរកានោះ លោកធ្លាប់បានឃើញអ្នកទោសនោះត្រូវបានគេបញ្ជូនទៅមន្ទីរស្រុកឬក៏ថាមន្ទីរនៅផ្សារអង្គរកាហ្នឹងដែរឬទេ?

**ឆ៖** បាទ អ្នកទោសគេបញ្ជូនមកតែមន្ទីរៗកន្លែងខ្ញុំជាប់ហ្នឹង អាហ្នឹងនៅពីខាងលិចផ្សារអង្គរកាបន្តិចហ្នឹង។ ហើយអារឿងគេយកទៅសម្លាប់ ឬក៏ទៅណានោះ ខ្ញុំអត់បានដឹងទេ ពីព្រោះខ្ញុំលបមើលតាមប្រឡោះជញ្ជាំងក្ដារអ៊ីចឹងវាអត់មាននៀវ វាមានប្រហោងតូចៗ ខ្ញុំលបមើលទៅឃើញគេយកអ៊ីចឹងបណ្ដើរទៅលិចៗទៅ ខ្ញុំអត់ដឹងថាយកទៅណា។

[១១:០៧:៥៥]

**ស៖** តើនៅពេលនោះ លោកធ្លាប់បានឮអ្នកទោសផ្សេងទៀតនិយាយ ដែលគេអ្នកទោសជាមួយលោកនៅអង្គរកានោះ ធ្លាប់បាននិយាយពីមន្ទីរសន្តិសុខក្រាំងតាចាន់ដែរឬទេ? តើលោកធ្លាប់បានឮគេនិយាយអំពីមន្ទីរក្រាំងតាចាន់ហ្នឹង ហើយនិងពីមុខងារនាទីហ្នឹងទេ នាទីហ្នឹងជានាទីអ្វីដែរ?

**ឆ៖** ខ្ញុំៗបាទមិនដែលឮទេ អារឿងហ្នឹងពីព្រោះថាអ្នកទោសណាក៏គេនៅជាប់ជាមួយគ្នាហ្នឹងក៏មិនដែលឮថាមន្ទីរក្រាំងតាចាន់ហ្នឹងដែរ ទើបដឹងឥឡូវហ្នឹងដែរទេ ដឹងអាពេលបែកហើយដែរ អត់ដឹងថា -- អ្នកទោសនៅជាប់ជាមួយខ្ញុំមិន វាមិនធ្លាប់ឮគេនិយាយអ៊ីចឹងដែរ អត់មាននរណានិយាយអីផង។

**ស៖** លោកបានឆ្លើយនៅថ្ងៃទី០២ មេសា កន្លងមកនេះ តើគេបានឲ្យលោកធ្វើការហ្នឹងក្រោយពេលលោកទៅដល់មន្ទីរឃុំឃាំងក្បែរមន្ទីរ -- ក្បែរអង្គរកាហ្នឹងហើយទើបបានគេឲ្យលោកធ្វើការពីរខែហើយ។ ហើយក្រោយមក ម៉េង សួរចម្លើយលោកហើយៗ។ អ៊ីចឹងលោកដឹងថាហេតុអ្វីបានគេអនុញ្ញាតឲ្យលោកធ្វើការពេលថ្ងៃដែរទេ បន្ទាប់ពីគេសួរចម្លើយលោកហើយអស់ហ្នឹង គេឲ្យលោកធ្វើការពេលថ្ងៃ?

**ឆ៖** បាទ បន្ទាប់ពីខ្ញុំនៅជាប់នៅក្នុងមន្ទីរហ្នឹងគិតទៅវាចូលថាបីខែ ហើយដល់រួច ដល់ពេលអាពួកគេជាប់មុនហ្នឹង គេចេញទៅធ្វើការអស់អ៊ីចឹងទៅនៅតែខ្ញុំម្នាក់ឯងហ្នឹង។ ហើយបានឈ្មោះ ម៉េង ហ្នឹង គេហៅខ្ញុំទៅសួរចម្លើយ ហើយកត់ឆ្នាំណានៅឯណាៗ បានរួចទៅគេឲ្យចេញធ្វើការពេលថ្ងៃ។ គេគ្រាន់តែសួរចម្លើយចប់គេឲ្យខ្ញុំរែកទឹកស្រោច ដូចជាដូង ដូចជាត្រប់ ដូចជាអំពៅ ដូចអ៊ីចឹង ហើយខ្ញុំចេះតែខំរែកទៅបាទ។

[១១:១០:៤៧]

**ស៖** ក្រៅពីកម្មាភិបាល រស់ ដែលជាឈ្លបដែលលោកបានជួបពីដំបូងទី តើមានមេ ឬក៏កម្មាភិបាលស្រុកណាផ្សេងទៀតទេដែលបានមកជួប ម៉េង នៅគុកហ្នឹង? តើលោកធ្លាប់បានសង្កេតឃើញថាមានកម្មាភិបាលផ្សេងទៀតមកជួបម៉េងនៅមន្ទីរហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់ធ្លាប់ដែលឃើញទេបាទ មិនធ្លាប់ដែលឃើញទេ។

**ស៖** តើ ម៉េង ដែលជាប្រធានគុកហ្នឹង មាននីរសារដែរឬទេ?

**ឆ៖** អារឿងគេមានមិនមាន គេមិនឲ្យយើងដឹងទេ ខ្ញុំអត់ដឹងផង បាទ។

**ស៖** នៅថ្ងៃទី០២ មេសា កន្លងមកនេះ ឆ្នាំ២០១៥នេះ លោកបាននិយាយអំពីកូនង៉ាដែលនៅជាមួយម្តាយ ដែលឃុំខ្លួននៅអង្គរការពេលដែលលោកទៅដល់ទីនោះ ហើយថ្ងៃនេះក៏បានលោកនិយាយថាកូនក្មេង ហើយកូនង៉ានោះមិនត្រូវបានដាក់ខ្នោះទេ ក៏ប៉ុន្តែម្តាយពួកគេត្រូវបានដាក់ខ្នោះ។ អ៊ីចឹងលោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនដើមបណ្តឹងរដ្ឋប្បវេណីនូវឯកសារ E3/4093 ហើយនិងសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១១:១២:៤២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ មុននឹងចូលទៅហ្នឹង ខ្ញុំសូមសួរសំណួរមួយ ថាតើកូនង៉ាហ្នឹងទទួលជោគវាសនាដូចម្តាយពួកគេដែរឬអត់? គឺចង់និយាយថា បើសិនជាម្តាយរបស់គេត្រូវបាននាំចេញទៅហ្នឹង គឺកូនង៉ាទាំងអស់ហ្នឹងក៏ត្រូវបាននាំចេញដែរ។ តើអ៊ីចឹងមែនទេ?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ចុះអាកូនង៉ា នៅបៅដោះហ្នឹង តែម្តាយវាទៅណា កូនទៅជាមួយតែគ្នាហ្នឹង បាទ។

**ស៖** បាទ ទំព័រ ERN ជាភាសាខ្មែរ គឺមានបួនទំព័រ គឺយើងនឹងបញ្ចាំងជាបន្តបន្ទាប់។ គឺ ERN 00270786 រហូតដល់ 89, បាទជាភាសាបារាំង ERN គឺ ERN 00729674 ហើយនិង75, ជាភាសាអង់គ្លេស គឺ 00831486 ទៅដល់ 87។ បាទ គឺជាឯកសារដែលត្រូវទទួលយថាភាពរួចហើយ ដែល ដោយ តាសាន ដែលជាមេស្រុកនៅត្រាំកក់ ហើយបានផ្តល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះនេះ គឺជាបញ្ហាចេញថ្ងៃទី ៧ សីហា ឆ្នាំ ១៩៧៨ ដោយតាសាន ទៅតាឈឿន ដែលមានសរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ទាក់ទងនឹងស្ត្រីមេម៉ាយដែលមកពីត្រពាំងធំខាងជើង សព្វថ្ងៃនេះពួកស្ត្រីមេម៉ាយទាំងអស់នេះនៅកន្លែងសមមិត្តមេន អ៊ីចឹងខ្ញុំសូមឲ្យបោសសម្អាតទាំងអស់ ឲ្យបោសសម្អាតឲ្យស្អាត”។ សូមបញ្ចប់ការដកស្រង់។ ទំព័រ បន្ទាប់ទៀតគឺជាភាសាខ្មែរគឺ លេខERN 00270788។ ខ្ញុំសូមដកស្រង់ នេះគឺជាសាររបស់ ម៉េង ដែលចុះថ្ងៃទី៨ សីហា ឆ្នាំ១៩៧៨។ ខ្ញុំសូមដកស្រង់ “ខ្ញុំសូមបញ្ជាក់ដូចតទៅនេះទាក់ទងទៅនឹងរបាយការណ៍នៅមូលដ្ឋានឃុំត្រពាំងធំខាងជើង ទាក់ទងទៅនឹងរឿងស្ត្រីមេម៉ាយទាំងប្រាំនាក់ ដែលមានឈ្មោះដូចខាងក្រោមនេះ៖ ឈ្មោះទី១ គឺឈ្មោះ មួយ កូនកាត់ចិន-យួន, ទី២ ឈ្មោះ បាន សុគន់ ហៅ ហៀក កូនកាត់ចិន-យួន, ទី៣ គៀវ, ទី៤ ធូ ហៅ ឡេង ជនជាតិវៀតណាម, ទី៥ ម៉ៅ”។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងរបាយការណ៍នេះនិយាយថា ពួកស្ត្រីទាំងអស់នេះរអ៊ូរទាំរឿងខ្វះអាហារ និងធ្វើការងារលំបាក ហើយសម្រេចរត់ទៅវៀតណាម។

បាទ នេះនិយាយពីអ្នកទោសទាំងប្រាំនាក់ នៅខែសីហា ឆ្នាំ១៩៧៨។ នៅក្នុងចំណោមអ្នកទោសទាំងអស់នោះគឺលោកក៏ជាអ្នកទោសដែរ។ តើលោកធ្លាប់ស្គាល់ស្ត្រីមេម៉ាយទាំងប្រាំនាក់ហ្នឹងដែរឬទេ? គឺថាមានមួយ, មាន បាន សុគន់, ហៀក, គៀវ ហើយធូ ហៅ ឡេង ឬក៏ម៉ៅ នេះលោកធ្លាប់ស្គាល់ស្ត្រីមេម៉ាយទាំងប្រាំនាក់ហ្នឹងដែរឬទេ?

[១១:១៦:៣៨]

**ឆ៖** បាទ ស្ត្រីទាំងអស់ហ្នឹង ខ្ញុំមិនធ្លាប់ស្គាល់ទេ ក៏ប៉ុន្តែខ្ញុំបានឃើញ។ ឃើញចូលទៅជាប់ហ្នឹងជាមួយខ្ញុំហ្នឹងដែរបាទ។ ប៉ុន្តែជាប់ហ្នឹងអត់យូរទេ ទៅគ្រាន់តែដាក់ខ្នោះមួយយប់ ពីរយប់ហ្នឹង គេយកចេញទៅទៀតទៅ។ បាទ តែប៉ុណ្ណឹងទេ។ រឿងវាទៅភ្លាមៗ ចេញភ្លាមៗអ៊ីចឹង ខ្ញុំអត់បានស្គាល់ដែរ បាទ ជម្រាបប៉ុណ្ណឹង។

**សៈ** តើលោកមានចាំទេថា មានកូនង៉ានៅជាមួយពួកស្ត្រីមេម៉ាយទាំងអស់ហ្នឹងដែរឬទេ?

**ឆៈ** មានម្នាក់ បាទ មានកូនង៉ាម្នាក់នៅនឹងម្តាយហ្នឹងប៉ៅ បំបៅដោះនៅហ្នឹង។

**សៈ** បាទ ឥឡូវនេះ ខ្ញុំសូមបង្ហាញឯកសារមួយទៀតជូនលោក គឺឯកសារ D157.6។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារនេះទៅដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសូមអនុញ្ញាតបញ្ចាំងលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:១៨:២៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ERN ជាភាសាខ្មែរគឺ 007--

**អ្នកបកប្រែ៖**

លោកប្រធាន សូមទោសខ្ញុំតាមលេខ ERN អត់ទាន់លោកប្រធានពីសំណាក់អ្នកបកប្រែ។

**ប្រធានអង្គជំនុំ៖**

បាទ សូមបង្ហាញបញ្ជាក់ពីលេខ ERN នៃឯកសារដែលលោកបំណងបង្ហាញនាពេលនេះ។ អំមិញអត់មានការបកប្រែភាសាទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**សៈ** បាទ សូមអរគុណលោកប្រធាន។ ជាភាសាខ្មែរគឺ 00270720, ជាភាសាអង់គ្លេសគឺ 00322089។ មិនមានការបកប្រែជាភាសាបារាំងទេលោកប្រធាន។ បាទ នេះគឺជាឯកសារដែលផ្ញើចេញ ផ្ញើដោយ ម៉េង ផ្ញើទៅអង្គការជូនជាព័ត៌មាន។ ខ្ញុំសូមបញ្ជាក់ផងដែរ មុននឹងរៀបរាប់គឺថាមានភាពមិនស៊ីសង្វាក់គ្នា គឺថានៅ -- ជាភាសាអង់គ្លេសគេនិយាយពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៤ តែតាមពិតទៅដូចជាឆ្នាំ១៩៧៨ ទេ។ ហើយព័ត៌មាននេះទាក់ទងនឹងអ្នកទោសតែមួយទេ គឺឈ្មោះ ឡាយ គៀត ដែលមាននៅក្នុងឯកសារផ្សេងទៀតផងដែរ ដែលឯកសារនោះចុះឆ្នាំ១៩៧៨ទេ។ អ៊ីចឹងនេះ គឺជាឯកសារចុះថ្ងៃទី១៧ មិថុនា ដែលផ្ញើចេញដោយ ម៉េង ជូនទៅបក្ស ជូនជាព័ត៌មាន ទាក់ទងទៅនឹង ឡាយ គៀត ដែលកាលនោះ គាត់មានអាយុ២៧ឆ្នាំ កើតនៅផ្សារគីរីរម្យ ស្រុក១០៩ ដែលជាប្រជាជនថ្មី

ត្រូវបានគេនាំមកត្រាំកក់។ ម៉េង បានរៀបរាប់ថា ឡាយ គៀត ហ្នឹង បានត្អូញត្អែរអំពីលក្ខខណ្ឌរស់នៅជាជីវភាពក្រោយបដិវត្តន៍ ហើយធ្វើការលើកម្លាំង ហើយគាត់ក៏បានប្រមូលផ្តុំគ្នាជាមួយយុវជនផ្សេងទៀត ហើយត្អូញត្អែរថា ហូបចុកមិនគ្រប់គ្រាន់ ហើយនិងពួកគេបានបំផ្លាញកូនខ្ទុរ។ តើនៅពេលដែលលោកជាអ្នកទោសនៅអង្គរកានោះ លោកមានធ្លាប់ស្គាល់យុវជនម្នាក់ដែលឈ្មោះ ឡាយ គៀត ដែរឬទេ ដែលតាមឯកសារមួយទៀត នៅក្នុងសំណុំរឿងហ្នឹង គឺឯកសារ E3/4092 ដែលក្នុងឯកសារនុ៎ងបញ្ជាក់ថា ឡាយ គៀត នេះជាប់ខ្សែចិន។ លោកស្គាល់ឈ្មោះ ឡាយ គៀត នេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ស្គាល់ទេ។

[១១:២១:២៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់ស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺប៉ុណ្ណោះ លោកប្រធាន។ ខ្ញុំសង្កេតឃើញថាវាមានភាពខុសគ្នាទាក់ទងទៅនឹងកាលបរិច្ឆេទ នៅពេលបកប្រែទៅជាភាសាអង់គ្លេស គឺនៅខុសពីនឹងឯកសារជាភាសាខ្មែរ។ ទោះបីថាខ្ញុំមិនយល់ច្បាស់ ប៉ុន្តែនៅក្នុងឯកសារភាសាខ្មែរខុសពីនេះ។ ខ្ញុំឃើញថាយើងគួរតែកត់សម្គាល់ ហើយខ្ញុំស្នើសុំឱ្យមានការកែតម្រូវទៅលើកាលបរិច្ឆេទ ហើយយើងគួរតែសម្រេចនៅពេលនេះតែម្តង នៅពេលដែលមានការបកប្រែខុសបែបនេះ។ សូមអរគុណលោកប្រធាន។

[១១:២២:១៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៤:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ដើមបណ្តឹងរដ្ឋប្បវេណីអញ្ជើញចេញក្រៅមួយភ្លែត។

សូមបញ្ជាក់ឡើងវិញថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់ត្រូវការទៅបន្ទប់ទឹកជាបន្ទាន់។ អ៊ីចឹងហើយបានយើងសម្រេចឱ្យគាត់ អនុញ្ញាតឱ្យគាត់ទៅ ដោយសារគាត់មិនអាចទ្រាំបាន។

បាទ ប្រគល់ភារៈជូនលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ អម្បាញ់មិញនេះ។ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស័៖**

នេះគឺជាការឆ្លើយតបទៅនឹងសំណើឲ្យមានការណែនាំពីខាងមេធាវីការពារក្ដី។ យើងស្នើថា គឺមេធាវីការពារអាចធ្វើសំណើសុំឲ្យមានការកែតម្រូវ ដើម្បីឲ្យមានភាពងាយស្រួលនៅក្នុងសំណុំរឿង ហើយភាគីដែលរកឃើញថាវាកំហុស ឬក៏មានបញ្ហា អាចធ្វើសំណើបាន។ សូមអរគុណ។

[១១:២៦:០៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន មុននឹងដើមបណ្ដឹងរដ្ឋប្បវេណីត្រឡប់មកវិញនេះ ខ្ញុំសូមបញ្ជាក់ថាលេខ៤ ហើយនិងលេខ៨នេះ ស្រដៀងគ្នាជាភាសាខ្មែរ។ អ៊ីចឹង ពេលខ្លះអ្នកបកប្រែហ្នឹង គាត់ពិបាកនឹងយល់ឲ្យច្បាស់។ ហើយខ្ញុំសូមទាញការសន្និដ្ឋានថា ពិតជាឆ្នាំ៧៨ ព្រោះថានៅក្នុងឯកសារបីផ្សេងទៀត គឺចុះឆ្នាំ៧៨ទាំងអស់។ អ៊ីចឹង ខ្ញុំសូមផ្ដល់ឯកសារទាំងបីនេះ គឺឯកសារ E3/4083, ជាភាសាអង់គ្លេស គឺERN 00323947, ហើយនិងឯកសារមួយទៀត E3/2046, ERN ជាភាសាអង់គ្លេសគឺថា 00290202។ មួយទៀត គឺឯកសារ E3/4092, ERN ជាភាសាខ្មែរគឺ 00271150, ជាភាសាអង់គ្លេសគឺ 0083 4809 ដល់ 10។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទខ្ញុំនៅសល់តែពីរសំណួរទៀតទេលោកដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីសួរទៅកាន់លោក។ ឈ្មោះ ឡាយ គៀត នេះ បើតាមឯកសារដែលអានជូនលោក នៅនឹងអង្គរកានេះ ខ្ញុំសួរថាតើនៅអង្គរកានេះមានមនុស្សដែលត្រូវបានគេចាប់ខ្លួនច្រើនដែរទេ ដោយហេតុថាគាត់ហ្នឹងបានរិះគន់អំពីជីវភាព ហើយនិងលក្ខខណ្ឌការងារនៃបដិវត្តន៍នៅក្រោមរបបខ្មែរក្រហមហ្នឹង?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ដូចជានៅកន្លែងមន្ទីរសន្តិសុខអង្គរកាហ្នឹង ដូចអត់មានឃើញអ្នកណារិះគន់ស្អីផង ខ្ញុំអត់ដឹង។

[១១:២៨:៤៥]

**ស៖** បាទ ខ្ញុំដឹងថា នៅពេលដែលគាត់ទៅដល់គុកហើយហ្នឹង គាត់មិនរិះគន់បដិវត្តន៍ទេ ក៏ប៉ុន្តែខ្ញុំសួរថាតើអ្នកទោសផ្សេងទៀតដែលជាប់គុកជាមួយលោកដែរនោះ គាត់ប្រាប់ដល់គាត់ ដោយសារគាត់រិះគន់របបហ្នឹងហើយ គឺថាគាត់រិះគន់អង្គាល់ដែលគាត់នៅសហករណ៍ ឬក៏នៅក្នុងកងចល័តហ្នឹងគាត់

រិះគន់របបហ្នឹង អ៊ីចឹងហើយបានគេចាប់គាត់មកដាក់គុកអង្គរកាហ្នឹង?

**ឆ៖** បាទ គេចាប់មកដាក់គុកអង្គរកាហ្នឹង បើនេះទៅមនុស្សវាច្រើនអ៊ីចឹង ខ្ញុំអត់បានស្គាល់ឈ្មោះអស់ទេ មិនដឹងមួយណាជាមួយណា ឈ្មោះអីៗ ខ្ញុំអត់ស្គាល់ទេ បាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ឥឡូវហ្នឹង ខ្ញុំអស់សំណួរហើយ លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមអរគុណដែលមកត្រឡប់មកវិញដើម្បីឆ្លើយនឹងសំណួរ និងចំណាយពេលវេលា។ បាទ សូមអរគុណ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ ដែលអង្គុយអមគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅខាងមុខអង្គជំនុំជម្រះនេះនៅវេលាម៉ោងមួយ និងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយ សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តី ដែលជាដំបូងនេះ ប្រគល់ទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរតិចតួចទេ ដែលត្រូវសួរលោកបន្តពីអ្វីដែលបានសួរព្រឹកមិញ ទាក់ទងទៅនឹងខែមេសា នៅក្នុងឆ្នាំនេះ។ ខ្ញុំសូមចាប់ផ្តើមអានសារខ្លីទេ ចេញពីសក្ខីកម្មរបស់លោក គឺនៅប្រតិចារឹក នៅម៉ោង ១១:២១ គឺលោកបានឆ្លើយដូចតទៅ ខ្ញុំសូមអាន "ខ្ញុំត្រូវបានគេចាប់ខ្លួន ដោយសារថាកូនស្រីច្បងរបស់ខ្ញុំ នៅកងកុមារ ហើយគាត់រត់ចេញពីកងជាមួយនឹងនាង អៀម យេន ពួកគេបានលួចស្ករចេញពីកង ហើយក៏ត្រូវបានគេចាប់ខ្លួន ហើយវាយដំ និងបង្ខំឱ្យឆ្លើយថា គាត់ហ្នឹងគឺជាទាហានអនុសេនីយ៍ពាក់ស័ក្តិ២ នៅភ្នំពេញ"។ បញ្ចប់ការដងស្រង់។ នេះគឺជាមូលហេតុនៃការចាប់ខ្លួន។ លោកចាំទេ ថាលោកបានឆ្លើយចម្លើយបែបនេះទេ?

[១៣:៣៤:១៩]

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ខ្ញុំឆ្លើយចម្លើយបែបហ្នឹងមែន។

**ស៖** ខ្ញុំ ខ្លាចតែខ្ញុំយល់លោកឆ្លើយនេះមិនច្បាស់ទេ លោកបានឆ្លើយថាកូនស្រីរបស់លោក ពេលនោះ ប្រហែលជាអាយុ៧ឆ្នាំ ត្រូវបានចាប់ខ្លួនដោយសារតែលួចរបស់មួយ គឺលួចស្ករ ហើយកូនស្រីរបស់លោកក៏ត្រូវបានគេបង្ខំឱ្យឆ្លើយសារភាពថាលោកនេះ ថាឪពុករបស់នាង គឺលោកនេះ គឺ"ពាក់ស័ក្តិ២"។ តើកូនស្រីរបស់លោកដែលប្រាប់លោករឿងហ្នឹងទេ? ហើយលោកបានដឹងថាកូនស្រីរបស់លោកត្រូវគេបង្ខំឱ្យឆ្លើយថាលោកពាក់ស័ក្តិ២ហ្នឹង ដឹងពីណាមកដែរ?

**ឆ៖** បាទ ខ្ញុំដឹងហ្នឹងដោយសារថាពួកខ្មែរក្រហមហ្នឹង ពួកឈ្លបហ្នឹងវាវ៉ៃខ្ញុំ។ ដល់វាវ៉ៃប្អូនប្រាំនាក់អ៊ីចឹងទៅវាសួរចម្លើយចុះឡើងៗ វាថាឱ្យខ្ញុំហ្នឹងមិនបាច់លាក់លៀមទេ "ឆ្លើយប្រាប់ឱ្យត្រង់មក ព្រោះកូនអ្អែងហ្នឹងប្រាប់គេដឹងអស់ហើយ ថាអ្អែងនៅភ្នំពេញពាក់ស័ក្តិ២" វាអ៊ីចេះ! ហើយដល់រួចទៅ

ខ្ញុំក៏នឹកឃើញថា កូនមិនគួរធ្វើបាបឪពុកសោះ។ ខ្ញុំនឹកខឹងអ៊ីចឹងដែរ ប៉ុន្តែចិត្តមួយនឹកថា ហេតុតែគ្នានៅក្មេង ហើយគេបង្ខំឲ្យវាឆ្លើយ គឺវា -- ហើយដល់តែខ្ញុំបានរួចហ្នឹង វាៗថាមែន វាចង់រួចខ្លួនវាចេះតែឆ្លើយទៅបាទ។ តែប៉ុណ្ណឹងបាទ សូមជ្រាប។

**ស៖** តើកូនស្រីរបស់លោកមានបានប្រាប់លោកថា ហេតុអ្វីបានជានាងប្រាប់ទៅខាងឈ្លបនុំ៎ងថា លោកពាក់ស័ក្តិ២? ម៉េចក៏មិនប្រាប់ថាពាក់ស័ក្តិដូចជា វរសេនីយ៍ ឬក៏គ្រាន់តែជាកូនទាហានអ៊ីចឹង ឬក៏ពាក់ស័ក្តិ៥នោះ?

[១៣:៣៦:៥១]

**ឆ៖** ការពិតទៅវាៗនិយាយដែរ វាថា គេគំរាមវាហ្នឹងឲ្យឆ្លើយអ៊ីចឹង។ ពួកខ្មែរក្រហមហ្នឹង គេចាប់វាបានអ៊ីចឹងទៅ ព្រោះវាគេចកង វេះកងកុមារហ្នឹង វាដើរកាច់អំពៅកាច់អីគេហ្នឹងហូបហ្នឹង។ គេគំរាមវាឲ្យឆ្លើយអ៊ីចឹងថា "ឆ្លើយថាឪអ្នែងពាក់ស័ក្តិ២ទៅ អង្កាល់នៅភ្នំពេញនុ៎ង អញឲ្យរួចខ្លួន"។ អ៊ីចឹងវាក៏ឆ្លើយតាមតែគេគំរាម គេបង្គាប់ហ្នឹងទៅ ព្រោះក្មេងវាចង់រួចខ្លួន។

**ស៖** តើលោកដឹងថាហេតុអ្វី គឺថាអ្នកសួរចម្លើយលោកនេះ ត្រូវការចម្លើយពីកូនស្រីរបស់លោកដែលមានអាយុតែ៧ឆ្នាំប៉ុណ្ណោះ ដើម្បីចាប់ខ្លួនលោក លោកដឹងទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរបាទ ព្រោះខ្ញុំនៅកងវទេះនេះ ហើយខ្ញុំអត់បានដឹងដែរ។ មូលហេតុដែលគេចាប់ខ្ញុំហ្នឹង មកពីកូនហ្នឹងវាឆ្លើយអ៊ីចឹងបានគេចាប់ហ្នឹងបាទ។

**ស៖** ខ្ញុំសូមត្រឡប់ទៅសំណួរខាងដើមវិញ។ តើក្រោយមកកូនស្រីរបស់លោកមាននិយាយថា ហេតុអ្វីបានជានាងប្រាប់ទៅឈ្លបហ្នឹងថាលោកជាថ្នាក់អនុសេនីយ៍អ៊ីចឹង ម៉េចក៏មិនមែនក៏ជាថ្នាក់ស័ក្តិ២ មិនមែនជាកូនទាហានធម្មតា?

**ឆ៖** ខ្ញុំបានជម្រាបលោកហើយៗ ថាវាៗប្រាប់ខ្ញុំអ៊ីចឹងថា គេគំរាមវាថា ឲ្យឆ្លើយថា ធ្វើទាហានពាក់ស័ក្តិ២អ៊ីចឹងទៅ នៅភ្នំពេញ។ វាៗ គេគំរាមវាឲ្យឆ្លើយអ៊ីចឹង វាមិនមែននឹកឆ្លើយថាអ៊ីចឹងនោះទេ។ ថាឪពុកធ្វើទាហានពាក់ស័ក្តិ២អ៊ីចឹងទេ ប៉ុន្តែអានេះជាពាក្យ ដែលគេបង្គាប់វាឲ្យឆ្លើយអ៊ីចឹង ហើយគេនឹងឲ្យវារួចខ្លួនបាទ។ ឲ្យទៅកងកុមារវិញ។ បាទ សូមជ្រាប។

[១៣:៣៩:៤៤]

**ស៖** តើវាមានន័យថាឈ្លបមានការសង្ស័យមកលើរូបលោករួចមកហើយថា លោកពាក់ស័ក្តិ២ ហើយទើបបានជាសួរការបញ្ជាក់ពីកូនស្ត្រីរបស់លោក អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** វាអត់មានការសង្ស័យអីមកលើខ្ញុំទេ ពីព្រោះថាខ្ញុំប្រាប់វាអ៊ីចឹងថា ខ្ញុំអត់មានដែលធ្វើទាហានធ្វើអីទេ។ អានេះជា វាមូលហេតុដែលដំបូងហ្នឹងគឺវាចាប់កូនខ្ញុំហ្នឹង ព្រោះអាកូនហ្នឹងវានៅកងវាកង គំនិតខូចខ្លួនវាៗឆ្លើយ គេគំរាមវា គេវ៉ៃវា គំរាមឲ្យឆ្លើយអ៊ីចឹងទៅណ៎ា។ បាទ សូមជ្រាបចុះ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងឱកាសមួយចំនួននោះ លោកបានឆ្លើយថាឈ្លបដែលបានចាប់ខ្លួនលោកយកទៅអង្គរកា គឺថាឈ្លបទាំងនោះស្ពាយ អាកា៤៧។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា អ្នកយាមទាំងអស់នោះ ស្ពាយកាំភ្លើងអាកា៤៧ហ្នឹង លោកដឹងដោយរបៀបណា?

**ឆ៖** បាទ ពេលដែលគេដឹកខ្ញុំពីត្រពាំងធំ ទៅដល់ផ្សារអង្គរកាហ្នឹង ឈ្លប តាសេ – ឈ្មោះសេៗហ្នឹងគេមិនដឹងជាឈ្លបភូមិ ឬក៏ឈ្លបឃុំទេ បាទ ហើយគេប្រគល់ឲ្យទៅ តារស់ ហ្នឹង។ គេថា "តារស់ យកអ្នកទោសម្នាក់ទៅ!" ហើយ តារស់ ហ្នឹងគេក៏បានចូលទៅអាកន្លែងការិយាល័យគេហ្នឹង គេទាញអាកាហ្នឹង អាបង់-ងហ្នឹងមួយដើមមក។ បាទ ខ្ញុំឃើញផ្ទាល់ភ្នែកអ៊ីចឹង។

**ស៖** ខ្ញុំយល់ចម្លើយរបស់លោកបែបនេះឯង ប៉ុន្តែខ្ញុំសួរថាតើនៅពេលនោះ លោកដឹងថាកាំភ្លើងដែលលោកបានឃើញហ្នឹង លោកស្គាល់ថាជាកាំភ្លើងអាកា៤៧ បានហ្នឹងដោយរបៀបណា?

**ឆ៖** បាទ ខ្ញុំ វាមិនដឹង ៤៧ ឬ ៤៨ អីដែរទេ ប៉ុនថាអាកាំភ្លើងហ្នឹងវា បង់វា-ង ហើយកាំភ្លើងហ្នឹងខ្ញុំអាចស្គាល់ ព្រោះកាំភ្លើងអាកាហ្នឹងខ្ញុំស្គាល់ ខ្ញុំឃើញផ្ទាល់ភ្នែកខ្ញុំ។ បាទ សូមជ្រាប។

[១៣:៤៣:១៨]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាលោកមើលដឹងនេះ បង់កាំភ្លើងហ្នឹង ជាបង់កាំភ្លើងអាកា៤៧ហ្នឹង ដោយរបៀបណា? សូមលោកបញ្ជាក់។

**ឆ៖** កាំភ្លើង អាកា៤៧ ហ្នឹងវាមានបង់វា-ង មួយបង់ៗហ្នឹង។ ខ្ញុំធ្លាប់ឃើញ ខ្ញុំដឹងថាអាហ្នឹងកាំភ្លើង អាកា៤៧ ហើយ ព្រោះអាហ្នឹង មួយបង់វាហ្នឹង អាចដាក់បាន ៣០គ្រាប់។ ខ្ញុំដឹងអ៊ីចឹងទៀត។ ប៉ុន្តែនៅក្នុងបង់ហ្នឹង មានប៉ុន្មានគ្រាប់ខ្ញុំអត់ដឹងទេបាទ។ ខ្ញុំគ្រាន់តែថាខ្ញុំស្គាល់ អារឿងកាំភ្លើងហ្នឹង។

**ស៖** តើលោកដឹងថាក្នុងកាំភ្លើងអាកា៤៧ហ្នឹង ក្នុងមួយបង់មានប៉ុន្មានគ្រាប់ហ្នឹង លោកដឹងពីអ្នកណា? លោកដឹងដោយរបៀបណា?

**ឆ៖** ព្រោះអាកាំភ្លើងហ្នឹង ខ្ញុំវាធ្លាប់ដែលឃើញ ព្រោះកាលខ្ញុំនៅមុនថ្ងៃ១៧ ហ្នឹង ខ្ញុំនៅភ្នំពេញហ្នឹង ខ្ញុំធ្លាប់ឃើញ ខ្ញុំធ្លាប់ស្គាល់ដែរហ្នឹង ហើយខ្ញុំស្គាល់តាម ដូចថា ខ្ញុំនៅជំរំអូរបែកក្អមហ្នឹង ខ្ញុំស្គាល់ពួកទាហានជាង ទាហានពួកសូនីអីគេហ្នឹងនៅនុំង ហើយខ្ញុំស្គាល់តាមហ្នឹង។ ហើយខ្ញុំគ្រាន់តែឃើញមក

ខ្ញុំដឹងស្គាល់ថា អ៊ូ! កាំភ្លើងៗបង់-ងហ្នឹង អាហ្នឹងកាំភ្លើងអាកា៤៧ហ្នឹង។

**ស៖** លោកសាក្សី អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានសួរលោក គឺឯកសារ E319/12.3.8, សំណួរទី៦ សំណួរអំពីទាហានវៀតណាម ដែលពេលនោះគេហៅថា "ពួកម៉ែហ្វក"។ បាទ សូមដកស្រង់ ឬក៏គេថាជា គឺពួកស្នែកស្លាប់ ដែលមានពាក់ស្លាកសញ្ញាក្បាលខ្មោច។ សូមលោកជម្រាបជូនអង្គជំនុំជម្រះ លោកដឹងអង្គភាពទាហាននេះ ហៅថា "ក្រុមម៉ែហ្វក ឬស្នែកស្លាប់" លោកដឹងដោយរបៀបណា?

[១៣:៤៦:៣៣]

**ឆ៖** បាទ ខ្ញុំបាទហ្នឹងវានៅតាមព្រំហ្នឹង អ៊ីចឹងទៅ ខ្ញុំឃើញពួកដែលថា រដ្ឋប្រហារឆ្នាំ៧០ ដែលឯកឧត្តមសេនាប្រមុខ លន់ នល់ នេះ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ហ្នឹង។ ហើយអ៊ីចឹងទាហានក្បាលខ្មោចហ្នឹង អាពួកអាម៉ែហ្វកហ្នឹង វា -- ខ្ញុំមើល ខ្ញុំនៅហ្នឹង នៅភូមិទួលពង្រហ្នឹង ខ្ញុំឃើញវាឡើងមកគ្នាវាច្រើនណាស់។ អ៊ីចឹង ខ្ញុំស្គាល់តាមរយៈហ្នឹង។ បាទ សូមជ្រាប។

**ស៖** នៅក្នុង -- នៅកំណត់ហេតុដែលគឺត្រង់សំណួរលេខ៤៤ លោកបានឆ្លើយថា "ខ្មែរក្រោមនៅភូមិស្វាយវល្លិ គឺជានាយទាហាន"។ ខ្ញុំសូមអានសំណួរពេញតែម្តង ដើម្បីឲ្យលោកឆ្លើយ។ "សួរ៖ នៅពេលដែលលោកនៅភូមិស្វាយវល្លិ តើលោកដឹងថាមានគេសម្លាប់មនុស្សទេ? ចម្លើយរបស់លោកឆ្លើយថា៖ បាទ មានការសម្លាប់មនុស្ស។ ខ្មែរក្រោមសុទ្ធតែធ្វើទាហាន ហើយមានពាក់ស័ក្តិ។ នៅភូមិស្វាយវល្លិ ខ្មែរក្រហមបានឃោសនាថាអ្នកណាមានស័ក្តិអ្វី កាលនៅជំនាន់លន់ នល់ គេនឹងឲ្យទៅកាន់មុខតំណែងក្នុងកងទ័ព ហើយបន្ទាប់មកត្រូវបានគេវៃ -- ទៅវៃជាមួយយួន តែការពិតទៅពួកគេយកទៅសម្លាប់ចោល"។ ដែលលោកនិយាយថា ដែលក្នុងចម្លើយនោះ ខ្ញុំសូមសង្កត់ធ្ងន់ទៅលើថា ខ្មែរក្រោមគឺធ្វើជាទាហាន ហើយមានបណ្តាស័ក្តិទៀត។ សូមលោកជម្រាបជូនអង្គជំនុំជម្រះ លោកដឹងថាពួកគេមានបណ្តាស័ក្តិដោយរបៀបណា?

[១៣:៤៨:៤៥]

**ឆ៖** បាទ ពេលដែលពួកយើងខ្ញុំ គេជម្លៀសទៅដល់នុ៎ង អ៊ីចឹងបានបួនប្រាំថ្ងៃ ឬក៏១០ថ្ងៃអ៊ីចឹង ហើយមេភូមិអីគេឈ្មោះ តាស៊ុម ហ្នឹង គេប្រជុំប្រាប់ថា -- ប្រកាសប្រាប់ថា "សូមបងប្អូនខ្មែរទាំងអស់អ្នកណាមានមុខងារ ឬក៏ឋានៈបណ្តាស័ក្តិដូចជា កងទ័ពធ្វើមានបណ្តាស័ក្តិអីហ្នឹង ឆ្លើយប្រាប់គេត្រង់មកឲ្យគេ -- ហើយគេនឹងឲ្យទៅកាន់មុខតំណែងនោះវិញ។ បើអ្នកណាពាក់ស័ក្តិ១ ថាស័ក្តិ១ ពាក់ស័ក្តិ២ ថា

ស័ក្តិ២ ស័ក្តិ៣ថាស័ក្តិ៣ ឬក៏គ្រូបង្រៀន គេនឹងយកទៅឲ្យ -- បើគ្រូគេយកឲ្យបង្រៀនក្មេង ហើយបើអ្នកមានបណ្ដាស័ក្តិហ្នឹង គេនឹងឲ្យទៅកាន់កងទ័ពនៅសមរភូមិមុខដើម្បីវៃជាមួយយួន"។ គេនិយាយអ៊ីចឹង។ ហើយដល់គេប្រកាសប្រាប់អ៊ីចឹង អ្នកខ្លះដូចថាវា អានេះជាល្បិច ជានយោបាយរបស់គេ គេថាអ៊ីចឹង តែការពិតទៅវាមិនមែនដូចវាថាឯណា មិនដូចពួកអស់ហ្នឹងថាឯណា វាជាល្បិចរបស់វា ដើម្បីវាចង់ដឹង ដូចថាវា នរណាមានពាក់ស័ក្តិពាក់អីវាកត់ទុក ចំណាំទុក យក វាចងកំហឹងជាមួយពួកហ្នឹង។ បាទ សូមជ្រាប។

**ស៖** សំណួរខ្ញុំបានស្ដាប់ចម្លើយរបស់លោកយ៉ាងយកចិត្តទុកដាក់ ប៉ុន្តែខ្ញុំមិនឮសួរថាលោកពន្យល់ខ្ញុំថា ហេតុអ្វីបានជាប្រជាជនខ្មែរក្រោមធ្វើជាទាហាន ហើយមានបណ្ដាស័ក្តិទៀត? ខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកឆ្លើយថាខ្មែរក្រោមហ្នឹងធ្វើទាហាន ហើយមានបណ្ដាស័ក្តិទៀត។ លោកដឹងដោយរបៀបណា?

**ឆ៖** បាទ នែ៎ ខ្ញុំបាទហ្នឹងដឹងដោយសារថា ពួកខ្មែរក្រោមហ្នឹង ពួកហ្នឹងគេៗប្រាប់ គេប្រជុំអ៊ីចឹងដល់រួចទៅគេប្រាប់ៗ ចុះបើខ្ញុំរស់នៅជាមួយគេ គេថា "ខ្ញុំនៅនេះណាអី ខ្មែរកម្ពុជាក្រោមអ៊ីចឹង ហើយខ្ញុំធ្វើទាហាននៅកំពង់សោម ហើយគេបានជម្លៀសចេញមកអ៊ីចឹងមក" មកនៅជាមួយខ្ញុំហ្នឹង ពួកហ្នឹងគេពួកហ្នឹងវានិយាយប្រាប់ខ្ញុំអ៊ីចឹងណា បានខ្ញុំហ្នឹងដឹងតាមរយៈហ្នឹង។ ហើយដល់ខ្ញុំចេះតែពិនិត្យតាមដានមើលអ្នកដែលឆ្លើយប្រាប់ពួកខ្មែរក្រហមហ្នឹង ឆ្លើយប្រាប់ថាអ៊ីចឹង។ ដល់រួចហើយស្រាប់តែពីរបីថ្ងៃក្រោយមកបាត់ខ្លួនអស់រលីងទៅ។ បាទ ខ្ញុំសន្និដ្ឋានថាវាយកទៅហ្នឹង វាគ្មានយកទៅណាទេ វាបាត់ខ្លួនអស់ហើយ មានតែយកទៅសម្លាប់ចោល។ បាទ សូមជ្រាប។

[១៣:៥២:៥៥]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅការសួរមកកាន់រូបលោកពាក់ព័ន្ធទៅនឹងអង្គរកា។ លោកបានឆ្លើយថាលោកត្រូវបានគេវាយដំសួរចម្លើយ សួរម្ដងហើយ ម្ដងទៀតដែលថា តើលោកពិតជាពាក់ស័ក្តិ២មែនឬក៏អត់នៅក្នុងជួរទាហានលន់នល់។ ហើយលោកបានជម្រាបអង្គជំនុំជម្រះថាលោកគ្មានទោសអីទេកាលនោះនោះ គ្មានទោសពៃរ៍អីទេ។ តើលោកនៅចាំទេថា ការសួរចម្លើយរបស់លោកនោះ គេមានទទួលយក ឬក៏ថាជឿលោកថាលោកមិនមែនជានាយទាហានលន់នល់ទេ គេជឿលោកទេ?

**ឆ៖** បាទ ប្រហែលជាវានៅស្ទាក់ស្ទើរ បានវាទុកខ្ញុំនៅក្នុងគុកហ្នឹង បើសិនជាវាជឿខ្ញុំ ថាខ្ញុំជាកម្មកររកបានលក់ឧសលក់អីបានបន្តិចបន្តួចគ្រាន់ចិញ្ចឹមប្រពន្ធកូនហ្នឹង ហីបែបវាមិនទាន់បានព័ត៌មាន

ច្បាស់អីយ៉ាងម៉េច បានវាចេះតែទុកខ្ញុំឲ្យនៅរស់ទៅ។ បាទ សូមជ្រាប។

[១៣:៥៤:២៤]

**ស៖** តើលោកដឹងដោយរបៀបនោះ ថាតើគេដឹងពីប្រវត្តិលោក គេជឿលោក ឬក៏យ៉ាងម៉េច បានជាៗគេទុកលោកហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទហ្នឹងមិនដឹងថាគេជឿ ឬមិនជឿខ្ញុំអត់ដឹងទេ បាទ ព្រោះខ្ញុំមិនអាចសន្និដ្ឋានបានទេ ថាគេជឿ ឬមិនជឿហ្នឹង ខ្ញុំមិនដឹង ប៉ុន្តែថាវាៗ -- ខ្ញុំវារងការធ្វើទារុណកម្ម ឬក៏បានឆ្លងកាត់ហ្នឹងពិតប្រាកដមែន។ បាទ សូមជ្រាប។

**ស៖** តើលោកត្រូវបានគេសួរចម្លើយប៉ុន្មានដងដែរ លោកនៅចាំទេ?

**ឆ៖** គេសួរចម្លើយខ្ញុំហ្នឹង មុនដំបូងបង្អស់ហ្នឹង ប្រធានឈ្លបគេហ្នឹង កាលពេលគេចាប់ភ្លាមៗហ្នឹង គេសួរចម្លើយពេលគេធ្វើទារុណកម្មខ្ញុំហ្នឹង។ គេសួរចម្លើយម្តង។ អ៊ីចឹងទៅ ដល់តែពេលទៅនៅក្នុងគុកគេហ្នឹង គេសួរចម្លើយខ្ញុំបាទម្តងទៀត។ បាទ សូមជ្រាប។

**ស៖** លោកនៅចាំថា លោកឆ្លើយចំពោះឈ្លបហ្នឹងយ៉ាងដូចម្តេចដែរ បានគេជឿលោក ថាលោកមិនមែនជានាយទាហាន លន់ នល់?

**ឆ៖** បាទ អារឿងគេជឿថា ខ្ញុំមិនមែនជានាយទាហាន លន់ នល់ ឬគេមិនៗជឿ ឬមិនជឿនោះក៏ខ្ញុំមិនអាចដឹងក្នុងចិត្តគេដែរ ពីព្រោះគេធ្វើទារុណកម្មខ្ញុំ គេវ៉ៃខ្ញុំ ប្អូនប្រាំនាក់ហ្នឹង គឺថាហត់ម្នាក់វ៉ៃអ៊ីចឹងទៅ ម្នាក់ចូលមកទៀតនៅតែសួរអ៊ីចឹង។ គេថា "បើអ្អែងធ្វើទាហានលន់ នល់ ពិតប្រាកដមែន ឆ្លើយឲ្យត្រង់មក អញលែងអ្អែងឲ្យទៅកងវិញ" គេថាអ៊ីចឹង ហើយវាចម្លើយខ្ញុំមិនដឹងឆ្លើយថាម៉េច បើខ្ញុំមិនបានធ្វើមែន។ បាទ សូមជ្រាប។

[១៣:៥៧:៤០]

**ស៖** តើលោកមានចាំទេ នៅពេលដែលគេសួរលោកហ្នឹង តើធ្វើម៉េចបានជាអ្នកសួរចម្លើយលោកហ្នឹង លោកធ្វើយ៉ាងម៉េច បានឲ្យអ្នកសួរចម្លើយលោកជឿថាលោកមិនមែនជានាយទាហានលន់ នល់ ?

**ឆ៖** បាទ ខ្ញុំដូចជម្រាបរួចមកហើយ ខ្ញុំថា រឿងគេជឿឬមិនជឿ ខ្ញុំមិនអាចសន្និដ្ឋានបានទេ ក៏ប៉ុន្តែគេវាយសួរចម្លើយហ្នឹង គេធ្វើទារុណកម្មហ្នឹង។ វាអត់មានចម្លើយសោះ ថាខ្ញុំធ្វើទាហានហ្នឹង ហើយបើអ៊ីចឹង ចម្លើយថានៅតែកម្មកររកស៊ីលក់ឧសលក់អីបន្តិចបន្តួច។ អ៊ីចឹងបានគេឲ្យរទេះសេះហ្នឹង

ដឹកយកទៅដាក់គុកហ្នឹង។ បាទ សូមជ្រាប។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីគួរបន្តសំណួរផ្សេងទៀតទៅ ប្រសិនបើមានសំណួរ ហើយបើថាអស់ហើយ គប្បីបញ្ចប់ត្រឹមហ្នឹងទៅ ជៀសវាងសំណួរច្រំដែលៗវិលទៅវិលមក សួររឿងដដែលៗ ចុះឡើងៗ ដប់សំណួរ ហើយនៅតែដដែលរបៀបនេះ។ បើលោកគ្មានសំណួរទេ យើងនឹងប្រគល់វេទិកាទៅឲ្យក្រុមមេធាវីការពារក្តីមួយទៀត។

[១៣:៥៩:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សំណួរហ្នឹងគឺតើកម្មាភិបាលខ្មែរក្រហមជឿគាត់ថាគាត់មិនមែនជានាយទាហាន លន់ នល់ ឬក៏អត់ ហើយតើវាមានផលវិបាកយ៉ាងម៉េច ដោយសារថាមានការចោទប្រកាន់ ហើយសួរចម្លើយមកលើរូបគាត់។ ស្តាប់ទៅហាក់បីដូចជាច្រំដែលៗ ក៏ប៉ុន្តែវាជាសំណួរចូលទៅខ្លឹមសារចំណុចសំខាន់នៃការសួរចម្លើយ ពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់ខ្មែរក្រហម ក្នុងការបោសសម្អាតនោះ។ ដូច្នេះ ខ្ញុំចង់ស្វែងរកការពិត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សមល្មមនឹងអាចយល់បានលើបញ្ហាប្រធានបទដែលលោកសួរហ្នឹង ហើយ បើលោកគ្មានសំណួរផ្សេងទៀតទេ អង្គជំនុំជម្រះបញ្ឈប់លោកមិនឲ្យសួរទៀតទេ ពាក់ព័ន្ធនឹងបរិបទនេះនៃការសួរចម្លើយនេះ ពីព្រោះគាត់បានឆ្លើយច្បាស់លាស់ហើយ គាត់មិនដឹងទេ។ រឿងគេដឹងឬក៏មិនដឹង គាត់មិនធ្វើសេចក្តីសន្និដ្ឋានទេ ហើយលោកមេធាវីមិនគប្បីសួររហូតដល់ឲ្យគោលដៅនៃការឆ្លើយតបហ្នឹង ចង់ឲ្យទទួលបានចម្លើយដូចបំណងរបស់លោកនោះទេ។ នីតិវិធីមិនតម្រូវឲ្យធ្វើដូច្នេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាថ្វីទេលោកប្រធាន ខ្ញុំសូមចូលប្រធានបទផ្សេង។

[១៤:០០:៥២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ក្រោយមកនោះ នៅក្នុងឆ្នាំ១៩៧៩ លោកដឹងទេ ហេតុម៉េចបានជាគេបញ្ជូនលោកទៅអង្គរកា មិនបញ្ជូនទៅឯក្រាំងតាចាន់វិញនោះ?

**លោក ចាន់ ធីម៖**

**ឆ៖** មិនអាចដឹងទេបាទ សូមជម្រាបចុះ ខ្ញុំមិនអាចដឹងទេ។

**ស៖** លោកក៏បាននិយាយពីរបីដងមកហើយ អំពីអ្នកទោសដែលថាអាចគេនាំខ្លួនយកទៅភ្នំដំរីរមៀល។ សូមលោកជម្រាបជូនអង្គជំនុំជម្រះ ហេតុអីបានលោកគិតថាអ្នកទោសនៅពេលនោះ អាចគេនាំទៅកាន់ទីតាំងជាក់លាក់នេះ ក្រៅពីចម្លើយរបស់លោកថាលោកបានជីករណ្ដៅអីយ៉ាងដូច្នេះ? សូមលោកបញ្ជាក់មើលថាហេតុអីបានជាអ្នកទោសដទៃត្រូវគេនាំខ្លួនទៅភ្នំដំរីរមៀល?

**ឆ៖** បាទ ខ្ញុំបាទក៏មិនបានដឹងដែរ។ ដូចខ្ញុំបានជម្រាបពីមុនមកហើយ ថាខ្ញុំបាទហ្នឹងនៅជាប់ខ្នោះជើងទាំងពីរនៅក្នុងគុកហ្នឹង។ គ្រាន់តែថាខ្ញុំបាទហ្នឹងលបមើលតាមប្រឡោះ អាដែងដូចថា ជញ្ជាំងក្តារអីចឹង វាមានប្រហោងអីចឹង ហើយគេយកទៅនេះ ខ្ញុំមិនអាចសន្និដ្ឋានថាគេយកទៅវៃចោលនៅភ្នំដំរីរមៀល ឬក៏គេយកទៅទីកន្លែងណាផ្សេងទៀតទេ។ ខ្ញុំគ្រាន់តែបានឃើញ គេចងហើយ គេបណ្ដើរទៅសំដៅភ្នំដំរីរមៀលហ្នឹងទៅបាទ។ ត្រង់គេយកទៅកន្លែងណាទៀត ខ្ញុំម៉េចនឹងដឹង ព្រោះខ្ញុំនៅជាប់ខ្នោះជើងនៅ រកតែប្រែខ្លួនមិនបានផង ដេកបានតែផ្ងារហ្នឹង។ បាទ សូមជម្រាបចុះ។

[១៤:០៣:០៨]

**ស៖** តើពីអង្គរកាមានចម្ងាយប៉ុន្មានគីឡូម៉ែត្រពីភ្នំដំរីរមៀល?

**ឆ៖** បាទ អារឿងចម្ងាយប៉ុន្មានគីឡូ ខ្ញុំមិនអាចសន្និដ្ឋានដឹងទេ ជាការស្មានៗទេ ខ្ញុំប្រហែលជា -- អ៊ូ! ខ្ទង់ -- ប៉ុនមើលភ្នំហ្នឹងឃើញ ខ្ញុំស្មានទៅ ប្រហែលជាខ្ទង់៧គីឡូ ឬក៏អីហ្នឹង ៦-៧គីឡូហ្នឹងពីអង្គរកាទៅ។ បាទ សូមជម្រាប។

**ស៖** សំណួរបន្ថែមទៀតទៅនឹងអ្នកទោសដែលជាប់ជាមួយលោក។ បើខ្ញុំយល់មិនច្រឡំទេលោកមិនបានដឹងច្រើនរឿងរ៉ាវច្រើនទេ ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនអ្នកទោសដែលគេយកមកឃុំជាមួយនឹងលោកនោះ។ តើលោកដែលនិយាយជាមួយអ្នកទោសដទៃទៀត សួរគ្នាអំពីមូលហេតុនៃការចាប់ខ្លួនដូចជានៅពេលយប់ ឬនៅពេលថ្ងៃ ដែលធ្វើការជាមួយគ្នា?

**ឆ៖** បាទ ខ្ញុំបាទអត់បាននិយាយ ឬក៏ជំនុំគ្នាអីទេ។ អត់ទេ អត់ប៉ានិយាយស្អីទាល់តែសោះព្រោះអាហ្នឹង វាមិនអាចនិយាយបានទេ កាលជំនាន់នោះ ហើយយើងមិនប៉ាននិយាយទៀត។ ខ្ញុំស្គាល់គ្រូកាន់ម្នាក់ហ្នឹង ដោយសារថាគាត់ហ្នឹង គាត់ថាឃ្វាលគោ ឃ្វាលអីចឹង គាត់ ដល់រួចទៅ គោហ្នឹងវាអាម៉េច គាត់ចោលអីចឹងទៅ វាត្រូវគោហ្នឹង កូនគោហ្នឹង។ ហើយដល់រួចបានគេ វាដូចថាបាក់ជើង បាក់ដៃ

អ៊ីចឹងទៅ បាក់ជើងគោហ្នឹងណា៎។ រួចទៅ គេចាប់គាត់យកមកដាក់គុកជាមួយខ្ញុំដែរ។

**ស៖** តើលោកមានដឹងថា អ្នកទោសដែលជាប់ជាមួយនោះត្រូវបានគេចោទប្រកាន់ថា ជាមន្ត្រី ជានាយទាហាន ឬក៏ជាកូនទាហានលន់ នល់ ដែរទេ?

**ឆ៖** បាទ ខ្ញុំបាទអត់បានដឹងទេ អត់បានជំនុំគ្នា ហើយក៏អត់បានដឹងដែរ។

[១៤:០៦:៤១]

**ស៖** ខ្ញុំមានសំណួរមួយទៀត លោកបាននិយាយពីព្រឹកមិញនេះ លោកបាននិយាយថា លោកនិយាយអំពីពាក្យស្លោក ដែលលោកបានស្តាប់ឮ គឺថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" នេះគឺជាពាក្យស្លោកដែលលោកបាននិយាយ។ តើលោកចាំទេថាអ្នកណាជាអ្នកនិយាយពាក្យនេះ?

**ឆ៖** បាទ អាពាក្យស្លោកហ្នឹង វានិយាយជាទូទៅហើយ មិនមែនតែខ្ញុំទេ ព្រោះខ្ញុំឮផ្ទាល់តែម្តង ពួកមូលដ្ឋានហ្នឹងអ្នកនិយាយ ពួកម៉េង ពួកពូឈឿង អីគាត់និយាយ។ គាត់ថា "បើទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ" ដូចជាអ្នកពិការ ដូចជា ដូចថាគ្នាពិការធ្វើអីមិនបាន ហើយអ៊ីចឹងគេនិយាយអ៊ីចឹងទៅ គេថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ បាទ សូមជ្រាបចុះ។

**ស៖** អ្វីដែលខ្ញុំចង់សួរលោក គឺថាតើលោកចាំទេ អ្នកណាជាអ្នកនិយាយពាក្យនេះ គឺថានៅពេលដែលលោកនៅអង្គរកា គឺអ្នកណាជាអ្នកនិយាយ? ខ្ញុំចង់ដឹងឲ្យបានច្បាស់ថានៅកន្លែងឃុំហ្នឹង តើអ្នកណាអ្នកនិយាយពាក្យនេះ?

**ឆ៖** ខ្ញុំប្រាប់ឲ្យចំចុះថា លោកម៉េង ហ្នឹងហើយ មេគុកហ្នឹង មេមន្ទីរសន្តិសុខអង្គរកាហ្នឹងអ្នកនិយាយថា "ទុកមិនចំណេញ ដកចេញក៏មិនខាតដែរ"។ បាទ សូមជ្រាប។

[១៤:០៨:៤៥]

**ស៖** តើលោកធ្លាប់ឮគេនិយាយ ឬក៏គេផ្សាយពាក្យស្លោកនេះតាមវិទ្យុដែរឬទេ?

**ឆ៖** កាលជំនាន់ហ្នឹង ខ្ញុំបាទហ្នឹង អត់ទេ ងងឹតដូចយប់អ៊ីចឹង មិនដែលនឹងមានឮស្អី ស្តាប់វិទ្យុ ស្តាប់អីមិនដែលឮទេ។ បាទ សូមជ្រាប។

**ស៖** តើលោកធ្លាប់ឮឈ្មោះ "ទង់បដិវត្ត" ដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទធ្លាប់ឮដែរ រឿងទង់បដិវត្តហ្នឹង ខ្ញុំគ្រាន់តែឮថា "ទង់បដិវត្ត"ហ្នឹង ខ្ញុំធ្លាប់ឮ។ បាទ សូមជ្រាប។

**ស៖** តើលោកធ្លាប់អាន "ទង់បដិវត្ត" ដែរឬទេ?

**ឆ៖** ខ្ញុំបាទអត់ធ្លាប់អានទេ តែគ្រាន់តែថាធ្លាប់បានឮអ៊ីចឹងមែន។ បាទ សូមជ្រាប។

**ស៖** តើធ្លាប់ -- អ្នកដែលគេធ្លាប់អានទស្សនាវដ្ដីទង់បដិវត្តហ្នឹង គេធ្លាប់និយាយប្រាប់លោកថា និយាយប្រាប់លោកអំពីពាក្យថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ហ្នឹង។ តើលោកដឹងទេថា នៅក្នុងទស្សនាវដ្ដីទង់បដិវត្តហ្នឹងមានពាក្យស្លោកហ្នឹងដែរឬអត់?

**ឆ៖** ខ្ញុំអត់បានដឹងដែរ។ ខ្ញុំមិនអានទស្សនាវដ្ដីហ្នឹងផង ព្រោះខ្ញុំមិនដែលបានអានទេបាទ ហើយ ខ្ញុំមិនដែលបានដឹងដែរ គ្រាន់តែថាធ្លាប់បានឮ។ បាទ សូមជ្រាប។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំចង់សួរលោកថា តើលោកចាំអំពីម៉ៃហ្វកហ្នឹងដែរឬទេ?

**ឆ៖** ទេ អារឿងម៉ៃហ្វកហ្នឹង ខ្ញុំហ្នឹង ខ្ញុំបាននិយាយហើយថា ខ្ញុំចាំព្រោះគេមានសញ្ញាក្បាល ខ្មោចគេហ្នឹង គេគូសនៅនឹងស្មាហ្នឹង អាសញ្ញាក្បាលខ្មោចហ្នឹង ប៉ុន្តែខ្ញុំឮតែគេថាដែរហ្នឹង។ ម៉ៃហ្វកៗ ហ្នឹង គេថាស្អែកស្លាប់ ថ្ងៃស្អែកស្លាប់ៗហ្នឹង។ បាទ ទាហានវៀតណាមហ្នឹងវាឡើងមកហ្នឹង។ បាទ សូមជ្រាប។

[១៤:១២:០៨]

**ស៖** តើលោកធ្លាប់ធ្វើជាទាហានម៉ៃហ្វកហ្នឹង ឬក៏ធ្លាប់ចូលរួមជាមួយនឹងម៉ៃហ្វកហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទមិនដែលបានធ្វើទាហានម៉ៃហ្វក ឬក៏ធ្លាប់បានចូលរួមអី ខ្ញុំបាទមិនដែលទេ បាទ។ គ្រាន់តែបានឃើញ។ សូមជ្រាប។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។ សូមអញ្ជើញបាទ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។ ខ្ញុំមានសំណួរតិចតួចទេ សម្រាប់ ដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជាដំបូងនេះ ខ្ញុំចង់សួរបញ្ជាក់លោកទៅលើឯកសារ E3/5034 ដែលជាទម្រង់បែបបទ

ព័ត៌មានអំពីជនរងគ្រោះរបស់លោក។ ហើយនៅក្នុងឯកសារនេះគឺមានឈ្មោះ ចៅ នី ជាសាក្សីម្នាក់ នៅក្នុងទម្រង់នៃការបំពេញនេះ។ ខ្ញុំចង់សួរលោកថា តើលោកស្គាល់ ចៅ នី នេះពីមុននឹងការបំពេញទម្រង់បែបបទនេះដែរទេ ឬក៏លោកស្គាល់នៅពេលណា លោកអាចបញ្ជាក់កាលបរិច្ឆេទបានទេ? សូមអញ្ជើញ!

**លោក ថាន់ ធីម៖**

**ឆ៖** បាទ ខ្ញុំបាទហ្នឹងមិនដែលស្គាល់ ចៅ នី ហ្នឹងពីមុនមកនោះទេ។ ទើបតែមានថ្មីមួយដែលយើងថា មានបង្កើតនូវតុលាការកូនកាត់នៅកម្ពុជាយើងនេះ ហើយខ្ញុំមានថ្ងៃមួយនុ៎ង ឃើញ ចៅ នី ហ្នឹង គាត់ទៅដល់ៗហ្នឹងមិនទៅដល់ផ្ទះខ្ញុំទេ ទៅដល់ផ្ទះ អៀម យេន ហ្នឹង។ នាង អៀម យេន ហ្នឹងក៏ប្រាប់ថា ខ្ញុំហ្នឹងធ្លាប់ទទួលទារុណកម្ម ធ្លាប់ជាប់គុកអីចឹង។ ដល់ ចៅ នី ហ្នឹងគាត់ក៏ប្រើគេឲ្យយកម៉ូតូទៅដឹកខ្ញុំមកពីផ្ទះខ្ញុំមកបាទ មកជួបគាត់ ហើយគាត់ប្រាប់ថាធ្លាប់រងទទួលទារុណកម្ម ធ្លាប់ជាប់គុកនៅកន្លែងណាៗហ្នឹង ឲ្យសរសេរជាពាក្យបណ្ដឹងមកយើងឥឡូវវាមានកើតនូវតុលាការនៅកម្ពុជាយើងហើយ ឲ្យខ្ញុំហ្នឹងធ្វើពាក្យ ដាក់ពាក្យដាក់អីមក គាត់អ្នកយកពាក្យហ្នឹងមកដាក់ឲ្យខ្ញុំ។ ខ្ញុំហ្នឹងគ្រាន់តែថា មិនដឹងថាកន្លែងទទួលពាក្យនុ៎ងនៅកន្លែងណាទេ ក៏ប៉ុន្តែ ចៅ នី ហ្នឹងគាត់ឲ្យខ្ញុំហ្នឹងសរសេរជាពាក្យមួយ តាមដែលរឿង ដែលយើងបានឆ្លងកាត់ ធ្លាប់បានដឹងច្បាស់លាស់ ហើយគាត់ជាអ្នកយកមកដាក់ឲ្យ។ បាទ សូមជ្រាប។

[១៤:១៥:៥១]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា ពាក្យហ្នឹងលោកសរសេរដោយខ្លួនឯងផ្ទាល់ ឬក៏មានជំនួយអ្នកណាជួយសរសេរលោកដែរ?

**ឆ៖** បាទ ពាក្យរបស់ខ្ញុំបាទនេះ គឺខ្ញុំសរសេរផ្ទាល់ដៃខ្លួនឯងតែម្ដងបាទ គឺសរសេរផ្ទាល់ដៃខ្លួនឯងតែម្ដង ខ្ញុំសរសេរនៅនឹងផ្ទះខ្ញុំ សរសេរតែម្នាក់ឯង គ្មានជំនួយពីណាពីណាមក អត់ទេ។ គ្រាន់តែថា ចៅ នី ហ្នឹងគាត់អ្នកដឹងថា កន្លែងដាក់ពាក្យហ្នឹងនៅត្រង់ណាត្រង់ណាអី នៅត្រង់ណាៗហ្នឹង គាត់យកមកដាក់ឲ្យខ្ញុំបាទ។ ហើយខ្ញុំសរសេរម្នាក់ឯង អត់មានអ្នកណាជួយស្អីទេ សរសេរផ្ទាល់ដៃខ្លួនឯងតែម្ដង។ បាទ សូមជ្រាប។

**ស៖** បាទ សូមអរគុណ។ អីចឹងបានន័យថា ក្នុងទម្រង់បំពេញបែបបទរបស់លោកនេះ គឺជាសំណេររបស់លោកផ្ទាល់។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E319/12.3.8 ត្រង់សំណួរចម្លើយលេខ៩៧ និងលេខ៩៨ ខ្ញុំសូមអានជូន ដកស្រង់ "សំណួរ៖ តើលោកជាអ្នកបំពេញទម្រង់បែបបទព័ត៌មានបន្ថែមនេះមែនទេ? ចម្លើយ៖ គឺទេ មិនមែនទេ។ សំណួរតទៀត "មានស្នាមមេដៃរបស់លោកនៅលើតម្រង់នេះ តើលោកដឹងថា នរណាជាអ្នកបំពេញទម្រង់បែបបទព័ត៌មានបន្ថែមនេះទេ? ចម្លើយ៩៨៖ ខ្ញុំពុំបានបំពេញទម្រង់បែបបទព័ត៌មានបន្ថែមដោយខ្លួនឯងទេ ហើយខ្ញុំក៏មិនចាំថា អ្នកណាជាអ្នកបំពេញឲ្យខ្ញុំដែរ។ ប៉ុន្តែឈ្មោះ ចៅ នី ជាអ្នកជួយយកទម្រង់បែបបទនេះទៅដាក់ឲ្យខ្ញុំ"។ ខ្ញុំចង់សួរថាតើលោកចាំពីទម្រង់ដែលលោកបំពេញហ្នឹងមានពីរទម្រង់ផ្សេងគ្នាទេ?

[១៤:១៨:៥៩]

**ឆ៖** វាអារឿងពាក្យហ្នឹងវាយូរពេកហើយ ខ្ញុំក៏វាមានការភ្លេចភ្លាំងមិនបានដូចថា វា១ពីរទម្រង់មានពីរទម្រង់មែន បាទ ពាក្យរបស់ខ្ញុំហ្នឹង។ ប៉ុន្តែអារឿងថា ខ្ញុំឆ្លើយថាទេហ្នឹង មកអំពីអ៊ីចេះ មកអំពីទម្រង់មួយនោះ ខ្ញុំមើលទៅមិនមែនជាអក្សររបស់ខ្ញុំទេ។ ហើយមានដាក់ថា ខ្ញុំហ្នឹងបានឃើញគេយកប្រជាជនវៀតណាមប៉ុន្មាននាក់ទៅសម្លាប់នោះ។ ហើយបានជាខ្ញុំឆ្លើយថា ទេ អាទម្រង់ហ្នឹងខ្ញុំអត់បានបំពេញទេ អត់មានបំពេញបន្ថែមទេ អាហ្នឹង។ បាទ សូមជ្រាប។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារដដែលគឺ E319/12.3.8 ត្រង់សំណួរចម្លើយលេខ៥៤។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ម្តងទៀត ចុច 8 ឬ ចុច 18?

**លោក គង់ សំអុន៖**

ចុច 8 លោកប្រធាន។

**ស៖** បាទ ត្រង់សំណួរចម្លើយលេខ៥៤។ ខ្ញុំសូមអានជូន "សំណួរ៖ តើពួកខ្មែរក្រហមយកខ្មែរក្រោមដែលធ្លាប់ធ្វើការនៅក្នុងរបប លន់នល់ យកទៅសម្លាប់ ចុះពួកគេយកខ្មែរក្រោមដែលពុំធ្វើការនៅក្នុងរបបលន់នល់ទៅសម្លាប់ដែរឬទេ បើសិនជាគេដឹងថាជាខ្មែរក្រោម? ចម្លើយ ៥៤៖ តាមខ្ញុំដឹង ខ្មែរក្រោមដែលមិនបានធ្វើការក្នុងរបបលន់នល់ គេមិនស្លាប់ទេ។ ម្យ៉ាងវិញទៀត ពិបាកនឹងកំណត់ដែរថាជាខ្មែរក្រោម"។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ជូនអង្គជំនុំជម្រះថា តើលោកដឹងព័ត៌មានថា អ្នកដែល--

បុគ្គលដែលមានអត្តសញ្ញាណជាខ្មែរក្រោម ហើយមិនត្រូវបានគេយកទៅសម្លាប់នោះ លើកលែងតែបុគ្គលនោះមានពាក់ព័ន្ធទៅនឹងការងារជាយោធា ជាទាហានជាដើម។ លោកដឹងដោយរបៀបណា? ដឹងពីប្រភពណាដែរ?

[១៤:២១:៥៥]

**ឆ៖** បាទ អារឿងខ្មែរក្រោមហ្នឹង ដូចថាគេ ទាល់តែគេប្រជុំមេភូមិអីហ្នឹង គេប្រកាសប្រាប់អ៊ីចឹង វាគ្មានស្គាល់ថា ខ្មែរក្រោម ខ្មែរលើអីទេពួកហ្នឹង។ ប៉ុនថា ដោយសារថាមេភូមិហ្នឹងគេប្រជុំប្រកាសប្រាប់ហ្នឹងថា អ្នកណាដែលមានឋានៈបុណ្យសក្តិ មុខងារជាអ្វីគេឲ្យទៅបម្រើការនៅមុខក្រសួងនោះវិញ។ អ៊ីចឹងដែលពួកខ្មែរក្រោមហ្នឹង វាឆ្លើយប្រាប់គេថា វាធ្វើទាហានមកពីកំពង់សោមអ៊ីចឹងទៅ ហើយគេពាក់ស័ក្តិប៉ុន្មានៗ អ៊ីចឹងទៅ ហើយបើថាអ្នកដែលខ្មែរក្រោមដែរ តែមិនបានឆ្លើយនេះទេ គេជាអ្នកកសិករដែរ គេវាគ្មានមុខងារអី។ ហើយបើតាមពិតទៅវាមិនសួរថា ខ្មែរក្រោម ខ្មែរលើអីផង ប៉ុន្តែវាសម្គាល់ថា ខ្មែរក្រោមហ្នឹងនិយាយវាមិនសូវច្បាស់អ៊ីចឹងណ៎ា និយាយដូចថាវារដឺនៗ វាមិនច្បាស់ដូចខាងលើហ្នឹង។ បាទ ខ្ញុំដឹងតែប៉ុណ្ណឹងទេ សូមជ្រាបចុះ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី!

[១៤:២៤:០២]

**សួរដោយលោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។

**ស៖** ខ្ញុំមានសំណួរខ្លីទេ ពាក់ព័ន្ធទៅនឹងចម្លើយដែលលោកបានឆ្លើយទៅនឹងលោកមេធាវី វ៉ិចទ័រ កូប៉េ ស្តីអំពីការដឹងអំពីអាវុធ។ ខ្ញុំកត់សម្គាល់ឃើញថា លោកមិនត្រឹមតែស្គាល់កាំភ្លើង ស្គាល់បង់កាំភ្លើងអាកា៤៧ ដែលមានគ្រាប់៣០។ លោកបានចេះរៀបរាប់អំពីរូបភាពបង់កាំភ្លើងអីទៀត ដែលគេដាក់ទៅក្នុងកាំភ្លើងនុំង។ លោកនិយាយថា បង់ហ្នឹងរាងកោង រាង-ង ខ្ញុំបានស្តាប់ឮច្បាស់ណាស់ថា លោកបាននិយាយថា លោកបានឃើញកាំភ្លើងនៅពេលដែលលោកនៅទីក្រុងភ្នំពេញ នៅក្នុងជំរំជនភៀសខ្លួន ក្នុងពេលដែលលោកជាជនភៀសខ្លួននោះ។ អ៊ីចឹង ខ្ញុំចង់ដឹងថាម៉េចក៏លោកដឹងច្បាស់ម្ល៉េះ ដឹង

យ៉ាងលម្អិតទៀត មិនត្រឹមតែដឹងពីថាបង់កាំភ្លើងហ្នឹងដាក់គ្រាប់បានប៉ុន្មានទេ ដឹងតាំងពីរាង-ង រាងអី អ៊ីចឹងទៀត។ ម៉េចក៏លោកដឹងច្បាស់ម្ល៉េះ?

**លោក ថាន់ ធីម៖**

**ឆ៖** បាទ បានជាខ្ញុំដឹងច្បាស់ហ្នឹង មកអំពីខ្ញុំហ្នឹងនៅជំរំហ្នឹងមានទាហាននៅជាមួយគ្នាដែរ ពួកទាហានហ្នឹង គេនៅការពារនៅហ្នឹងដែរណ៎ា។ ហើយដល់រួចទៅកាំភ្លើងអាកាក៏ខ្ញុំស្គាល់ អាកាំភ្លើងអឹមសី ក៏ខ្ញុំស្គាល់, អាអៀកែងហ្នឹង ក៏ខ្ញុំស្គាល់តែទាំងអស់ហ្នឹង ព្រោះនៅៗជំរំហ្នឹង វាមានទាហាននៅហ្នឹង នៅការពារពួកជនភៀសខ្លួនហ្នឹង បាទ សូមជ្រាប។

[១៤:២៦:០៤]

**ស៖** អ៊ីចឹង ពួកទាហានហ្នឹង បង្ហាញកាំភ្លើងទៅឲ្យលោក ហើយប្រាប់ថា កាំភ្លើងហ្នឹង គេបាញ់យ៉ាងម៉េចអីយ៉ាងម៉េច គេបង្ហាញបង់គ្រាប់ គេបង្ហាញគ្រាប់កាំភ្លើង គេពន្យល់របៀបបាញ់អីទៅលោក អ៊ីចឹងមែនទេ បានលោកដឹងច្បាស់អ៊ីចឹង?

**ឆ៖** បាទ ខ្ញុំនៅជាមួយទាហានហើយ ព្រោះទាហានហ្នឹងនិយាយប្រាប់ខ្ញុំ។ បាទ ហ្នឹងសូមជ្រាបចុះ ខ្ញុំនៅជាមួយទាហានហ្នឹងដែរ។ ខ្ញុំជាអ្នកកម្មករកាប់ឧសទេ ប៉ុន្តែថាអ្នកជនភៀសខ្លួនទេ ប៉ុន្តែថាទាហានហ្នឹងក៏គេនៅជាមួយពួកការពារជនភៀសខ្លួនហ្នឹងដែរ។ ហើយដល់រួចទៅ ខ្ញុំតែងតែសាកសួរគេអ៊ីចឹងទៅ "អានេះកាំភ្លើងអី?"ៗ ខ្ញុំចេះតែសួរលេងអ៊ីចឹងទៅ បានស្គាល់ហ្នឹង។ បាទ សូមជ្រាប។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកមេធាវី។ បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោក ថាន់ ធីម ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៤:២៧:៥០]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ថាន់ ធីម វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះក៏សូមអរគុណចំពោះលោក យួន សារ៉ាត់ ដែលជាបុគ្គលិកអង្គការ ធី.ភី.អូ ដែលបានអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋ-ប្បវេណីរូបនេះ។ ហើយឥឡូវនេះ ដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ លោក សារ៉ាត់។

ឈប់ៗៗ! នៅ បាទ នៅៗមួយទៀត។ បាទ សូមអង្គុយចុះវិញ។ នៅតិវិធីនៅមួយទៀត ដោយសារភ័ន្តច្រឡំរវាងសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្ប-វេណី លោកៗ ថាន់ ធីម ជាចុងក្រោយ យើងបានប្រាប់ព្រឹកមិញហើយ ថាលោកអាចថ្លែងរៀបរាប់ជូនដល់អង្គសវនាការស្ដាប់ អំពីរឿងរ៉ាវទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទារសំណងផ្លូវចិត្តនិងសម្ភារភាពពីជនជាប់ចោទ និងពីព្យសនកម្មដែលមានចំពោះលោក ជាអាទិ៍ ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត។ ផលវិបាកដែលកើតផ្ទាល់ពីបទឧក្រិដ្ឋ ព្យសនកម្មផ្ទាល់ខ្លួន ដែលបានកើតពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

បាទ នេះជាសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការចូលរួមផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺនាទីចុងក្រោយ លោកអាចថ្លែងរៀបរាប់អំពីស្ថានភាពនេះ ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

[១៤:២៩:៥១]

**លោក ថាន់ ធីម៖**

បាទ ខ្ញុំបាទសូមអរគុណណាស់ចំពោះលោកប្រធាន។ អ៊ីចឹង ខ្ញុំបាទនឹងសូមថ្លែងនូវសេចក្ដីទុក្ខសោករបស់ខ្ញុំបាទផ្ទាល់ដែលខ្ញុំបាទបានឆ្លងកាត់នូវរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹង បាទ។ អ៊ីចឹងខ្ញុំបាទឆ្លងកាត់របបនេះ គឺវាវេទនាមហាសែនហើយ ដូចថាវាដូចជាទើបនឹងបានរស់រានកំណើតទី២របស់ខ្ញុំបាទអ៊ីចឹង ព្រោះថាខ្ញុំបាទហ្នឹង គេប្រើឲ្យធ្វើការជាទម្ងន់ ហើយហូបតែបបរ ហើយចាប់ខ្ញុំបាទយកទៅដាក់គុក ដាក់មន្ទីរឃុំឃាំងអីអ៊ីចឹង ដូចថាវា ទាំងផ្លូវកាយ ខ្ញុំបាទក៏ពិបាកខ្លាំង អាផ្លូវចិត្តហ្នឹង ក៏ពិបាកខ្លាំង មិនដឹងស្រែកហៅអ្នកណាមួយឲ្យជួយបានទេបាទ។ អំពាវតែគុណឪពុក គុណម្ដាយ គុណជីដូនជីតា ទេវតា វត្ថុស័ក្ដិសិទ្ធិ ទសបារមីឲ្យលោកជួយ។ អ៊ីចឹងឃើញថា ខ្ញុំហ្នឹងវាបានមានភ័ព្វសំណាង

មកដល់ថ្ងៃនេះគឺថាដោយគុណ៧មករាដែរ។ ថ្ងៃ៧មករាហ្នឹង វាដូចថា វាមានថ្ងៃហ្នឹង បានខ្ញុំហ្នឹងបានរស់រានមានជីវិតហ្នឹង។ ព្រោះថាវាពិបាកមហាសែនហើយ ជាប់ខ្នោះជើងពីរ ដេកអត់មានប្រែខ្លួនអីបានទេ នៅតែផ្ងារអ៊ីចឹងបាទ គឺផ្ងាររហូត តែគេគ្រប់គ្នា ក៏គេមិនដូចខ្ញុំ គេជាប់តែជើងមួយ ខ្ញុំបានជាប់ដល់រហូតដល់ជើងពីរ។ ក្នុងការបត់ដែបត់ជើងអីហ្នឹង បត់ជើងតូចបត់ជើងធំអីហ្នឹង ពិបាកវេទនាមហាសែន។ បាទ ពីព្រោះថាអាខាប់អាចម៍ហ្នឹង បើវានៅឆ្ងាយអាខាប់ហ្នឹង គេដាក់ឲ្យយើងបត់ជើងតូចបត់ជើងធំហ្នឹង វានៅនេះមួយ នៅនោះមួយៗ។ អ៊ីចឹងដល់រួចទៅ បើវានៅឆ្ងាយពេក ខ្ញុំជើងពីរជាប់ជើងពីរ រើសម៉េចរួច ឡើងកិលខាប់ហ្នឹងម៉េចបាន ទាល់តែរកគេអាអ្នកជើងមួយហ្នឹង ទម្រាំនឹងបានយក កិល រុញមក ហើយកិលដល់កន្លែង បានខ្ញុំចាប់អាខាប់ហ្នឹងលើកយកមកដាក់លើហ្នឹងហើយបានឡើងបត់ជើងអ៊ីចឹងទៅ។ គឺមហាសែនវេទនាទុក្ខសោករបស់ខ្ញុំនោះ គឺពិបាកណាស់។ ហើយខ្ញុំថាវាមិនគួរឡើយដែលខ្ញុំអត់មានកំហុសអីសោះ ណោះ! បានមកទទួលរងនូវអំពើអយុត្តិធម៌ដូចរបប៣ឆ្នាំនេះ ខ្ញុំៗនឹកក្នុងចិត្តថា មិនដែលទេ បាទ តាំងពីខ្ញុំកើតមក ចំណាស់នេះហើយ គឺខ្ញុំមិនដែលបានឆ្លើយកាត់ទេ ទើបតែឆ្នាំ៧៥ ដល់៧៩នេះ ម៉េចក៏មហាសែនពិបាកមាំម្ល៉េះ។ រស់ស្ទើរ -- រស់សឹងមិនកើត ស្ទើរងាប់ស្ទើររស់។ បានរាល់ថ្ងៃហ្នឹងខ្ញុំក៏បាន ដូចថាបានរស់មែន ក៏ប៉ុន្តែរស់ហ្នឹង វាខូចខាតកាយសម្បទាហ្នឹង ក៏វាធ្វើការអីមិនបានជាមាំមួនដែរ។ អ៊ីចឹងបានថា សំណូមពររបស់ខ្ញុំ ខ្ញុំសូមថាលោកតុលាការជួយមេត្តាជួយធ្វើយ៉ាងណារកយុត្តិធម៌ឲ្យខ្ញុំ ដូចថាប៉ះប៉ូវជាថវិកាអីខ្លះ បានខ្លះទេបាទ ហើយនិងសំណងជាខ្លះជាលក្ខណៈសមូហភាពហ្នឹង ក៏ខ្ញុំក៏សំណូមពរអ៊ីចឹងដែរ ប៉ុន្តែវា បើសំណងជាលក្ខណៈបុគ្គលហ្នឹងខ្ញុំក៏សុំទាមទារខ្លះដែរ ពីព្រោះខ្ញុំបានឆ្លងកាត់មក វាខូចខាតអាផ្លូវរាងកាយហ្នឹង កាយសម្បទាខ្ញុំហ្នឹងវាអត់បានរកស៊ីអីបានមាំមួនដូចគេទេ បាទ។ គឺធ្វើបានតិចតួចការងារស្រាលៗ។

[១៤:៣៤:៤៨]

អ៊ីចឹង ខ្ញុំបាទក៏សូមគោរពជូនពរដល់អស់លោក លោកស្រី ចៅក្រម អស់លោក លោកស្រី សហមេធាវី, អស់លោក លោកស្រី សហព្រះរាជអាជ្ញា បាទ ទាំងជាតិ ទាំងអន្តរជាតិ។ សូមគោរពជូនពរឲ្យអស់លោកទាំងអស់បានជួបនូវសេចក្ដីសុខ សេចក្ដីចម្រើន អាយុយឺនយូរ កម្លាំងខ្លាំងក្លាប្រាជ្ញាឈ្លាសវៃ ដើម្បីដោះស្រាយជូនដល់ពួកយើងខ្ញុំជាជនរងគ្រោះឲ្យទទួលបាននូវជោគជ័យផងបាទទទួលយុត្តិធម៌ផង។ សូមជ្រាប សូមអស់យោបល់ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សាថ្មីម្ដងទៀត អរគុណលោក ថាន់ ធីម ប៉ុន្តែទន្ទឹមនឹងនេះ អង្គជំនុំជម្រះសូមឆ្លើយបញ្ជាក់ជម្រាបជូនលោកឱ្យបានច្បាស់លាស់ នៅតុលាការនេះ គឺមិនមានការទាមទារសំណងជាបុគ្គល ឬក៏ជាប្រាក់កាក់ជាក់លាក់នោះទេ នៅក្នុងវិធានផ្ទៃក្នុងដែលចែងពាក់ព័ន្ធជាមួយនឹងការទាមទារសំណង គឺមានសិទ្ធិក្នុងការទាមទារសំណងជាសមូហភាព សំណងជំងឺចិត្ត ហើយនិងជាសមូហភាពតែប៉ុណ្ណោះ។ នេះសូមបញ្ជាក់ឱ្យបានច្បាស់លាស់។ មិនអាចប្ដឹងទាមទារសំណងជាបុគ្គល ហើយជាថវិកា ឬក៏សម្ភារះអ្វីសម្រាប់ជាបុគ្គលនោះទេ។

ហើយលោកអាចចាកចេញបានហើយ លោក ថាន់ ធីម ហើយនិងបុគ្គលិកអង្គការ ធី.ភី.អូ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសវនាការនៅពេលបន្ទាប់នេះ អង្គជំនុំជម្រះនឹងចាប់ផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មស្ដាប់សាក្សី ដែលមានរហស្សនាម 2-TCW-809។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះ គឺធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានសហនាម 2-TCCP-809។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអ្វី?

**លោក ពេជ្រ ជឹម៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ ពេជ្រ ជឹម។

**ស៖** អរគុណលោក ពេជ្រ ជឹម។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** បាទ ខ្ញុំកើតនៅថ្ងៃ២៩ ខែ៩ ឆ្នាំ១៩៤១។

[១៥:០១:១៨]

**ស៖** ទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណាលោក ពេជ្រ ជឹម?

**ឆ៖** បាទ នៅភូមិត្រពាំងព្រៃ ឃុំត្រពាំងធំ ស្រុកត្រាំកក់។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃ តើលោករស់នៅទីកន្លែងណា?

**ឆ៖** សព្វថ្ងៃខ្ញុំរស់នៅភូមិផ្អាវ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ឧត្តរមានជ័យ។

**ស៖** អរគុណ។ តើឪពុកបង្កើតរបស់លោកឈ្មោះអី? ម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** គាត់ស្លាប់អស់យូរហើយ។ ឈ្មោះគាត់ឈ្មោះពុក ពាវ ពេជ្រ, ម្ដាយ អ៊ូ ណន។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ប្រពន្ធឈ្មោះ ច្រឹក ពេជ្រណេង, មានកូនប្រាំនាក់ ស្លាប់ម្នាក់ក្នុងសមរភូមិ នៅបួននាក់ ស្រីមួយ។

**ស៖** បាទ អរគុណ។ លោក ពេជ្រ ជឹម តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងគឺថា លោកមិនមានឪពុកម្ដាយ បុព្វញាតិ កូន ឬបច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធត្រូវបានទទួលស្គាល់យកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដី០០២ ទេ។ តើពិតមែនដែរទេ?

[១៥:០៣:០៨]

**ឆ៖** បាទ អ៊ីចឹងពិតមែន។

**ស៖** ហើយតើលោកបានស្បថហើយ ឬនៅមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ ខ្ញុំស្បថរួចហើយ។

**ស៖** អរគុណ។ ជាតទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ លោក ពេជ្រ ជឹម អំពីសិទ្ធិក្នុងនាមលោកជាសាក្សីនៅក្នុង

កិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការអំណះអំណាងណាមួយ ច្រើនដែលដាក់បន្ទុកលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ បាននាំឲ្យលោកត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចលោក ពេជ្រ ជឹម ក្នុងនាមលោកជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបនូវរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ដូចយើងបានប្រាប់អំពីសិទ្ធិរួចមកហើយអម្បាញ់មិញនេះ។ ហើយក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ លោក ពេជ្រ ជឹម តើលោកធ្លាប់ផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យនៃសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើមានតើធ្វើប៉ុន្មានដង? ហើយការធ្វើនោះនៅទីកន្លែងណា? នៅពេលណា? លោកចងចាំដែរឬទេ?

[១៥:០៥:១៦]

**ឆ៖** បាទ ខ្ញុំ -- ទៅសួរដល់ផ្ទះច្រើនដងខ្ញុំអត់ចាំទេ។ សម្ភាសដល់ផ្ទះច្រើនដង ហើយមកនេះម្តងកន្លែងហ្នឹង។

**សៈ** ហើយនៅមុនពេលចូលមកមុខអង្គជំនុំជម្រះនេះ ថាតើលោក ពេជ្រ ជឹម បានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បានអានឲ្យស្តាប់មួយចប់។

**សៈ** អរគុណ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ ថាតើលោកអាចបញ្ជាក់បានដែរទេ ថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន -- បានស្តាប់ការអានមួយចប់ដើម្បីរំឭកការចងចាំនោះគឺពិតជាត្រឹមត្រូវ ឬវាស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសជាមួយ

នឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

**ឆ៖** អាចវែកញែកបានតាមការចងចាំ។

**ស៖** បាទ ហើយលោក ពេជ្រ ជឹម នៅពេលនេះ លោកបានទទួលជំនួយមេធាវីប្រឹក្សាដែលអង្គជំនុំជម្រះផ្តល់ឲ្យលោកតាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ តាមសំណើរបស់លោកហើយ គឺលោកមេធាវី មឿន សុវណ្ណ។ តើលោកបានប្រឹក្សាយោបល់ជាមួយនឹងមេធាវីប្រឹក្សារបស់លោករួចហើយឬនៅ?

**ឆ៖** បានប្រឹក្សាខ្លះៗ អត់បានទាំងអស់ទេ សំណួរហ្នឹង។

**ស៖** បាទ អរគុណ។ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ពេជ្រ ជឹម មុនភាគីឯទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃ និងមួយវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី។

[១៥:០៨:០១]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំសូមចាប់ផ្តើមដោយសួរសំណួរលោកខ្លីៗចំនួនពីរបីទាក់ទងទៅនឹងប្រវត្តិរបស់លោក។ នៅក្នុងកិច្ចសម្ភាសន៍លើកក្រោយគឺ E319.1.9 នៅសំណួរ១៨ និង២០ លោកបាននិយាយថា លោកក្លាយជាសមាជិកបក្ស នៅថ្ងៃ០១ តុលា។ ហើយលោកជាសមាជិកបម្រុងរយៈពេលប្រាំមួយខែ បន្ទាប់មកលោកក្លាយជាសមាជិកពេញសិទ្ធិនៅថ្ងៃ០១ មេសា ឆ្នាំ៧១។ ហើយលោកបានរៀបរាប់អំពីពិធីតែងតាំង ដែលនៅពេលនោះមានអ្នកណែនាំលោកចូលផងដែរ។ ខ្ញុំចង់សួរថាតើ អ្នកណាជាអ្នកណែនាំលោកចូលបក្ស? គឺនៅពេលដែលលោកក្លាយជាសមាជិកបក្សនោះ អ្នកណាជាអ្នកណែនាំលោក?

**លោក ពេជ្រ ជឹម៖**

**ឆ៖** កាលនោះ ចូលគ្នាក្នុងស្រុកមាន ឈ្មោះ គាវ, ឈ្មោះ ខុម – ខុម នេះស្រី។ ស្រីទៀត ជាតិ

និង ញ៉េវ មានប៉ុណ្ណឹង ហើយនិងខ្ញុំ។

**ស៖** ចុះបុគ្គលដែលលោកហៅថា ឈ្មោះ ខុម ស្រីហ្នឹង តើខុម ហ្នឹងគឺជាកូនស្រីរបស់តាម៉ុក មែនទេ?

**ឆ៖** មែនហើយ ប្រពន្ធលោក មុត។ គាត់ជាប្រធានបក្សស្រុក។

**ស៖** នៅក្នុងសំណួរដដែលហ្នឹងគឺសំណួរ៧៩ លោកបានផ្តល់សក្ខីកម្មដូចតទៅនេះ "សំណួរ៖ នៅក្នុងតួនាទីលោកជាសមាជិកពេញសិទ្ធិ តើលោកមានអំណាចអ្វីដែរ? ឆ្លើយ៖ ខ្ញុំមិនអាចរៀបរាប់ទាំងអស់បានទេ ក្នុងនាមជាសមាជិកបក្ស គឺយើងត្រូវអនុវត្តន៍វមាគ៌ាបក្ស មានវគ្គរៀនសូត្រ និងមិទ្ទីង ហើយយើងគឺជាសមាជិកថ្មី ដូច្នេះ យើងត្រូវតែព្យាយាមសិក្សាអំពីមាគ៌ាបក្ស ហើយនិងការណែនាំ"។ ដូច្នេះ ខ្ញុំចង់សួរលោកថាៗតើអ្នកណាជាអ្នកណែនាំលោកនៅក្នុងវគ្គរៀនសូត្រនៅពេលដែលលោកចាប់ផ្តើមរៀនអំពីបញ្ញត្តិ ហើយនិងមាគ៌ាបក្សនោះ។ តើអ្នកណាជាអ្នកបង្រៀនលោក?

**ឆ៖** ថ្នាក់រៀន គឺប្រធានតំបន់ ឈ្មោះ សោម។ ឥឡូវនេះ គាត់ស្លាប់បាត់ហើយ។

[១៥:១១:៥០]

**ស៖** ខ្ញុំគិតថានៅក្នុងកិច្ចសម្ភាសន៍ដំបូងរបស់លោក គឺលោកបានកំណត់ -- បានបង្ហាញពីឈ្មោះ គឺគ្រូហឿន ដែលលោកនិយាយថាគឺជាសមាជិករណសិរ្ស។ តើលោកអាចប្រាប់បានទេថាតើអ្នកណាជាលោកគ្រូអឿន ហើយតើគ្រូអឿន គាត់មានតួនាទីអ្វីនៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** គាត់អត់បានចូលបក្សផង គាត់ជាអ្នករត់ការ ហើយជំនួយការក្នុងស្រុកហ្នឹងរហូតមក អត់មានបានចូលបក្សទេ។ ខ្ញុំមិនប៉ានស្នើបញ្ចូល ព្រោះខ្ញុំអនុធន គ្រូហើយ អនុធនៗទាំងអស់ ចង់ភ័យខ្លួនឯងដែរ ជំនាន់ហ្នឹងអីចឹង មិនមែនចេះតែមានគ្នាទីហើយចេះតែគ្រាន់បើបានទេ ចេះតែធំបានទេ ធំលើបក្ស ប្រធានបក្ស បក្សស្រុក បក្សខេត្ត អីដែលស្នើយល់ព្រមបានប៉ានធ្វើ បើមិនយល់ព្រម អត់ប៉ានធ្វើទេ អត់ប៉ានធ្វើនេះ និយាយតែការងារសំខាន់ៗ បើបញ្ហាបង្កបង្កើនផលចិញ្ចឹមជីវិតដោះស្រាយជីវភាពប្រជាជន អាហ្នឹងញាប់ស្នេកហើយ ប្រឹងបាន អត់ចេះខុសទេ ត្រូវទាំងអស់។ ឲ្យតែមានស្រូវច្រើនកន្លែងណាអត់មកសុំអង្ករ ខ្ញុំផ្តល់ហើយ។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ដដែលគឺ E319.1.18 និងចម្លើយទី៣ ដល់ទី៥ លោកបាននិយាយអំពីបងប្រុសរបស់លោកមួយឈ្មោះ ពេជ្រ នៅ –ខ្ញុំសង្ឃឹមថាខ្ញុំអានឈ្មោះគាត់ត្រូវ– គឺ ពេជ្រ នៅ ដែលជាប្រធានរណសិរ្សឃុំនៅក្នុងឆ្នាំ៧០ ដល់ ៧៥។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ច្បាស់ថាតើលោកមានបង

ប្អូនប៉ុន្មាននាក់? ហើយតើបងប្អូនលោកប៉ុន្មាននាក់ដែលមានតួនាទីនៅក្នុង ដែលមានតួនាទីនៅក្នុងរបបខ្មែរក្រហមនោះ?

[១៥:១៤:៤២]

**ឆ៖** បងប្អូនប្រុសប្រាំមួយនាក់ តែស្លាប់អស់ហើយ។ នៅធ្វើក្នុងតួនាទីខ្មែរក្រហមហ្នឹងពីរនាក់ បីទាំងខ្ញុំ ខ្ញុំហ្នឹងក្រោយគេ។ "បងមិនឲ្យធ្វើទេ អូនអ្នែងវីវរផុតពូជ" ខ្ញុំប្រាប់ត្រង់ "ងាប់ៗបងចុះ!"។ ខ្ញុំក៏ធ្វើគ្រូបង្រៀនស្វាត់អីចឹងមក ដែលមានមាត់ -- នយោបាយថាអី អត់ទេ នៅស្ងៀម។ សូមអស់។

**ស៖** តើខ្ញុំនិយាយត្រូវដែរទេ ដែលថាបងប្អូនរបស់លោកពីរនាក់ហ្នឹង គឺមានតួនាទី គឺមួយឈ្មោះ ពេជ្រ នោ ហើយនិងបងប្រុសរបស់លោកមួយទៀតឈ្មោះ គិត។ តើខ្ញុំនិយាយអីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រូវហើយ។

**ស៖** តើបងប្រុសរបស់លោក គឺលោក ពេជ្រ នោ ហ្នឹងគាត់ជាប្រធានឃុំឈ្មោះអីដែរ ឃុំនោះ?

**ឆ៖** សូមបញ្ជាក់ ប្រធានរណសិរ្សឃុំត្រពាំងធំ ៧០។ ក្រោយមកដកចេញដាក់ គិត ដោយឈ្មោះ ដុំ ទៅទាក់ទងឃុំ ហើយធ្វើការឃោសនា មានភស្តុភារ ស្ករស ទឹកដោះគោអីប្រមូល និមន្តលោកឆាន់អីឲ្យធ្វើ ដើម្បីប្រមូលកម្លាំង។ ហើយគាត់អត់នេះ គាត់នៅស្ងៀម។ ដល់ឃើញអីចឹង គេដកគាត់បាត់ ដកចេញពីនាទីឃុំ តាំងពីនុំងរហូតមក។ ក្រោយមក ទៅធ្វើការនៅមន្ទីរយុទ្ធជនត្នោតទោ ប៉ុណ្ណឹង។

**ស៖** ខ្ញុំនិយាយបន្តទៀត។ ថាតើគាត់ៗនៅរស់ដែរឬទេ ក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** ពេជ្រ នោ? គាត់ ពេលដែលវៀតណាមចូលប្រទេសពេញមក អ្នកតាកែវភៀសនៅកំពតនៅភ្នំ។ គាត់ភៀសទៅនៅៗព្រៃហ្នឹង ហើយស្លាប់ដោយជាន់មីន។ គ្នាឯងទៅផឹកគ្នាឯងនុំង ចេញមកជាន់មីនស្លាប់។ ហើយបង គិត នោះស្លាប់នៅនោះដែរ។ សភាពការណ៍វៀតណាមវាតត្បាតខ្លាំង នៅពួនក្នុងព្រៃ។ អ្នកនៅឯជុំវិញរវល់តែប្រលែងគ្នា សើចចោលគ្រាប់ ចោលគ្រាប់នោះ។ ខឹងពួកហ្នឹង ចេញទៅអង្គុយក្រៅវង់ទៅ ផ្អែកដើមឈើមួយធំ អង្គុយស្ងៀម ពែនភ្នែនដូចលោក។

[១៥:១៨:២៤]

ដល់ថ្ងៃដើររក ថ្ងៃរសៀលមិនឃើញ គាត់នៅស្លាប់អង្គុយពែនភ្នែនក្បែរដើមឈើ។ ហ្នឹងឥឡូវអស់ហើយ អត់មានបងប្អូនអី នៅខ្ញុំម្នាក់(ប្រុស) ស្រីបីស្លាប់ទាំងអស់។ បងប្អូនប្រាំបួននាក់ នៅតែមួយហើយពៅគេ ក្រោយគេបំផុត ស្មោះត្រង់តាំងពីតូច ឃើញអីថានុំង។ មិនវៀចវេរទេ។ មិនកេងប្រវ័ញ្ចហើយស្អប់អ្នកកេងប្រវ័ញ្ច បោកប្រាស់គេទៀត ស្អប់ចោរទៀត។ ហ្នឹងខ្ញុំ ទស្សនៈខ្ញុំអីចឹង ស្រឡាញ់ការ

ត្រឹមត្រូវ ស្រឡាញ់ប្រជាជន ស្រឡាញ់អ្នកក្រ អ្នកចេះក៏ស្រឡាញ់ មិនមែនត្រឹមតែអ្នកក្រទេ។ តាសាំងក៏ចូលចិត្តអ្នកចេះ ក៏ចូលចិត្ត ពេញចិត្ត។ យល់ឃើញថាអ្នកចេះហើយ ដែលដឹកនាំគេបានជឿនលឿន។ សូមពាក់ព័ន្ធអ៊ីចឹង ខ្លីៗជូនខ្លះ ដើម្បីអស់លោកយល់ទឹកចិត្ត។ ហើយចង់បានណាស់រាល់ថ្ងៃ ធ្វើម៉េចអស់លោកបញ្ចប់រឿងហ្នឹងឲ្យឆាប់ទៅ។ ខ្ញុំសូមប្រាប់ ជម្រាបត្រង់។ បើកភ្នែកមក ខ្មែរយើងឮតែទាស់គ្នា មិនដឹងអង្កាល់បានចប់ ឈប់ទាស់គ្នា ប្រទេសប៉ុប៉ុន ជាមហាអំណាចមួយ ឥឡូវសល់បន្តិចមួយ។ ហើយការទាស់ក្នុងប្រទេសក៏មិនចេះអស់ ជំនាន់ណាក៏ទាស់។ ហ្នឹងហេតុ ចង់ល្អពេក វាទៅជាចាញ់។ ចង់ល្អៗយូរទៅ អត់ទុកចិត្តគ្នាឯង ខ្ញុំនិយាយនេះចូលដល់សម័យខ្លះ។

**ប្រធានអង្គជំនុំ៖**

លោកៗ ពេជ្រ ជឹម លោកស្តាប់សំណួរ ហើយលោកឆ្លើយតែក្នុងក្របខ័ណ្ឌចាំបាច់ ពេញលេញតបនឹងសំណួរបានហើយ ជៀសវាងលោកឆ្លើយទៅមានការរាលដាលវែងឆ្ងាយ ដែលចាកផុតពីភាពចាំបាច់ឆ្លើយតបនឹងសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកសាក្សី។ បងប្រុសលោកមួយទៀត គឺបងគិត តើគាត់គឺជាប្រធានឃុំត្រពាំងធំដែរឬទេ? ថាតើគាត់ធ្លាប់ធ្វើជាប្រធាន -- តើ គិត ធ្លាប់ធ្វើជាប្រធានឃុំត្រពាំងធំហ្នឹងដែរទេ? ហើយប្រសិនបើគាត់ធ្វើជាប្រធានឃុំ តើនៅពេលណា?

[១៥:២១:២២]

**លោក ពេជ្រ ជឹម៖**

**ឆ៖** គាត់ធ្វើប្រធានឃុំត្រពាំងធំ។ កាលហ្នឹង ត្រពាំងធំតែមួយ ទើបតែបែកឥឡូវ។ គាត់ធ្លាប់ធ្វើហើយ បានឡើងមកធ្វើស្រុក។ រំដោះហើយ ឬជិតរំដោះ ខ្ញុំមិនចាំច្បាស់ទេ។ ខ្ទង់ចុង៧៦ គាត់ឡើងមកគាត់ -- មុន៧៦ គឺនៅឃុំត្រពាំងធំ។ ៧៦ បានឡើងមកធ្វើស្រុក ដើម៧៧ហ្នឹង។ អស់។

**ស៖** តើនៅពេលណាដែលគេបំបែកឃុំត្រពាំងធំទៅជាពីរហ្នឹង? តើមុនថ្ងៃ១៧មេសា ៧៥ ឬក៏ក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥?

**ឆ៖** ក្រោយទេ។ ក្រោយមករហូត មិនចាំច្បាស់ ប៉ុន្តែក្នុង៧៦ហ្នឹង ចុងឆ្នាំ៧៦ហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកបន្ថែម ដើម្បីឲ្យលោកជួយយើងយល់អំពីមេស្រុកត្រាំកក់នានានៅក្នុងរបបមួយនោះ ហើយចង់ដឹងថា តើអ្នកណាមានតួនាទីសំខាន់ៗអ្វីខ្លះ។ ដូច្នេះជាដំបូង ខ្ញុំចាប់ផ្តើម

សួរលោកអំពីមេស្រុកត្រាំកក់នៅក្នុងរបបនោះ។ លោក ហើយនិងសាក្សីដទៃទៀត បាននិយាយអំពីលេខាស្រុកត្រាំកក់ គឺយាយខុម ដែលជាកូនរបស់តាម៉ុក – គឺយាយខុម កូនរបស់តាម៉ុក។ ហើយលោកបាននិយាយថា មេឃុំដំបូងគេ គឺយាយខុម ហើយនិង គឹម។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកមានតួនាទីអ្វីដែរ នៅពេលដែល យាយខុម គឺជាមេស្រុកនោះ? តើលោកមានតួនាទីអ្វីដែរ នៅក្នុងគណៈកម្មការ?

[១៥:២៤:៣៤]

**ឆ៖** កាលដែល ខុម មកចុះធ្វើការហ្នឹង ខ្ញុំអត់មានតួនាទីអីក្នុងគណៈហ្នឹងទេ។ ជាមនុស្សដែលគេប្រើ រត់ចុះឡើង ដឹកឡូតិ៍ ដោះដូរសេដ្ឋកិច្ច ប្រមូលផលស្រូវអង្ករ បម្រើកងទ័ព។ រហូតបានពីរឆ្នាំ បានគេឲ្យទទួលជាសមាជិកស្រុកហ្នឹង ហើយធ្វើការសេដ្ឋកិច្ចដដែល បង្កបង្កើនផល ដឹកជញ្ជូនភស្តុភារដដែល។ ឯ ខុម ប្រធានបក្ស, អនុប្រធាន គាវ – តាគាវ ហើយសមាជិកបន្ទាប់មកទទួលយោធា ញ៉េវ។

**ស៖** ក្នុងនាមជាអនុលេខានៅក្រោម យាយខុម ហ្នឹង តើតាគាវ គាត់មានភារកិច្ច ឬក៏តួនាទីអ្វីដែរ?

**ឆ៖** តួនាទីអប់រំប្រជាជន អប់រំបក្ស បក្សក្នុងស្រុកហ្នឹង។ រួមជាមួយ ខុម។ អត់មានខុម គឺមានមុខគាត់។

[១៥:២៦:៤៥]

**ស៖** ក្នុងនាមជាសមាជិកគណៈកម្មការស្រុក ហើយខ្ញុំចង់និយាយក្រោយថ្ងៃ១៧ មេសា ៧៧ ក្នុងនាមជាសមាជិកគណៈស្រុក តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំកម្រិតស្រុកដែរឬទេ?

**ឆ៖** ប្រជុំ។

**ស៖** តើ យាយខុម គាត់ប្រជុំជាមួយមេឃុំ ឬក៏ជាមួយសមាជិកកម្មាភិបាលផ្សេងៗទៀតហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ញាប់ដែរ មិនមែនជាញាប់ពេក។ មានការញឹកទៅ បានហៅប្រជុំទៅ អត់ការក៏ធម្មតា ចុះជាប់។ វិធីចុះជាប់គឺគេចែកគ្នា។ ចុះពីរៗឃុំទៅ បែងតូចៗចែកគ្នាចុះទៅ ហើយបានមកជួបទាំងអស់គ្នា បើចុះទាំងអស់វាមិនសព្វ។ នេះវិធីចាត់ចែងការងារគ្នា គេបែងអ៊ីចឹង។ គាវ ពីឃុំទៅ, ខុម ពីរឃុំទៅ។ ខ្ញុំទៅមុខ នៅក្មេងជាងគេកាលនោះ វាសួរ ក្មេងនៅកម្លាំង ប៉ុន្តែអាយុចាស់ណាស់ដែរហើយ។ ខាងមុខគឺសំដៅថាកន្លែងដែលប្រទង់ប្រទាញ កន្លែងខាងក្រោយ កន្លែងដែលវាសុខសាន្ត គេដាក់ស្រី ហើយនិងចាស់។ អាហ្នឹងបញ្ជាក់ជូនអ៊ីចឹង វិធីធ្វើការងារ។ ហើយប្រជុំញឹករង្វើលមិនកំណត់ទេ។ តែ ខុម ហៅ

ប្រជុំហើយ គេហៅទាំងអស់។ ប៉ុន្តែលក្ខណៈដែលពេលខ្លះមិនបានមកទាំងអស់ សមាជិកស្រុកទាំងអស់ហ្នឹង បាត់ពីរបីនាក់ គឺខ្ញុំនៅមុខ នៅជាប់ការងារ ធ្វើទំនប់ ទប់ទំនប់ខ្ពបត្របែក។ ជូនគាត់ហៅទៅប្រជុំកន្លែងទំនប់ ជួនគាត់ធ្វើគុសឯណោះ គាត់ធ្វើខាងណោះ ខ្ញុំអត់មកទេ គ្រាន់តែថានៅហ្នឹងហើយ។ ហើយ ញ៉េវ នៅសមរភូមិ ក៏មក។

[១៥:៣០:០៥]

**សៈ** តើលោកអាចប្រាប់បានទេ ក្នុងឆ្នាំ៧៥ និង៧៦ តើមន្ទីរស្រុកហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆៈ** មន្ទីរស្រុកត្រាំកក់ហ្នឹង អត់មានកំណត់ទេ ច្រើនតែនៅតាមផ្ទះប្រជាជន ភូមិប៉ែនមាសហ្នឹង។ ដំបូងនៅប៉ែនមាស នៅបានមួយប្រាំងហ្នឹងមកនៅភូមិព្រៃតាដុក។ នៅព្រៃតាដុកហើយ មកនៅក្របីព្រៃ កូនផ្ទះយាយៗហ្នឹង ផ្ទះតូចៗ។ ហើយមកនៅកំពង់ថ្ម –ត្រពាំងថ្មជាប់ក្របីព្រៃហ្នឹង។

**សៈ** យើងបានស្តាប់ឮសក្ខីកម្មរបស់សាក្សីមួយចំនួនដែលនិយាយថា មន្ទីរស្រុកគឺមានទីតាំងនៅអង្គរកា។ តើលោកអាចប្រាប់បានទេថា នៅពេលណាដែលគេរើមន្ទីរស្រុកទៅអង្គរកា? ហើយប្រសិនបើលោកចាំថា តើគេរើហ្នឹងនៅពេលណាដែរ?

**ឆៈ** អង្គរកាហ្នឹងគឺដាក់ពាណិជ្ជ កន្លែងទាក់ទងពាណិជ្ជ។ ពាណិជ្ជហ្នឹងលក់ដូរក៏មានអីលក់ខាងសេដ្ឋកិច្ច។ ដល់ឃើញអីចឹងមតិគេក្រឡេកឃើញ ហើយអង្គការផ្ទះទំនេរច្រើន ឃើញប្រជុំឃើញអីហ្នឹង ថាលើក។ ឃើញទៅហ្នឹងរយៈអីចឹងទៅ បីបួនប្រាំខែទៅ មកឈរនេះវិញ។ ប៉ុន្តែនៅញឹកជាងគេភូមិត្រពាំងថ្ម ព្រៃតាដុក ភូមិសំរោងហ្នឹង ហើយទៅនៅអង្គរកាមែន។ ហើយអ្នកដែលនៅជាប់នៅហ្នឹង អ្នកពាណិជ្ជមិនមែនគណៈស្រុកទៅនៅជាប់ទេ ផ្ទះគេនៅក្រោយដដែល។ ជម្រាបប៉ុណ្ណឹង។

**សៈ** ខ្ញុំសូមសួរលោកបន្តទៀត។ ដំបូងគឺថា លោកគឺជាសមាជិកគណៈស្រុក គឺចាប់ពីឆ្នាំ ចាប់ពី១៧ មេសា ៧៥ រហូតទៅដល់ពេលដែលលោកក្លាយទៅជាមេស្រុកស្តីទី។ តើនៅពេលនុំងលោកធ្វើការនៅកន្លែងណាដែរ? តើលោកមានមន្ទីរដែរឬទេ? ហើយប្រសិនបើមានមន្ទីរ តើមន្ទីរហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆៈ** មន្ទីរហ្នឹងផ្ទះយាយមួយនៅកំពង់ថ្ម ឈើចាស់ៗ រុះធ្វើបានកូនផ្ទះមួយ ដីគាត់ទំនេរក្បែរហ្នឹងឥឡូវមិនដឹងនៅឬអត់។ ហើយដេកនៅឯណា កំណត់ យូរៗចូលមន្ទីរមួយថ្ងៃ។ ស្អែកឡើងចេញវិញទាល់ដល់ថ្ងៃគេប្រជុំបានមកប្រជុំនឹងគេ ហើយចេញទៅវិញ។ ចេញទៅវិញជាប់ចលនា។ ឃុំលាយបូរ

មួយយប់ពីរ ភូមិស្រែរនោងភូមិដូរមុខ ខ្ញុំដើរទាំងអស់ជាមួយ ញ៉ែវ។ ប៉ុណ្ណឹង។ ឯមន្ទីរហ្នឹងមានអ្នកមន្ទីរមួយប្រចាំការនៅហ្នឹងតែម្តង សំបុត្រអីវាមកហ្នឹង។ អ្នកហ្នឹងយកសំបុត្រតាម ដំណឹងអីៗដឹងគ្នាជាប់។ ថាឲ្យតាំងទីនៅហ្នឹងតែម្តង នៅតិចថ្ងៃណាស់។

[១៥:៣៥:២៣]

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរលោកនូវសំណួរដដែលគឺថាក្នុងរយៈពេលប្រាំមួយខែ ដែលលោកជាមេស្រុកនោះ តើវា -- ដែលលោកប្រើប្រាស់មន្ទីរស្រុកហ្នឹងនៅកន្លែងដដែល ឬក៏លោកប្រើប្រាស់នៅកន្លែងផ្សេងគឺថា នៅពេលដែលលោកធ្វើជាមេស្រុកត្រាំកក់ហ្នឹង លោកប្រើប្រាស់មន្ទីរដដែល ឬមួយក៏យ៉ាងម៉េច?

**ឆ៖** ក្តាប់មិនបាន អត់មានទីកំណត់ ចល័ត នៅចល័ត។ ហើយកន្លែងត្រពាំងថ្មហ្នឹងអត់រុះទេ នៅហ្នឹង។ ទីហ្នឹងនៅ អង្គការហ្នឹងនៅ ផ្ទះថ្មហ្នឹងយកអាជ្រុងខាងត្បូង ក្បាលស្ពាន។ ហើយដាក់អីវ៉ាន់ដឹកដោះដូរចែកប្រជាជនអីហ្នឹង។ ថាឲ្យមកនៅកន្លែងធ្វើអ្នកធំដូចរបបនោះអត់ទេ ក្បាលមូលតិលហើយ ចុះជាប់ឃុំនេះ ឃុំនោះ ទប់ទំនប់ធ្វើស្រែ នរណាធ្វើបានប៉ុន្មានៗ គ្រាន់មិនគ្រាន់ ហូបឆ្អែតមិនឆ្អែត ចុះជាប់។ បើមិនអ៊ីចឹងម៉េចមានហូប? បង្កបង្កើនផលស្រូវកន្លះ ស្រូវធ្ងន់ ដាំដំឡូងមីខាងជើងភ្នំលិច។ អត់បាយឲ្យដំឡូង។ សូមអស់។

**ស៖** ដូច្នេះដើម្បីបញ្ជាក់ឲ្យបានច្បាស់ នៅក្នុងពេលដែលលោកធ្វើជាមេស្រុកគឺមិនមានមន្ទីរមួយកន្លែងទេ គឺលោកធ្វើការចល័តរហូតនៅក្នុងពេលដែលលោកធ្វើជាមេស្រុក។ តើអ៊ីចឹងមែនទេ?

[១៥:៣៨:០៧]

**ឆ៖** ជំនាន់នោះ នៅដល់អង្គរកាជាប់ជាងកន្លែងណាទាំងអស់។

**ស៖** លោកបាននិយាយអំពីផ្ទះយាយម្នាក់ដែលលោកយកធ្វើជាមន្ទីរ។ តើផ្ទះយាយហ្នឹងមានទីតាំងនៅកន្លែងណាដែរ?

**ឆ៖** នៅក្នុងផ្សារហ្នឹង។

**ស៖** លោកនិយាយពីផ្សារអង្គរកាមែនទេ?

**ឆ៖** ផ្សារអង្គរកា។ កាលខ្ញុំនៅ ដាក់ផ្សារញោចមកកើត ផ្ទះគាត់ឈ្មោះ តាយិន។ ផ្ទះនោះថ្មប៉ុនជញ្ជាំងវ៉ែបែកចង់អស់ហើយ។ ដល់ខ្ញុំចេញទៅ ឃើញអ្នកនោះទៅនៅផ្ទះខាងលិចផ្លូវ អាទទឹងនេះវិញ។ ហ្នឹងជំនាន់ក្រោយមក គេនៅឃើញនៅខាងលិច។ លិចហ្នឹងក៏ផ្ទះថ្មដូចគ្នាដែរ។ អាហ្នឹងវា

ត្រីកោណ។

**ស៖** លោកបាននិយាយថា គឺតែងតែមានអ្នកនៅប្រចាំការនៅមន្ទីរណាមួយដើម្បីទទួលលិខិត ឬក៏ការបញ្ជូនព័ត៌មាននានា។ ថាតើមន្ទីរនៅអង្គរកាគឺជាអ្នកចាំទទួលព័ត៌មានហ្នឹង ឬមួយក៏នៅកន្លែងណាផ្សេងដែលចាំទទួលព័ត៌មាន ចាំទទួលអ្វីៗទាំងអស់នោះ?

**ឆ៖** មន្ទីរអង្គរកាហ្នឹងមាននីរសារ មានសេដ្ឋកិច្ចនៅហ្នឹង មានសំបុត្រមានអី យកមកត្រឹមហ្នឹង ហើយនិងបញ្ជូនបន្តទៅ វាយតាមឃុំ។ តាគាវ នៅឃុំញ៉ែងញ៉ង បញ្ជូនទៅតាគាវ។ ខ្ញុំនៅឃុំស្រែរនោង បញ្ជូនខ្ញុំទៅស្រែរនោង ដល់ខ្ញុំដឹងឡើងមក មានការអីអ៊ីចឹង រឿងប៉ុណ្ណឹងទេ មិនមានអីទេ។

[១៥:៤១:២០]

**ស៖** បើយើងបានស្តាប់ឮចម្លើយដែលបានឆ្លើយមួយរយៈកន្លងមក អំពីមនុស្សមួយចំនួនដែលមានតួនាទីជាប្រធានមន្ទីរស្រុក ដែលជាតួនាទីមួយដាច់ដោយឡែកពីលេខាស្រុក ក្នុងចំណោមអ្នកទាំងនេះដែលបានតួនាទីនេះ គឺមនុស្សម្នាក់ដែលលោកបានស្គាល់ឈ្មោះថា ឌឿន -- ដន សូមទោស ដន។ តើ ដន ជាប្រធានមន្ទីរស្រុកត្រាំកក់ ឬក៏មិនមែនទេនៅពេលដែលលោកធ្វើជាប្រធានមន្ទីរស្រុកហ្នឹង?

**ឆ៖** ដន ប្រធានមន្ទីរមែន។

**ស៖** តើ ដន ធ្វើការជាអចិន្ត្រៃយ៍នៅមន្ទីរស្រុកនៅឯអង្គរកា ឬក៏គាត់ធ្វើការនៅទីកន្លែងផ្សេងទៀតដែរ?

**ឆ៖** អចិន្ត្រៃយ៍ធ្វើនៅហ្នឹង ប៉ុន្តែមានរឿងទាក់ទង ចល័តៗទៅជួប មិនមែនដឹកមន្ទីរតាមទេ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើ ដន មានការទទួលខុសត្រូវអ្វីខ្លះក្នុងឋានៈគាត់ជាប្រធានមន្ទីរស្រុក ហើយថាតើការទទួលខុសត្រូវទាំងអស់នេះ វាខុសពីលោកយ៉ាងម៉េចដែរក្នុងឋានៈលោកជាលេខាស្រុកនោះ?

[១៥:៤៣:៥២]

**ឆ៖** អត់មានអី សិទ្ធិប្រធានមន្ទីរដូចស្រុកមិនមានទេ ជាមនុស្សដែលមនុស្សប្រើ ថ្នាក់ស្រុកប្រើណែនាំឲ្យធ្វើអី ធ្វើហ្នឹង ឲ្យកោះហៅប្រជុំ ប្រជុំ ឲ្យប្រមូលផលស្រូវប៉ុន្មានតោនដាក់នៅហ្នឹង ប្រមូលមកចេញឲ្យអស់គ្រប់តំបន់ គ្រប់ខេត្ត រកៗពូជ ដោះស្រាយអ៊ីចឹង។ វាជាជំនួយការ បើអត់មានមន្ទីរ។ ស្រុកពីរបីនាក់ហ្នឹងទៅរែក ទៅលីធ្វើម៉េចបាន។ សូមអស់។

**ស៖** តើលោកនៅចាំទេ អ្នកណាជាប្រធានមន្ទីរស្រុកមុន ដន?

**ឆ៖** នឹកមិនឃើញ មាន ដន ហ្នឹងយូរហើយ។ មានដន, មានភី។ យូរណាស់ នឹកមិនឃើញ។

**ស៖** ខ្ញុំសូមសួរមនុស្សម្នាក់ដែលលោកទើបនិយាយឈ្មោះគាត់អម្បាញ់មិញ ឈ្មោះ ភី ។ យើងបានឮរឿងរ៉ាវរបស់បុគ្គលម្នាក់ឈ្មោះ ភី ដែលបានគេ -- ដែលគេថាវាពិការជើង ឬក៏កំពៀចជើងហ្នឹង។ តើ ភី ហ្នឹងជា ភី តែមួយទេ គឺ ភី ដែលធ្វើជាប្រធានមន្ទីរហ្នឹង តែមួយទេ ឬក៏ម៉េច?

**ឆ៖** តែមួយហ្នឹងទេ។ ភី នោះធ្វើពេទ្យទេ, ដន ប្រធានមន្ទីរ។ ហ្នឹងចាត់តាំងអ៊ីចឹង ចេះចាក់ថ្នាំ។

**ស៖** ហើយមនុស្សម្នាក់ឈ្មោះ ភី ដែលលោកកំពុងតែនិយាយនេះ តើគាត់ជាមនុស្សដែលមានជើងពិការ ឬក៏មិនមែនទេ?

[១៥:៤៧:២២]

**ឆ៖** នោះហើយ។ គាត់ពិការជើង ធ្វើការអត់កើត អត់ប៉ានចាក់ថ្នាំ ដើរចែកថ្នាំគ្រប់ឃុំគ្រប់ភូមិ ព្យាបាលអ្នកជំងឺ។

**ស៖** តើលោកនៅចាំបានទេ មានពេលណាមួយដែល ភី មានតួនាទី ឬក៏មុខងារណាផ្សេងទៀតក្រៅពីទទួលខុសត្រូវខាងផ្នែកចាយថ្នាំនេះ?

**ឆ៖** កាលខ្ញុំនៅ ប្រើអ៊ីចឹង ប៉ុនដល់ខ្ញុំចេញ មិនដឹងគេប្រើយ៉ាងម៉េច។ កាលខ្ញុំនៅនោះ អត់មានឲ្យធ្វើអីក្រៅពីចែកថ្នាំទេ។ ធ្វើការតិចតួច មើលក្មេងក្នុងក្នុងមន្ទីរអីហ្នឹង អត់មានទៅណាទេ។ ហើយក្រោយមក ខ្ញុំចេញហួស ដឹងមានផ្លាស់យកទៅណាទៀត ក្តាប់អត់បាន។

**ស៖** សំណួររបស់ខ្ញុំទាក់ទងទៅនឹងឈ្មោះ ភី។ តើលោកបានដឹងថាគាត់បន្តធ្វើការនៅស្រុកត្រាំកក់នេះ ពេញមួយអំឡុងពេលដែរឬអត់ គឺចាប់ពីខែមេសា ១៩៧៥ រហូតដល់ថ្ងៃទី០៧ មករា ១៩៧៩?

**ឆ៖** គាត់ធ្វើរហូតមក។ តាំង១៧ មេសា រហូតមករំដោះទូទាំងប្រទេសហើយ។ ៧៦ ខ្ញុំចេញមក គាត់នៅនោះឯង។ ដន ហ្នឹង គាត់នៅហ្នឹង។

[១៥:៥០:០៨]

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងមន្ទីរស្រុក។ លោកបានឆ្លើយថា នៅពេលដែលលោកផ្លាស់ទៅកំពង់ចាម គឺ ដន ក៏ទៅជាមួយលោកដែរ។ តើលោកដឹងទេ អ្នកណាក្លាយទៅជាប្រធានមន្ទីរថ្មីនៅពេលនោះ នៅពេលដែល ដន ហ្នឹង ទៅកំពង់ចាមជាមួយលោក?

**ឆ៖** សូមជម្រាប ដន ទៅក្រោយ។ ខ្ញុំទៅអត់មាន ដន ទេ, ដន នៅហ្នឹង។ បានប្រាំមួយខែស្មាន ប្រហែលប្រាំមួយខែ ខ្ញុំមកលេងស្រុក មកជាមួយគ្រួសារជាមួយអី ដល់នេះ ដន គេសុំទៅ។

សុំទៅ ហើយ "ឯងសុំ គិត ទៅ"។ ទៅមុន បម្រុងយក បងគិត អត់ឲ្យៗ ប៉ុននៅ ហើយវាសុំបាន។ ឲ្យទៅ។ ប៉ុន្តែក្រោយមក ស្លាប់ហើយ។ គាត់ទៅធ្វើការនៅចម្ការកប្បាស ស្លាប់បាត់ហើយ។ អស់។

[១៥:៥១:៣៧]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំក្រឡេកមើលទៅនាឡិកាទៅ ហើយខ្ញុំដឹងថាយើងឈប់សម្រាក១០នាទី មុនធម្មតា។ ឥឡូវនេះ ខ្ញុំត្រូវប្តូរប្រធានបទថ្មី សូមសួរថាតើវាជាពេលមួយសមស្របឈប់សម្រាកសិន ដោយសារតែខ្ញុំនៅសល់ពេលតែ១០នាទី។ បាទ សុំដើម្បីដាក់សារណា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោក ពេជ្រ ជឹម ដំណើរការស្តាប់សក្ខីកម្មរបស់លោក ក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត គឺថ្ងៃទី ថ្ងៃពុធ ទី២២ ខែមេសា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ នាពេលនេះលោកអាចវិលត្រឡប់ទៅកាន់កន្លែងដែលលោកស្នាក់នៅបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកគាំពារសាក្សី និងអ្នកជំនាញ ជូនលោក ពេជ្រ ជឹម វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណចំពោះលោកមេធាវី មឿន សុវណ្ណ ហើយមេធាវីអាចសម្រាកបានហើយ ហើយថ្ងៃស្អែកសូមអញ្ជើញមេធាវីមកចូលរួមបន្តប្រឹក្សាសាក្សី ពេជ្រ ជឹម តាមពេលវេលាដែលបានកំណត់អម្បាញ់មិញនេះ។ សូមអញ្ជើញចុះ!

[១៥:៥៣:៤៤]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើ -- ស្តាប់នូវសារណាផ្ទាល់មាត់តបរបស់សហ -- តំណាងសហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក នួន ជា ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីចំនួន១៥រូបថែមទៀត ពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ត្រាំកក់ និងទីកន្លែងមន្ទីរសន្តិសុខក្រាំងតាចាន់ ដូចឯកសារ E346។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងលើកឡើងសង្ខេបទេ។ ខ្ញុំសូមលើកឡើងនូវចំណុចមួយចំនួន យើងខ្ញុំមានការព្រួយបារម្ភពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្តែងនេះ ចុងក្រោយទាក់ទងទៅនឹងសាក្សីរូបនេះ។ ហើយក្នុងពេលជាមួយគ្នានេះដែរ យើងខ្ញុំយល់ឃើញថា ត្រូវតែសម្រេចទៅលើអង្គសេចក្តីមិនមែនសម្រេចទៅលើបញ្ហានីតិវិធីនោះទេ។

ទាក់ទងទៅនឹងបញ្ហានេះ គឺថាមានសាក្សីពីររូបដែលយើងខ្ញុំបានស្នើសុំ ហើយដែលយល់ឃើញថា វាមានអាចនឹងដាក់នូវភស្តុតាងដោះបន្ទុក។ ហើយសាក្សីដែលខ្ញុំកំពុងតែនិយាយយោងទៅនេះ ខ្ញុំនឹងមិននិយាយឈ្មោះទេ។ សាក្សីនោះឈ្មោះ មានរហស្សនាមតែពីរបីនាក់ទេ ប៉ុន្តែសាក្សីទី១នេះ គឺជាសាក្សីទី១ ដែលកំណត់នៅក្នុងសំណើសុំពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើទាហានលន់នល់។ ហើយលោកកូប៉េ បានប្រើឈ្មោះសាក្សីរូបនេះ ដែលបានផ្តល់សក្ខីកម្មនៅទីនេះ។ ភស្តុតាងពីសាក្សីរូបនេះ គឺថាអាចជាជនសង្ស័យ ប៉ុន្តែខ្ញុំជឿថាយើងត្រូវតែស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ។ តាមដែលខ្ញុំយល់ គឺថាមិនត្រូវការឆ្លើយអីយូរទេ គាត់គឺជាកម្មាភិបាលមកពីផ្នែកមួយផ្សេងនៃភូមិភាគនិរតីធ្វើការនៅត្រាំកក់។

[១៥:៥៦:៣១]

សាក្សីម្នាក់ទៀត ដែលតាមការយល់ឃើញរបស់យើងខ្ញុំ ក៏មានភស្តុតាងដោះបន្ទុក។ សាក្សីនេះពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ គឺជាបុគ្គលម្នាក់ដែលខ្ញុំបានកំណត់អត្តសញ្ញាណដោយផ្ទាល់។ គឺសាក្សីដែលបានផ្តល់សក្ខីកម្មនៅទីនេះថាគាត់ គឺជាចារីម្នាក់ដែលពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សាក្សីរូបនេះ គឺថាបានបដិសេធមិនឆ្លើយខ្លះហើយ ប៉ុន្តែមានការទទួលស្គាល់ ហើយមេធាវីការពារក្តីហ្នឹងគាត់ចង់ស្តាប់សាក្សីរូបហ្នឹង ដែលត្រូវបានគេកំណត់ថាជាអ្នកប្រព្រឹត្តដោយផ្ទាល់ដៃ ប៉ុន្តែគាត់បានបដិសេធទៅ។ ដូច្នេះ យើងខ្ញុំក៏ស្នើសុំអង្គជំនុំជម្រះឲ្យស្តាប់សក្ខីកម្មសាក្សីរូបនេះ។

បន្ថែមពីលើនេះទៀត ដូច្នេះខ្ញុំសូមស្នើសុំអង្គជំនុំជម្រះអនុវត្តនូវឆន្ទានុសិទ្ធរបស់ខ្លួន ដើម្បីឈានទៅដល់ការស្វែងរកការពិត។

ទាក់ទងទៅនឹងសាក្សីដទៃៗទៀត យើងខ្ញុំបានឃើញថាមានការជំទាស់តវ៉ាថា ភស្តុតាងមានភាពច្របូកច្របល់ណាស់។ ដូច្នេះ យើងខ្ញុំស្នើសុំឲ្យមានការស្តាប់សាក្សីដទៃទៀត។ ខ្ញុំគិតឃើញថា មេធាវីការពារក្តី គឺថាសប្បាយចិត្តណាស់ បើកាលណាភស្តុតាងវាមានចម្រូងចម្រាស់បែបនេះ។ អ៊ីចឹងយើង -- កម្មាភិបាល ក៏ដូចជាជនរងគ្រោះ គឺយល់ស្របទៅនឹងចំណុចភាគីច្រើនទៅហើយ។ ហើយអ្នកខ្លះត្រូវ

បានគេចាប់យកទៅក្រាំងតាចាន់សម្លាប់ចោល អ្នកខ្លះក៏ត្រូវបានដោះលែង អ្នកខ្លះត្រូវបានទទួលធ្វើទារុណកម្ម គេច្រកស្បោងកៅស៊ូដើម្បីឲ្យថប់ដង្ហើម។ មានការយល់ស្របគ្នាភាគច្រើនទៅលើអង្គហេតុទាំងអស់នេះ។ ដូច្នេះ សម្រាប់មេធាវីការពារក្តី គឺថាយើងខ្ញុំស្នើសុំឲ្យស្តាប់បន្ថែមទៀតពាក់ព័ន្ធទៅនឹងភស្តុតាងចម្រូងចម្រាស់បែបនេះ។

ដូច្នេះ អាស្រ័យទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ខ្ញុំសូមធ្វើការកត់សម្គាល់មួយចំនួនដូចខាងក្រោមនេះ។ មេធាវីការពារក្តីមានការស្នើសុំមួយចំនួន ពីរនាក់គឺជា ពាក់ព័ន្ធទៅនឹងសាក្សីដទៃៗទៀតបានឆ្លើយរួចមកហើយ។ ខ្ញុំថាមិនចាំបាច់ទេជាមួយអ្នកពីរនាក់នេះ។ ហើយបើសិនណាអង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មរបស់អ្នកទាំងនេះ គឺស្នើសុំឲ្យស្តាប់កម្មាភិបាលដែលជាពេទ្យនារីហ្នឹង គឺថាជាការប្រសើរជាជាង។ ហើយមេធាវីការពារក្តីនិយាយហើយពីការប្រទូស ចម្រូងចម្រាស់ជាមួយគ្នាពាក់ព័ន្ធទៅនឹងការប្រទូសរ៉ាយផ្លូវភេទ -- ប្រទូសផ្លូវភេទនេះ។

[១៥:៥៩:៣០]

ខ្ញុំសូមបញ្ជាក់ថាហេតុអ្វីក៏វាមានការពាក់ព័ន្ធគ្នា? ជនជាប់ចោទមិនត្រូវបានចោទប្រកាន់ទៅលើការរំលោភផ្លូវភេទបែបនេះទេ។ ប៉ុន្តែគេចោទប្រកាន់អំពើមនុស្សឃាតដោយចេតនា។ ដូច្នេះ សាក្សីដែលជាពេទ្យកម្មាភិបាលនារីនេះគឺជាការមួយស្នើសុំ អាស្រ័យទៅលើការពិចារណារបស់អង្គជំនុំជម្រះ។ ហើយតាមការយល់ឃើញរបស់ខ្ញុំ គឺអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទេ។ អ្នកយាមម្នាក់ទៀត ពីរនាក់គឺថា យើងមិនដឹងថានៅរស់ ឬក៏អត់។ យើងស្គាល់ឈ្មោះរបស់គេម្នាក់គឺបានផ្តល់ចម្លើយហើយគាត់ធ្វើការជាមួយនឹងអង្គភាពតែមួយ។ ខ្ញុំមិនដឹងថាតើគាត់មានព័ត៌មានអីបន្ថែមច្រើនបាន ឬក៏អត់នោះទេ។

មានកម្មាភិបាលពីរនាក់ទៀត ម្នាក់គឺ 2-TCW-833 យើងយល់ស្របជាមួយមេធាវីការពារក្តីហើយថា បុគ្គលរូបនេះត្រូវតែកោះហៅមកស្តាប់ចម្លើយ ពីព្រោះគាត់ពាក់ព័ន្ធទៅនឹងការបោសសម្អាត។ ហើយសាក្សីម្នាក់ទៀត យើងបានស្នើសុំ ពីព្រោះថាគាត់ជានីរសារនៅស្រុកត្រាំកក់ ហើយក្រោយមកគាត់ធ្វើការជាមួយ វន វ៉េត ហើយក៏ត្រូវបានចាប់ខ្លួនពេលជាមួយនឹង វន វ៉េត។ នេះជាមូលហេតុចម្បងហើយដែលយើងខ្ញុំស្នើសុំ វាមាននៅក្នុងបញ្ជីរបស់យើងខ្ញុំ ហើយយើងមិនបានបង្ហាញព័ត៌មានពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ក្រោយៗមកទៀតជាមួយបុគ្គលរូបនោះទេ។

ដូច្នេះ តាមការយល់ឃើញរបស់យើងខ្ញុំ គឺថាត្រូវស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះពាក់ព័ន្ធទៅ

នឹងការបោសសម្អាត។ ប្ដីរបស់គាត់ដែលពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ ខ្ញុំថាមិនជាការចាំបាច់នោះទេ។ ហើយក៏មានសំណើសុំឲ្យហៅអ្នកប្រព្រឹត្តដោយផ្ទាល់ដៃមកសួរ។ អានេះ ខ្ញុំយល់ថាមិនជាចាំបាច់អីត្រូវប្ដីរបស់គាត់នោះទេ។ ហើយមានសាក្សីបន្ថែមទៀតទៅលើឯកសារដែលបានដាក់ គឺខ្ញុំគិតថាសាក្សីទាំងនេះគឺជាសាក្សីដែលមានអត្ថិភាពខ្ពស់។ យើងក៏បានសួរពាក់ព័ន្ធទៅនឹងៗយថាភាពនៃឯកសារទាំងនេះដែរ ហើយពួកគេបាននិយាយថាមានព័ត៌មានតិចតួចណាស់ដែលត្រូវបន្ថែមទៅលើចម្លើយទាំងអស់នេះ។ ហើយយើងបានស្ដាប់សក្ខីកម្មសាក្សីមួយចំនួននោះ ឃើញថាវាមានភាពស៊ីសង្វាក់គ្នាពាក់ព័ន្ធទៅនឹងបញ្ហាឯកសារទាំងអស់នេះ។ បាទ សូមអស់ហើយលោកប្រធាន។

[១៦:០២:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន តើមានអ្វីចង់លើកឡើងជាសារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងបញ្ហាសំណើសុំរបស់ក្រុមមេធាវីការពារក្ដីលោក នួន ជា នេះដែរឬទេ? សូមអញ្ជើញប្រសិនបើមានបាទ។

**លោក អាកឡូរ វ៉ែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំកំពុង -- ខ្ញុំភ្ញាក់ផ្អើលនៅពេលឃើញសហព្រះរាជអាជ្ញាគាត់រិះគន់ខាងមេធាវីការពារ នួន ជា ថាស្នើសុំឲ្យកោះហៅសាក្សី១៥នេះ។ គឺថាចុះគាត់វិញផ្ដល់ឯកសារមកទាំងដុំៗមកឲ្យយើងនៅចុងក្រោយហ្នឹង យើងនៅស្ងៀម យើងមិនរិះគន់អីផង។ ខ្ញុំគិតថាអង្គជំនុំជម្រះអាចស្ដាប់សាក្សីទាំង១៥ហ្នឹង ខ្ញុំគាំទ្រសំណើរបស់មេធាវីការពារក្ដីលោក នួន ជា ១០០ភាគរយតែម្ដង។ ខ្ញុំគិតថាយើងអាចទៅបានលឿន បានទៅមុខ។ ជាពិសេសគឺថា អាចសួរបានទៅលឿនផង។ ហើយកាលពីព្រឹកមិញនេះ សហព្រះរាជអាជ្ញាបានសួរសាក្សីអំពីអង្គរកា ខ្មែរក្រោម សួរអំពីការជម្លៀសដោយបង្ខំដែលនៅក្រៅវិសាលភាពនៃសវនាការ។ អ៊ីចឹងនេះគឺជាកត់សម្គាល់របស់ខ្ញុំ គឺថាខ្ញុំគាំទ្រទៅលើសំណើរបស់មេធាវីការពារក្ដីលោក នួន ជា។

[១៦:០៤:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះមេធាវីការពារក្ដីលោក នួន ជា មានអ្វីឆ្លើយតបនឹងសារណាផ្ទាល់មាត់របស់តំណាងសហព្រះរាជអាជ្ញាដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមានទេ លោកប្រធាន យើងខ្ញុំនៅតែរក្សាសំណើសុំរបស់យើងខ្ញុំដដែល។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណដែលបាន -- នូវរាល់មតិយោបល់ដែលបានលើកឡើងពាក់ព័ន្ធជាមួយនឹងសំណើសុំរបស់លោក ក្រុមមេធាវីការពារក្ដីលោក នួន ជា ក្នុងការសុំឱ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សីបន្ថែមចំពោះអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ១៥នាក់ទៀត នូវតាមឯកសារ E346 នេះ។ ហើយអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការពិនិត្យពិចារណា ហើយនិងចេញសេចក្ដីសម្រេចលើបញ្ហានេះឆាប់ៗ ក្នុងពេលឆាប់ៗខាងមុខនេះ។

បាទ ហើយនៅសវនាការនៅថ្ងៃនេះ ឃើញថា ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែកថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៥ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ពេជ្រ ជឹម សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឱ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*